ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
អគ្គនាយកដ្ឋានអប់រំ
នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ

# របាយការណ៍កិច្ចការស្រាវជ្រាវ
# ការអប់រំសិទ្ធិមនុស្សក្នុងប្រព័ន្ធសាលារៀនប្រទេសកម្ពុជា

ស្រាវជ្រាវដោយ
លោកស្រី ជិន យ៉ាហាន

9006

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

អគ្គនាយកដ្ឋានអប់រំ

នាយកដ្ឋានស្រាវជ្រាវគរុកោសល្យ

# របាយការណ៍កិច្ចការស្រាវជ្រាវ
# ការអប់រំសិទ្ធិមនុស្សក្នុងប្រព័ន្ធសាលារៀន

## I. **បរិបទ**

### ១. បរិបទប្រវត្តិសាស្ត្រ

ប្រទេសកម្ពុជាជាប្រទេសដែលស្ថិតនៅចន្លោះខ្សែស្របទី ១០ និងទី១៥ នៃរយៈទទឹងខាងជើង និងស្ថិតនៅចន្លោះខ្សែស្របទី ១០២ និង ១០៨ នៃរយៈបណ្តោយខាងកើត។ ស្ថិតក្នុងប្រវត្តិដ៏យូរលង់តាំងពីកំណាក់ណើតទឹកដី ប្រទេសកម្ពុជាទើបតែជួបភាពរងគ្រោះធ្ងន់ធ្ងរដោយសង្គ្រាមស៊ីវិលរ៉ាំរ៉ៃ រយៈពេលរហូតដល់ទៅជាងពីរទសវត្សរ៍ ដែលទើបត្រូវបានបញ្ចប់ប៉ុន្មានឆ្នាំកន្លងទៅនេះ។ បច្ចុប្បន្ន ប្រទេសកម្ពុជាមានប្រជាជនសរុបប្រមាណ ១៣ លាននាក់ រស់នៅលើផ្ទៃប្រទេសដែលមានទំហំ ១៨១ 000.0៣៥ គីឡូម៉ែតការេ។

ក្នុងរយៈកាលដែលស្ថិតក្នុងសង្គ្រាមស៊ីវិលរ៉ាំរ៉ៃ សោកនាដកម្មដ៏ធ្ងន់ធ្ងរបំផុតដែលប្រជាពលរដ្ឋនៅចងចាំមិនភ្លេច គឺ " ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ " ក្នុងសម័យ " ខ្មៅងងឹត " ដែលបានចាប់ផ្តើមពីថ្ងៃ ១៧ មេសា ១៩៧៥ និងបញ្ចប់ នៅថ្ងៃ 0៧ មករា ឆ្នាំ ១៩៧៩។ សម័យ " ខ្មៅងងឹត " បានធ្វើឱ្យខ្ទេចខ្ទាំសង្គមទាំងស្រុង។ ប្រជាពលរដ្ឋជាង៣លាននាក់ ត្រូវបានសម្លាប់។ ឯអ្នកសល់ពីស្លាប់ ជាង៣លាននាក់ សុទ្ធសឹងជាជនរងគ្រោះដោយអំពើរំលោភសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ មានការធ្វើទារុណកម្ម និងការដាក់ជាពលករដោយបំពាន។ ថ្ងៃរំដោះ ៧ មករា ១៩៧៩ ដែលដឹកនាំដោយរណសិរ្ស សាម គ្គីសង្គ្រោះជាតិ បាននាំយកមកវិញនូវសេរីភាពក្នុងការដើរហើរ សេរីភាពក្នុងការបង្កើតសមាគម សេរីភាពក្នុងជំនឿ សេរីភាពក្នុងការរស់នៅ សេរីភាពក្នុងអាពាហ៍ពិពាហ៍ និងសេរីភាពក្នុងការបំពេញអ្វីដែលជាតម្រូវការចាំបាច់របស់មនុស្ស។



រូបថតរបស់ DCCAM in Phnom Penh :



LIBRARY - BIBLIOTHEQUE
OHCHR
HRE/ASP/CMB/3

ដំណើរត្រឡប់មកស្រុកភូមិរបស់ប្រជាជនកម្ពុជានៅថ្ងៃបញ្ចប់របបខ្មែរក្រហម

នៅក្នុងកម្មវិធីដែលបានផ្សព្វផ្សាយភ្លាមៗបន្ទាប់ពីការរំដោះនៅទីក្រុងភ្នំពេញ ចំណុចសំខាន់ៗ ត្រូវបានលើកឡើងដើម្បីបង្ហាញនូវការប្ដេជ្ញាចិត្តជាផ្លូវការ ដែលមានពាក់ព័ន្ធនឹងការគោរពសិទ្ធិមនុស្សជាបឋម ។ "សេចក្ដីថ្លែងការណ៍បានប្រកាសឡើង ថាសាធារណរដ្ឋប្រជាមានិតកម្ពុជាកំពុងតែបំពេញសកម្មភាពការងារសមស្របតាមបំណងរបស់ប្រជាជន គឺធ្វើឱ្យសម្រេច សេរីភាពក្នុងការគោរពប្រជាធិបតេយ្យ សេរីភាពក្នុងជំនឿសាសនា សិទ្ធិក្នុងការធ្វើការងារ ក្នុងការសំរាក និងក្នុងការងារអប់រំ សិទ្ធិសេរីភាពទទួលការគារពសេចក្ដីថ្លៃថ្នូរជាមនុស្សនិងភាពជាឯកជនរបស់ប្រជាពលរដ្ឋគ្រប់រូប ការគោរពសមភាពភេទ និងសមភាពក្នុងបណ្ដាជាតិសាសន៍ផ្សេងៗដែលរស់នៅក្នុងប្រទេសកម្ពុជា ។

សាធារណរដ្ឋប្រជាមានិតកម្ពុជាបានដើរតាមគោលនយោបាយក្រៅប្រទេសអំពីសន្តិភាព មិត្តភាព និងមិនចូលបក្សសម្ព័ន្ធ ដោយប្រឹងប្រែងរួមវិភាគទានដើម្បីមូលហេតុសន្តិភាព ស្ថេរភាព និងវិបុលភាពនៅក្នុងតំបន់អាស៊ី អាគ្នេយ៍ និងដើម្បីមូលហេតុសន្តិភាព និងការរីកចំរើនក្នុងពិភពលោក។

ក្រោយថ្ងៃរំដោះ៧មករា ប្រទេសកម្ពុជាបានងើបឡើងពីចំណុចសូន្យនៃការវិនាសអន្តរាយទាំងស្រុង រួមទាំងហេដ្ឋារចនាសម្ព័ន្ធសង្គម សេដ្ឋកិច្ច និងវប្បធម៌។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ បណ្ដាអ្នកស្នេហាជាតិបានរួមគ្នាស្តារ និងកសាងជាតិឡើងវិញលើគ្រប់វិស័យតាមគ្រប់មធ្យោបាយដើម្បីសង្គ្រោះប្រជាជន ដោយមានការឧបត្ថម្ភគាំទ្រផ្សេងៗពីសប្បុរសជននៅក្នុងនិងក្រៅប្រទេស ។

## ២. បរិបទច្បាប់/រដ្ឋធម្មនុញ្ញ

ពីឆ្នាំ ១៩៧៩ ដល់ ២០០៨ ក្នុងដំណើរតស៊ូកសាងជាតិឡើងវិញ ការស្តារឯកភាពជាតិ ក៏ដូចជាការទទួលខុសត្រូវចំពោះជោគវាសនាប្រទេសជាតិដែលមានការលូតលាស់ទៅរកការរីកចំរើន ការអភិវឌ្ឍ វិបុលភាព និងជ័យជនះ និងក្នុងបំណងស្ថាបនានីតិរដ្ឋ រដ្ឋសភាជាតិក្នុងអាណត្តិនីមួយៗបានផ្ដល់សច្ចាប័នទទួលយកកតិកាសញ្ញា អនុសញ្ញាអន្តរជាតិមួយចំនួន និង បានធ្វើវិសោធនកម្មលើមាត្រា ឬជំពូកមួយចំនួននៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៨១ ជាបន្តបន្ទាប់ រហូតបានមកដល់រដ្ឋធម្មនុញ្ញបច្ចុប្បន្នដែលបានទទួលការអនុម័តពីឆ្នាំ ១៩៩៣។ នៅទន្ទឹមគ្នានេះដែរ រដ្ឋសភានៃប្រទេសកម្ពុជា ក៏បានចាប់ផ្ដើមអោយសច្ចាប័នលើកតិកាសញ្ញា អនុសញ្ញាសិទ្ធិមនុស្សជាច្រើនរបស់អង្គការសហប្រជាជាតិ តាំងពីកំណើតនៃរដ្ឋាភិបាលថ្មី ឆ្នាំ១៩៧៩ ។

ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ១៩៨១ ជាថ្ងៃប្រកាសអោយប្រើ **រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា** ។ ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៨១ នេះ មាន ៩០មាត្រា នៅក្នុង ៩ជំពូក ដែលមានការធានា និងចែងដោយលំអិតពីការគោរព **អនុសញ្ញាស្ដីពីការបង្ការ និងផ្ដន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍**[1] ក្រោមការដឹកនាំរបស់បក្សនយោបាយតែមួយ គឺគណបក្សប្រជាជនបដិវត្តកម្ពុជា។ នៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៨៩ មានការដាក់ចូលជាធរមាន **ច្បាប់រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា** ដែលបានធ្វើវិសោធនកម្មលើមាត្រាចំនួន ៣ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៨១ ( រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា) ។ វិសោធនកម្ម បានផ្ដោតទៅរកការធ្វើឱ្យមានរបបនយោបាយពហុបក្ស ការពង្រាវអាណត្តិរបស់រដ្ឋសភា និងការ

[1] អនុសញ្ញាស្ដីពីការបង្ការ និងផ្ដន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ សរសេរពីឆ្នាំ ១៩៤៨ ចូលជាធរមានជាសកលនៅឆ្នាំ ១៩៥១ ចូលជាធរមាននៅកម្ពុជា ឆ្នាំ ១៩៥១។

បញ្ចាក់ពីកាតព្វកិច្ច របស់ក្រុមប្រឹក្សាជាតិ ។

ដើម្បីផ្សះផ្សារជាតិ កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសត្រូវបានអនុម័តនៅថ្ងៃ២៣ ខែតុលា ឆ្នាំ ១៩៩១ ដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ដែលជាអង្គភាពស្របច្បាប់ និងជាអាជ្ញាធរកំពូលតែមួយគត់ ដែលធានាការដាក់តំកល់អធិបតេយ្យភាព ឯករាជ្យភាព និងការឯកភាពជាតិជាធំ នៅសម័យអន្តរកាល ។ ផ្នែកទី ៣នៃកិច្ចព្រមព្រៀងនេះ និយាយអំពីសិទ្ធិមនុស្ស ដែលក្នុងនោះ មាត្រាទី១៥ មានចែងថា :

១) មនុស្សគ្រប់រូបនៅប្រទេសកម្ពុជា ជនភៀសខ្លួន និងជនផ្លាស់ប្តូរទីកន្លែងនៅកម្ពុជាទាំងអស់ត្រូវមានសិទ្ធិ និងសេរីភាព ដែលមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងក្នុងបណ្តាកិច្ចព្រមព្រៀងអន្តរជាតិទាំងឡាយដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស ។

២) ដើម្បីសំរេចបានដូចនេះ :

ក- ប្រទេសកម្ពុជាសន្យាថា :

- ធានាគោរពនិងប្រតិបត្តិតាមសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់មនុស្ស នៅក្នុងប្រទេសកម្ពុជា
- គាំទ្រសិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូប
- ព្យាយាមធ្វើសកម្មភាពដែលនឹងលើកកំពស់និងការពារសិទ្ធិ និងសេរីភាពជាមូលដ្ឋានរបស់មនុស្ស
- បន្តដើរតាមកតិកាសញ្ញាសិទ្ធិមនុស្សអន្តរជាតិពាក់ព័ន្ធនានា ។

ខ- ហត្ថលេខីទាំងឡាយ នៃកិច្ចព្រមព្រៀងនេះ ធានាលើកកំពស់ រួមទាំងលើកទឹកចិត្តការគោរពនិងប្រតិបត្តិសិទ្ធិមនុស្សនិងសេរីភាពជាមូលដ្ឋានក្នុងប្រទេសកម្ពុជា ដែលមានចែងក្នុងកតិកាសញ្ញាអន្តរជាតិពាក់ព័ន្ធ និង សេចក្តីសំរេចចិត្តទាំងឡាយរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ជាពិសេសដើម្បីការពារទប់ទល់នឹងការកកើតឡើងវិញនូវការរំលោភសិទ្ធិមនុស្ស ។

នៅថ្ងៃទី ៦ ខែមេសា ឆ្នាំ ១៩៩២ ច្បាប់រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា ដែលមានវិសោធនកម្មលើ ៦មាត្រានៃ ច្បាប់រដ្ឋធម្មនុញ្ញលើកមុន ( ឆ្នាំ ១៩៨៩) បានអនុម័ត ។ វិសោធនកម្មបានផ្តោតជាសំខាន់លើក្របខ័ណ្ឌអំណាចរបស់រដ្ឋសភា អាណត្តិ និងភារកិច្ចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលបានចាត់ទុកជារដ្ឋាភិបាលនៃរដ្ឋកម្ពុជា ។

ឆ្នាំ ១៩៩២ មានការផ្តល់សច្ចាប័ននៅកម្ពុជា ដល់អនុសញ្ញាអន្តរជាតិចំនួន ៧ គឺ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ [២] អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ [៣] អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់

[២] អនុសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ សរសេរពីឆ្នាំ ១៩៦៦ ចូលជាធរមានជាសកលនៅឆ្នាំ ១៩៧៦ ចូលជាធរមាន នៅប្រទេសកម្ពុជា ឆ្នាំ ១៩៩២ ។

នៃការរើសអើងប្រឆាំងនារីភេទ[4] អនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ឬការប្រព្រឹត្តទណ្ឌកម្ម អំពើឃោរឃៅអមនុស្សធម៌ បន្ថោកបន្ទាបតម្លៃមនុស្ស[5] អនុសញ្ញាស្តីពីសិទ្ធិកុមារ[6] អនុសញ្ញាពាក់ព័ន្ធឋានៈនៃជនភៀសខ្លួន[7] និង ពិធីសារពាក់ព័ន្ធ ឋានៈជនភៀសខ្លួន[8] ។

នៅថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ ១៩៩៣ បន្ទាប់ពីមានដំណោះស្រាយរបស់សន្និសញ្ញាសន្តិភាពទីក្រុងប៉ារីស (២៣ តុលា ១៩៩១) រដ្ឋសភាថ្មី នៃអាណត្តិទី ១ ដែលមានសមាជិកចំរុះ ពីគណបក្សនយោបាយពហុភាគី បានផ្តល់សច្ចាប័នលើច្បាប់រដ្ឋធម្មនុញ្ញថ្មីមួយទៀត មានឈ្មោះថា **ច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា** ។ ច្បាប់កំពូលថ្មីនេះ ដែលមាន ១៤ជំពូក ១៣៩ មាត្រា មានចែងអំពីរបបនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស ហើយនិងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ។ នៅជំពូកទី ៣ទាំងមូល ចាប់ពីមាត្រាទី ៣១ ដល់ ៤៨ បានលើកឡើងដោយល្អិតល្អន់ជាងមុន អំពីសិទ្ធិ និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋកម្ពុជា ដោយមានការផ្សារភ្ជាប់ទៅនឹងអនុសញ្ញាអន្តរជាតិមួយចំនួន ។

***ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។***

***ប្រជាពលរដ្ឋខ្មែរមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ឯការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខ័ណ្ឌកំណត់ក្នុងច្បាប់ ។***

ស្របតាមសេចក្តីខាងលើ នៅថ្ងៃ ៣១ ខែឧសភា ឆ្នាំ ១៩៩៧ មានការផ្តល់សច្ចាប័នលើវិសោធនកម្មមាត្រាមួយចំនួន ដើម្បីឱ្យស្របតាមមាត្រា ដែលមានចែងក្នុងអនុសញ្ញា កតិកាសញ្ញាអន្តរជាតិនានា អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ

---

[3] អនុសញ្ញាអន្តរជាតិស្តីពី សិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ សរសេរពីឆ្នាំ ១៩៦៦ ចូលជាធរមានជាសកលនៅឆ្នាំ ១៩៧៦ ចូលជាធរមាន នៅប្រទេសកម្ពុជា ឆ្នាំ ១៩៩២ ។

[4] អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងនារីភេទ សរសេរពីឆ្នាំ ១៩៧៩ ចូលជាធរមានជាសកលនៅឆ្នាំ ១៩៨១ ចូលជាធរមាន នៅប្រទេសកម្ពុជា ឆ្នាំ ១៩៩២ ។

[5] អនុសញ្ញាស្តីពីការប្រឆាំងនឹងការធ្វើទារុណកម្ម ឬការប្រព្រឹត្តទណ្ឌកម្ម អំពើឃោរឃៅ អមនុស្សធម៌ បន្ថោកបន្ទាបតម្លៃមនុស្ស សរសេរពីឆ្នាំ ១៩៨៤ ចូលជាធរមានជាសកលនៅឆ្នាំ ១៩៨៧ ចូលជាធរមាន នៅប្រទេសកម្ពុជា ឆ្នាំ ១៩៩២ ។

[6] អនុសញ្ញាស្តីពីសិទ្ធិកុមារ សរសេរពីឆ្នាំ ១៩៨៩ ចូលជាធរមានជាសកលនៅឆ្នាំ ១៩៩០ ចូលជាធរមាន នៅប្រទេសកម្ពុជា ឆ្នាំ ១៩៩២ ។

[7] អនុសញ្ញាពាក់ព័ន្ធឋានៈនៃជនភៀសខ្លួន សរសេរពីឆ្នាំ ១៩៥១ ចូលជាធរមានជាសកលនៅឆ្នាំ ១៩៥៤ ចូលជាធរមាន នៅប្រទេសកម្ពុជា ឆ្នាំ ១៩៩២ ។

[8] ពិធីសារពាក់ព័ន្ធឋានៈជនភៀសខ្លួន សរសេរពីឆ្នាំ ១៩៦៦ ចូលជាធរមានជាសកលនៅឆ្នាំ ១៩៦៧ ចូលជាធរមាន នៅប្រទេសកម្ពុជា ឆ្នាំ ១៩៩២ ។

និងសិទ្ធិនយោបាយ  អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌  អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនារីភេទ   អនុ សញ្ញាប្រឆាំងនឹងការធ្វើទារុណកម្ម ឬការប្រព្រឹត្តទណ្ឌកម្មអំពើឃោរឃៅអមនុស្សធម៌ បន្ថោកបន្ទាបតម្លៃមនុស្ស អនុសញ្ញាស្តីពីសិទ្ធិកុមារ   អនុសញ្ញាពាក់ព័ន្ធឋានៈនៃជនភៀសខ្លួន   និងពិធីសារពាក់ព័ន្ធឋានៈជនភៀសខ្លួន  ។

នៅថ្ងៃទី ៦ មីនា ១៩៩៩ រដ្ឋសភានៃអាណត្តិទី ២ បានផ្តល់សច្ចាប័នដល់រដ្ឋធម្មនុញ្ញថ្មីមួយ ដោយផ្អែកលើរដ្ឋធម្មនុញ្ញមុន (រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣) និងបានធ្វើវិសោធនកម្មលើមាត្រាចំនួន១១ ដែលចែងដោយលំអិតអំពីភារកិច្ចរបស់ព្រះមហាក្សត្រ មាត្រាចំនួន ១ ចែងអំពីអ្នកដែលមានអាយុយ៉ាងតិច ៤០ឆ្នាំមានសិទ្ធិឈរឈ្មោះជាបេក្ខជន ព្រឹទ្ធសភា និងមាត្រាចំនួន ២៣ ចែងអំពីការបង្កើតស្ថាប័នព្រឹទ្ធសភា និងភារកិច្ចរបស់ព្រឹទ្ធសភា ។

នៅឆ្នាំ ២០០០ មានការផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិមួយចំនួនពាក់ព័ន្ធនឹងពលកម្មអន្តរជាតិជាបន្ថែម ទៀត ដែលជារួមមាន អនុសញ្ញាលេខ ៨៧ ស្តីពីសេរីភាពនៃសមាគម និងការការពារសិទ្ធិនៃការបង្កើតសមាគម [៩] អនុសញ្ញាលេខ ៩៨ ការអនុវត្តគោលការណ៍អំពីសិទ្ធិនៃការបង្កើតសមាគម និងសិទ្ធិនៃការចរចាជាសមូហភាព [១០] អនុសញ្ញា លេខ ១០០ ស្តីពីប្រាក់ឈ្នួលស្មើគ្នាសំរាប់កម្មករនិយោជិតបុរស-ស្ត្រី ចំពោះការងារមានតម្លៃស្មើគ្នា [១១] អនុសញ្ញាលេខ ១០៥ ស្តីពីការលុបបំបាត់ការងារដោយបង្ខំ [១២] អនុសញ្ញាលេខ ១១១ ស្តីពីការរើសអើងក្នុងការងារ និងមុខរបរ [១៣] និង អនុសញ្ញាលេខ ១៣៨ ស្តីពីការកំរិតអាយុអប្បបរមាសំរាប់ការចូលធ្វើការ [១៤] ។

នៅថ្ងៃទី ២ ខែកក្កដា ឆ្នាំ ២០០១ ច្បាប់រដ្ឋធម្មនុញ្ញដែលកំពុងប្រើ ត្រូវបានលើកយកមកធ្វើវិសោធនកម្មនៅមាត្រាចំនួន ២ ដោយបានបញ្ជាក់ពីវិធីតែងតាំងនាយករដ្ឋមន្ត្រី និងក្រុមប្រឹក្សារដ្ឋមន្ត្រី រួមទាំងការផ្តល់គ្រឿងឥស្សរិយយសដែលទទួលការយល់ព្រមពីព្រះមហាក្សត្រ ។

---

[9] អនុសញ្ញាលេខ ៨៧ ស្តីពីសេរីភាពនៃសមាគម និងការការពារសិទ្ធិនៃការបង្កើតសមាគម សរសេរពីឆ្នាំ ១៩៤៨ ចូលជាធរមានជាសកលនៅឆ្នាំ ១៩៥០ ចូលជាធរមាន នៅប្រទេសកម្ពុជា ឆ្នាំ ២០០០ ។

[10] សញ្ញាលេខ ៩៨ ការអនុវត្តគោលការណ៍អំពីសិទ្ធិនៃការបង្កើតសមាគម និងសិទ្ធិនៃការចរចាជាសមូហភាព  សរសេរពីឆ្នាំ ១៩៤៩ ចូលជាធរមានជាសកលនៅឆ្នាំ ១៩៥១ ចូលជាធរមាន នៅប្រទេសកម្ពុជា ឆ្នាំ ២០០០ ។

[11] អនុសញ្ញា លេខ ១០០ ស្តីពីប្រាក់ឈ្នួលស្មើគ្នាសំរាប់កម្មករនិយោជិតបុរស-ស្ត្រី ចំពោះការងារមានតម្លៃស្មើគ្នា សរសេរពីឆ្នាំ ១៩៥១ ចូលជាធរមានជាសកលនៅឆ្នាំ ១៩៥៣ ចូលជាធរមាន នៅប្រទេសកម្ពុជា ឆ្នាំ ២០០០ ។

[12] អនុសញ្ញាលេខ ១០៥ ស្តីពីការលុបបំបាត់ការងារដោយបង្ខំ សរសេរពីឆ្នាំ ១៩៥១ ចូលជាធរ មានជាសកលនៅឆ្នាំ ១៩៥៣ ចូលជាធរមាន នៅប្រទេសកម្ពុជា ឆ្នាំ ២០០០ ។

[13] អនុសញ្ញាលេខ ១១១ ស្តីពីការរើសអើងក្នុងការងារ និងមុខរបរ សរសេរពីឆ្នាំ ១៩៥១ ចូលជាធរ មានជាសកលនៅឆ្នាំ ១៩៥៣ ចូលជាធរមាន នៅ ប្រទេសកម្ពុជា ឆ្នាំ ២០០០ ។

[14] អនុសញ្ញាលេខ ១៣៨ ស្តីពីការកំរិតអាយុអប្បបរមាសំរាប់ការចូលធ្វើការ សរសេរពីឆ្នាំ ១៩៥១ ចូលជាធរ មានជាសកលនៅឆ្នាំ ១៩៥៣ ចូលជាធរមាន នៅ ប្រទេសកម្ពុជា ឆ្នាំ ២០០០ ។

នៅឆ្នាំ ២០០២ មានការផ្តល់សច្ចាប័ន លើអនុសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ចំនួន ២ទៀតគឺ ពិធីសារតាមចិត្តជ្រើសរើសជាប់នឹងអនុសញ្ញាស្តីពីសិទ្ធិកុមារ ពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងកាមសាស្ត្រកុមារ [១៥] និងលក្ខន្តិកៈទីក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ [១៦] ។

នៅថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ច្បាប់រដ្ឋធម្មនុញ្ញត្រូវបានលើកយកមកធ្វើវិសោធនកម្មលើ មាត្រាចំនួន ២ ដោយបញ្ជាក់ពីវិធីថ្មីមួយទៀតក្នុងការតែងតាំងស្ថាប័ននីតិបញ្ញត្តិ និងនីតិប្រតិបត្តិ ។

រួមមក នៅខណៈដែលមានវិសោធនកម្មលើច្បាប់រដ្ឋធម្មនុញ្ញជាច្រើនលើកច្រើនសារ ហើយរដ្ឋសភាក៏បានធ្វើការពិនិត្យ និងអនុម័តច្បាប់ និងអនុក្រឹត្យសំរាប់ប្រើប្រាស់ក្នុងប្រទេសបានរាប់រយច្បាប់ ដំណើរការនៃការអនុវត្តសិទ្ធិមនុស្ស និងប្រជាធិបតេយ្យក៏មានការវិវឌ្ឍទៅមុខ ។ នៅជំពូក ១៣ មាត្រា ១៣១ ស្តីពី អានុភាព ការសើរើ និងវិសោធនកម្មរដ្ឋធម្មនុញ្ញ បានចែងថា " រដ្ឋធម្មនុញ្ញនេះជាច្បាប់កំពូលនៃព្រះរាជាណាចក្រកម្ពុជា ។ ច្បាប់ និងសេចក្តីសំរេចទាំងឡាយនៃស្ថាប័ននានារបស់រដ្ឋ ត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត ។" មាត្រានេះ គូសបញ្ជាក់ពីតំរូវការចាំបាច់ និងជាក់លាក់ក្នុងការទាមទារឱ្យអនុវត្តតាមច្បាប់រដ្ឋធម្មនុញ្ញដែលមាន ដើម្បីនិរន្តរភាពក្នុងការអភិវឌ្ឍប្រទេសជាតិ ។

នៅពេលជាមួយគ្នានេះ ស្ថាប័ននីតិប្រតិបត្តិ ឬរាជរដ្ឋាភិបាល ដោយមានការចូលរួមពីបណ្តាអង្គការក្រៅរដ្ឋាភិបាល ឬសង្គមស៊ីវិល បានប្រឹងប្រែងអនុវត្តមាត្រាច្បាប់ ក៏ដូចជាគោរពសិទ្ធិមនុស្សជាហូរហែ ដោយយកចិត្តទុកដាក់ ដែលមានរូបភាពដូចជាការផ្សព្វផ្សាយច្បាប់ ឬចំណេះដឹងផ្សេងៗ តាមរយៈប្រព័ន្ធឃោសនា តាមរយៈការបណ្តុះបណ្តាលដោយផ្ទាល់ ឬការជំរុញការអនុវត្តច្បាប់ជាដើម ។ មានឧទាហរណ៍ ជាក់ស្តែងមួយអំពីការលើកកំពស់ការយល់ដឹងអំពីសិទ្ធិមនុស្ស គឺការប្រារព្ធពិធីបុណ្យជាតិ និងការរំលឹកទិវាអន្តរជាតិផ្សេងៗជាហូរហែយ៉ាងទៀងទាត់ និងជាបន្តបន្ទាប់នៅក្នុងឆ្នាំនីមួយៗ ។

ក្រៅពីពិធីបុណ្យជាតិនៃ ការប្រារព្ធពិធីចំរើនព្រះជន្មនៃព្រះមហាក្សត្រ ព្រះវររាជបិតា និងព្រះរាជវរមាតា

ពិធីរំលឹកខួបកំណើតនៃថ្នាក់ដឹកនាំរាជរដ្ឋាភិបាលនិងពីធីបុណ្យជាប្រពៃណីជាតិ មានការប្រារព្ធពិធីផ្សេងៗដែលមានអត្ថន័យជំរុញការគោរពសិទ្ធិមនុស្ស ដូចខាងក្រោមនេះ :

| | |
|---|---|
| ៧ មករា : ទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ | ៩ កក្កដា : រុក្ខទិវា |
| ៣១ មករា : ទិវាសុខភាពមាត់ធ្មេញ | ១២ សីហា : ទិវាអន្តរជាតិនៃយុវជន |
| ២៤ កុម្ភៈ : ទិវាសកម្មភាពកំចាត់មីន | ៨ កញ្ញា : ទិវាអក្ខរកម្មជាតិ និងអន្តរជាតិ |

---

[15] អនុសញ្ញាស្តីពីសិទ្ធិកុមារ ពាក់ព័ន្ធនឹងការលក់កុមារ ពេស្យាកម្មកុមារ និងកាមសាស្ត្រកុមារ សរសេរពីឆ្នាំ ២០០០ ចូលជាធរ មានជាសកលនៅឆ្នាំ ២០០២ ចូលជាធរមាន នៅ ប្រទេសកម្ពុជា ឆ្នាំ ២០០២ ។

[16] លក្ខន្តិកៈទី ក្រុងរ៉ូម ស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ សរសេរពីឆ្នាំ ១៩៩៨ ចូលជាធរមានជាសកលនៅ ឆ្នាំ ២០០២ ចូលជាធរមាន នៅ ប្រទេសកម្ពុជា ឆ្នាំ ២០០២ ។

| | |
|---|---|
| ៤ មីនា : ទិវានយោបាយទឹក | ៩ កញ្ញា : ទិវាពិភពលោកគ្មានថ្នាំជក់ |
| ៨ មីនា : ទិវាអន្តរជាតិនារី | ១៦ កញ្ញា : ទិវាអូសូនបរិស្ថានអន្តរជាតិ |
| ២២ មីនា : ទិវាអន្តរជាតិធនធានទឹក និងឧតុនិយម | ២១ កញ្ញា : ទិវាអន្តរជាតិនៃសន្តិភាព |
| ២៤ មីនា : ទិវាកំចាត់ជម្ងឺរបេង | ២៦ មិថុនា : ទិវាប្រឆាំងគ្រឿងញៀន |
| ៧ មេសា : ទិវាសុខភាពពិភពលោក | ១ កក្កដា : ទិវាមច្ឆាជាតិ |
| ៣០ មេសា : ទិវាចូលជាសមាជិកអាស៊ាន | ២៤ កញ្ញា : ទិវាប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ |
| ៣ ឧសភា : ទិវាសេរីភាពសារពត៌មាន | ១ តុលា : ទិវាមនុស្សចាស់ |
| ៨ ឧសភា : ទិវាកាកបាទក្រហម | ៥ តុលា : ទិវាគ្រូបង្រៀន |
| ១៥ ឧសភា : ទិវាអន្តរជាតិនៃគ្រួសារ | ២៣ តុលា : ទិវាសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីស |
| ៣១ ឧសភា : ទិវាពិភពលោកគ្មានថ្នាំជក់ | ១ ធ្នូ : ទិវាប្រឆាំងជម្ងឺអេដស៍ |
| ១ មិថុនា : ទិវាអន្តរជាតិកុមារ | ៣ ធ្នូ : ទិវាជនពិការពិភពលោក |
| ៥ មិថុនា : ទិវាបរិស្ថានជាតិ និងអន្តរជាតិ | ១០ ធ្នូ : ទិវាសិទ្ធិមនុស្ស |
| ១២ មិថុនា : ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ | ៤ ធ្នូ : ទិវាចូលរួមជាសមាជិកអង្គការសហប្រជាជាតិ |

ជាងនេះទៀត រដ្ឋាភិបាល តាមរយៈក្រសួងនានា បានធ្វើការសហការជាមួយអង្គការក្រៅរដ្ឋាភិបាល ចំនួនជាង ២០០០ ក្នុងការលើកកំពស់ការយល់ដឹងអំពីសិទ្ធិមនុស្ស ការលើកកំពស់ការគោរពច្បាប់ ក៏ដូចជាការបំពេញសកម្មភាពផ្សេងៗទៀតដើម្បីកសាងជាតិ ដែលជាការឆ្លុះបញ្ចាំងឱ្យឃើញពីការគោរពសិទ្ធិពលរដ្ឋ សិទ្ធិនយោបាយ សិទ្ធិសេដ្ឋកិច្ច វប្បធម៌ និងសង្គមកិច្ច ក្នុងប្រទេសកម្ពុជា។

### ៣. បរិបទអប់រំ

ដោយមានដំណើរស្របគ្នានឹងការអភិវឌ្ឍក្នុងបរិបទច្បាប់ ក៏មានការអភិវឌ្ឍក្នុងបរិបទអប់រំផងដែរ ក្នុងអំឡុងជាងពីរទសវត្សកន្លងទៅនេះ។

ពីឆ្នាំ ១៩៧៩ រហូតដល់ឆ្នាំ ២០០៨ ក្រសួងទទួលបន្ទុកវិស័យអប់រំនៅកម្ពុជា បានតស៊ូប្តូរផ្តាច់ក្នុងការងារកែលំអគុណភាពនៃការអប់រំ តាមរយៈ កំណែទំរង់ប្រព័ន្ធអប់រំ កំណែលំអកម្មវិធីសិក្សា សៀវភៅសិក្សា និងធ្វើទំនើបកម្មគោលវិធី

បង្រៀន និងរៀន ។

ជាក់ស្តែង រយៈពេលសិក្សានៃប្រព័ន្ធអប់រំសាធារណៈ ត្រូវបានកែប្រែចំនួន ៣ លើកកន្លងមកហើយ :

- ពីឆ្នាំ ១៩៧៩ ដល់ ១៩៨៦ ប្រព័ន្ធអប់រំមានរយៈពេល ១៣ឆ្នាំ ( ៤ឆ្នាំ នៅបឋមសិក្សា + ៣ឆ្នាំនៅមធ្យមសិក្សាបឋមភូមិ + ៣ឆ្នាំ នៅមធ្យមសិក្សាទុតិយភូមិ + ៣ឆ្នាំ នៅឧត្តមសិក្សា) ឬ ( ៤ +៣ +៣ + ៣) ។

- ពីឆ្នាំ ១៩៨៦ ដល់ ១៩៩៦ ប្រព័ន្ធអប់រំ មានរយៈពេល ១៥ឆ្នាំ គឺ ( ៥ + ៣ +៣ + ៤) ។

- ពីឆ្នាំ ១៩៩៦ រហូតដល់បច្ចុប្បន្ន ប្រព័ន្ធអប់រំមានរយៈពេល ១៦ឆ្នាំ គឺ ( ៦ + ៣ + ៣ + ៤) ។

ព្រមជាមួយគ្នានេះ គោលវិធីបង្រៀន និងរៀន បានប្រែក្លាយម្តងបន្តិចៗពីគោលវិធីគ្រូមជ្ឈមណ្ឌល ទៅគោលវិធីសិស្សមជ្ឈមណ្ឌល ។

## ប្រព័ន្ធសាលារៀន

ប្រព័ន្ធសាលារៀនបច្ចុប្បន្ននេះ មានសមាសភាពដូចខាងក្រោម :

**ក.** មត្តេយ្យសិក្សា ( មានរយៈពេល ៣ឆ្នាំ)

- កំរិតទាប ( សំរាប់កុមារអាយុ៣ឆ្នាំ)
- កំរិតមធ្យម ( សំរាប់កុមារអាយុ៤ឆ្នាំ)
- កំរិតខ្ពស់ ( សំរាប់កុមារអាយុ៥ឆ្នាំ)

**ខ.** ការអប់រំមូលដ្ឋាន( មានរយៈពេល៩ឆ្នាំ)

ការអប់រំមូលដ្ឋាន មានពីរដំណាក់ រួមមាន :

ខ.១ ដំណាក់បឋមសិក្សា មាន៦កំរិតថ្នាក់ :

- ថ្នាក់ទី១ ( សំរាប់កុមារអាយុ៦ឆ្នាំ)
- ថ្នាក់ទី២ ( សំរាប់កុមារអាយុ៧ឆ្នាំ)
- ថ្នាក់ទី៣ ( សំរាប់កុមារអាយុ៨ឆ្នាំ)
- ថ្នាក់ទី៤ ( សំរាប់កុមារអាយុ៩ឆ្នាំ)
- ថ្នាក់ទី៥ ( សំរាប់កុមារអាយុរ១០ឆ្នាំ)
- ថ្នាក់ទី៦ ( សំរាប់កុមារអាយុ១១ឆ្នាំ)

ខ.២ ដំណាក់មធ្យមសិក្សាបឋមសិក្សាភូមិ មាន៣កំរិតថ្នាក់ :

- ថ្នាក់ទី៧ ( សំរាប់កុមារអាយុ១២ឆ្នាំ)
- ថ្នាក់ទី៨ ( សំរាប់កុមារអាយុ១៣ឆ្នាំ)
- ថ្នាក់ទី៩ ( សំរាប់កុមារអាយុ១៤ឆ្នាំ) នឹងត្រូវប្រឡងថ្នាក់ជាតិ ដើម្បីឆ្លងចូលមធ្យមសិក្សាទុតិយភូមិ

គ. មធ្យមសិក្សាទុតិយភូមិ

នៅមធ្យមសិក្សាទុតិយភូមិ មាន៣កំរិតថ្នាក់ :

- ថ្នាក់ទី១០ (សំរាប់កុមារអាយុ១៥ឆ្នាំ)
- ថ្នាក់ទី១១ (សំរាប់កុមារអាយុ១៦ឆ្នាំ)
- ថ្នាក់ទី១២ (សំរាប់កុមារអាយុ១៧ឆ្នាំ) នឹងត្រូវប្រឡងថ្នាក់ជាតិ ដើម្បីឆ្លងចូលកំរិតឧត្តមសិក្សា។

ឃ. ឧត្តមសិក្សា

ការសិក្សានៅឧត្តមសិក្សា ត្រូវចំណាយពេលពី ៤ ទៅ៧ឆ្នាំ។

ប្រទេសកម្ពុជាមានសាលារៀន/គ្រឹះស្ថានអប់រំគ្រប់កំរិតផ្នែកសាធារណៈសរុបប្រមាណជាង ៨ពាន់ និងផ្នែកឯកជនរាប់រយ ដូចមានរៀបរាប់ខាងក្រោម:

- សាកលវិទ្យាល័យ និងវិទ្យាស្ថានជាតិចំនួន១៦ - សាកលវិទ្យាល័យនិងវិទ្យាស្ថានឯកជនប្រមាណ ២០ (តាមប័ណ្ណពត៌មានអាំងឌីកាទ័រអប់រំឆ្នាំ ២០០៥-២០០៦)
- សាលាមធ្យមសិក្សាទុតិយភូមិសាធារណៈចំនួន២៥២ - ឯកជនប្រមាណ ៣០ (តាមប័ណ្ណពត៌មានអាំងឌីកាទ័រអប់រំឆ្នាំ ២០០៥-២០០៦)
- សាលាមធ្យមសិក្សាបឋមភូមិសាធារណៈចំនួន៦៧០ - ឯកជនប្រមាណ ៣០ (តាមប័ណ្ណពត៌មានអាំងឌីកាទ័រអប់រំឆ្នាំ ២០០៥-២០០៦)
- សាលាបឋមសិក្សាសាធារណៈចំនួន៦.៤៧២ - ឯកជនប្រមាណ ៣០ (តាមរបាយការណ៍របស់នាយកដ្ឋានបឋមសិក្សា ឆ្នាំ ២០០៧-២០០៨)
- សាលាមត្តេយ្យសិក្សាចំនួន ១.៤២៩ - ឯកជនប្រមាណ ៤០ (តាមប័ណ្ណពត៌មានអាំងឌីកាទ័រអប់រំឆ្នាំ ២០០៥-២០០៦)។

## ដំណើរការនៃការអភិវឌ្ឍគោលនយោបាយ

ក្រសួងអប់រំ យុវជន និងកីឡាបានអភិវឌ្ឍ និងដាក់ស្នើសេចក្តីព្រាងច្បាប់ គោលនយោបាយ និងផែនការយុទ្ធសាស្រ្តជាច្រើន ដែលនៅក្នុងនោះមានសេចក្តីព្រាងខ្លះមានការពាក់ព័ន្ធយ៉ាងច្បាស់លាស់នឹងការអប់រំសិទ្ធិមនុស្ស។ ច្បាប់ គោលនយោបាយ និងផែនការយុទ្ធសាស្រ្តទាំងនោះ មានដូចជា:

- គោលនយោបាយសំរាប់អភិវឌ្ឍកម្មវិធីសិក្សា
- គោលនយោបាយសាលាកុមារមេត្រី
- គោលនយោបាយអប់រំកុមារពិការ
- ផែនការយុទ្ធសាស្រ្តអប់រំ
- គោលនយោបាយយេនឌ័រ
- គោលនយោបាយអប់រំសម្រាប់ទាំងអស់គ្នា
- គោលនយោបាយបច្ចេកវិទ្យាសារទូរគមនាគមន៍ពត៌មានក្នុងវិស័យអប់រំ

- គោលនយោបាយអប់រំក្រៅប្រព័ន្ធ
- ច្បាប់អប់រំ ។ល។

ច្បាប់ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រអប់រំទាំងនេះត្រូវបានអភិវឌ្ឍតាមលំនាំរួមមួយ ដោយត្រូវឆ្លងកាត់ការពិគ្រោះយោបល់ជាច្រើនដំណាក់ ជាមួយស្ថាប័ន និងភាគីអ្នកចូលរួមផ្សេងៗ។ ឧទាហរណ៍ ពង្រាងផែនការយុទ្ធសាស្ត្រអប់រំ ដែលបានអភិវឌ្ឍដោយគណៈកម្មការកណ្តាល បានឆ្លងកាត់ការពិគ្រោះយោបល់ជាមួយ :

- ការិយាល័យអប់រំ យុវជន និងកីឡា គ្រប់ខេត្ត-ក្រុង ( ត្រូវបានចាត់ទុកជាដៃគូនៅមូលដ្ឋាន)
- ស្ថាប័នពាក់ព័ន្ធទាំងអស់នៅកំរិតស្មើគ្នា ( ត្រូវបានចាត់ទុកដូចជាដៃគូពាក់ព័ន្ធផ្ទៃក្នុង)
- ក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាលពាក់ព័ន្ធទាំងអស់ ( ត្រូវបានចាត់ទុកជាអ្នកត្រួតពិនិត្យ)
- គណៈកម្មការឬ អង្គការ សមាគម ជាតិ និងអន្តរជាតិពាក់ព័ន្ធទាំងអស់ ( ត្រូវបានចាត់ទុកជាភាគីចូលរួម) ។

## II. ច្បាប់អប់រំ គោលនយោបាយ កម្មវិធីសិក្សា និងកម្មវិធីផ្សេងៗ

### ក. គោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សាចំណេះទូទៅ

គោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សាចំណេះទូទៅ( ថ្នាក់ទី ១-១២) ត្រូវបានរៀបចំឡើងពីឆ្នាំ ២០០៤ ដើម្បីកែលំអគុណភាព និង ប្រសិទ្ធិភាពនៃការងារអប់រំ ។ ការរៀបចំឱ្យមានគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សា គឺជាភារកិច្ចចាំបាច់ ដើម្បីផ្តល់ការណែនាំដល់ការអភិវឌ្ឍកម្មវិធីសិក្សា។ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំគោលនយោបាយនេះបាននៅដំណាក់កាលដែលប្រទេសកម្ពុជាកំពុងតែឈាន ទៅរកការរីកចំរើនលើគ្រប់វិស័យ ពិសេសវិស័យសេដ្ឋកិច្ច សង្គម និងវប្បធម៌ ។

គោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សាចំណេះទូទៅ មានខ្លឹមសារសមស្របនឹងផែនការ និងយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល រួមមានផែនការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជាលើកទី២, ផែនការយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ, ផែនការជាតិអប់រំសំរាប់ទាំងអស់គ្នា ឆ្នាំ២០០៣-២០១៥, ផែនការយុទ្ធសាស្ត្រវិស័យអប់រំកម្ម និងកម្មវិធីគាំទ្រវិស័យអប់រំ ជាដើម ។ល។

គោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សាចំណេះទូទៅ ឆ្លើយតបទៅនឹងតំរូវការនៃសកលនីយកម្ម តំបន់នីយកម្ម និងបុគ្គលនីយកម្ម។ គោលនយោបាយនេះ រួមចំណែកក្នុងការផ្តល់សមធមិក្នុងការទទួលការអប់រំនៅកំរិតអប់រំមូលដ្ឋាន, ពង្រីកភាពជាដៃគូរវាងរដ្ឋនិងឯកជន សំរាប់ការអប់រំប្រកបដោយគុណភាពខ្ពស់ នៅមធ្យមសិក្សា និងបង្កើនការទទួលខុសត្រូវក្នុងការអភិវឌ្ឍស្តង់ដានៅសាលារៀន ពកំរិត ( បឋមសិក្សា មធ្យមសិក្សាបឋមភូមិ មធ្យមសិក្សាទុតិយភូមិ) ។

គោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សាចំណេះទូទៅ មានរក្សាទុកនូវចំណុចគន្លឹះមួយចំនួនដែលមានក្នុងកម្មវិធី

សិក្សាគោលឆ្នាំ ១៩៩៦ បន្ទាប់ពីបានធ្វើការកែលំអ មានដូចជារបាយម៉ោងសិក្សា ការផ្តល់ការអប់រំបំនិនជីវិតក្នុងកម្មវិធីបំនិនជីវិតតាមមូលដ្ឋាន ការផ្តល់សិទ្ធិឱ្យសិស្សជ្រើសរើសមុខវិជ្ជាសិក្សានៅថ្នាក់ទី ១១និង១២ ដោយបន្ថែមម៉ោងសិក្សាសំរាប់មុខវិជ្ជានីមួយៗ ជាដើម ។ គួរកត់សម្គាល់ថា គោលនយោបាយនេះតំរូវអោយបន្ថយចំនួនមុខវិជ្ជាដែលសិស្សត្រូវរៀន ។

គោលនយោបាយនេះ ត្រូវបានគ្រោងទុកថានឹងអនុវត្តទូទាំងប្រទេសពីឆ្នាំសិក្សា ២០០៧-២០០៨ សំរាប់ថ្នាក់ទី ១ និងពីឆ្នាំសិក្សា ២០០៨ — ២០០៩ សំរប់ថ្នាក់ទី ៧ និងទី ១០ ។

## ខ. គោលនយោបាយសំរាប់ការអប់រំទាំងអស់គ្នា (គោលដៅចំនួន ៦ គិតដល់ឆ្នាំ ២០១៥)

គោលនយោបាយសំរាប់ការអប់រំទាំងអស់គ្នាត្រូវបានអនុម័ត និងបោះពុម្ពផ្សាយជាភាសាខ្មែរពីឆ្នាំ ២០០៥ ។ គោលនយោបាយនេះ មានចែងអំពីខ្លឹមសារសំខាន់ៗដូចខាងក្រោម :

- សាវតារ
- ការអភិវឌ្ឍនិងការគាំទ្រកុមារតូច
- ការអប់រំមូលដ្ឋានក្នុងប្រព័ន្ធសាលារៀន
- ការអប់រំបំណិនជីវិតក្នុងការអប់រំចំណេះទូទៅ និងការអប់រំក្រៅប្រព័ន្ធ
- អក្ខរកម្មមនុស្សចាស់
- ការលុបបំបាត់គំលាតយេនឌ័រក្នុងការអប់រំនៅបឋមសិក្សា និងមធ្យមសិក្សា
- កំណែទំរង់ និងកំណែលំអគុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅគ្រប់វិស័យ ។

គោលនយោបាយសម្រាប់ការអប់រំទាំងអស់គ្នានេះ កំពុងត្រូវបានអនុវត្ត ។

## គ. ផែនការយុទ្ធសាស្ត្រវិស័យអប់រំ

ក្នុងបណ្តាឯកសារជាច្រើនស្តីពីផែនការយុទ្ធសាស្ត្រវិស័យអប់រំដែលមានកន្លងមក យើងបានលើកយកតែឯកសារពីរប៉ុណ្ណោះដែលទើបបានអភិវឌ្ឍក្រោយគេថ្មីៗនេះ យកមកពិនិត្យ :

១. ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០០១ – ០៥ បានឆ្លុះអោយឃើញពីសកម្មភាពកែទំរង់វិស័យអប់រំ នៅកម្ពុជា បានបង្កអោយមានការរីកចំរើនគួរកត់សំគាល់ក្នុងការផ្តល់សមធមិក្នុងការចូលរៀន ការបង្កើនគុណភាពអប់រំ ការបង្កើតកម្មវិធីសិក្សាស្នូលជា កំណែទំរង់ការងារគ្រប់គ្រងក្នុងវិស័យអប់រំ ។ ទន្ទឹមនឹងនេះ ផែនការនេះក៏បានផ្តល់បទពិសោធយ៉ាងច្រើនដល់ផែនការយុទ្ធសាស្ត្រវិស័យអប់រំនៅទីបន្ទាប់ផងដែរ ។

២. ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០០៦ – ១០ ត្រូវបានរៀបចំឡើងដើម្បីកំណត់គោលនយោបាយ និងយុទ្ធសាស្ត្រជាអាទិភាពសំរាប់កំណែទំរង់ក្នុងរយៈពេល ៥ឆ្នាំ ។ ក្រសួងអប់រំ នៅតែរក្សាការផ្តល់អាទិភាពដល់ការផ្តល់សម

ធម៌ក្នុងការចូលរៀន និងការផ្តល់ការអប់រំមូលដ្ឋានប្រកបដោយគុណភាព ដែលជាគោលដៅ នៃយុទ្ធសាស្ត្រអប់រំសំរាប់ទាំងអស់គ្នា ក្នុងរយៈកាលនេះ ។

ផែនការនេះ កំពុងត្រូវបានអនុវត្តក្នុងភាពជាដៃគូជាមួយអ្នកចូលរួមនៃស្ថាប័នឯកជន អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍មាតាបិតាសិស្ស លើសកម្មភាពសំខាន់ៗដូចខាងក្រោមនេះ :

- ពង្រីកការងារអប់រំកុមារតូច
- ពង្រីកការងារអប់រំក្រៅប្រព័ន្ធ និងការបណ្តុះបណ្តាលវិជ្ជាជីវៈដល់យុវជន
- ការបង្កើនឱកាសចូលរៀននៅសាលាមធ្យមសិក្សា និងឧត្តមសិក្សា
- ធានាការលើកទឹកចិត្តដល់ការបង្កើនសមត្ថភាពដល់បណ្តាអ្នកអប់រំ
- ជំរុញការអនុវត្តច្បាប់អប់រំ អភិបាលកិច្ចល្អ និងការទទួលខុសត្រូវ ។

### ឃ. ច្បាប់អប់រំ

ច្បាប់អប់រំ ដែលបានផ្តល់សច្ចាប័ននៅថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០០៧ និងបានចូលជាធរមាននៅថ្ងៃទី ៨ ខែធ្នូ ឆ្នាំ ២០០៧ គឺជាឧបករណ៍ថ្មីមួយសម្រាប់ប្រើប្រាស់ជាមូលដ្ឋានក្នុងការពង្រឹងគុណភាពការងារអប់រំ ។

ខាងក្រោមនេះ ជាខ្លឹមសារដកស្រង់ពីមាត្រាមួយចំនួនដែលមានចែងពាក់ព័ន្ធយ៉ាងជិតស្និទ្ធនឹងការអប់រំសិទ្ធិមនុស្ស :

- ក្នុងជំពូក ៤ អំពី " បទបញ្ញត្តិទូទៅ" មាត្រា ៤ ចែងថា

" ការអប់រំក្នុងច្បាប់នេះ សំដៅដល់កិច្ចដំណើរ ការអភិវឌ្ឍការសិក្សា ឬការបណ្តុះបណ្តាលកាយសម្បទា សតិ បញ្ញា និងសីលធម៌ តាមរយៈគ្រប់សកម្មភាពអប់រំដែលធ្វើអោយអ្នកសិក្សាទទួលបានសំណុំចំណេះដឹង ជំនាញ សមត្ថភាព និងតំលៃដើម្បីអោយក្លាយខ្លួនជាបុគ្គលល្អដែលមានប្រយោជន៍សំរាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក ។ "

និយមន័យខាងលើនេះ បានបង្កឱកាសបើកទូលាយដល់ប្រភេទនៃការអប់រំសំខាន់ៗនានា ក្នុងនោះមានការអប់រំសិទ្ធិមនុស្ស ផងដែរ ។

ទោះជាយ៉ាងណាក្តី អ្នកអប់រំល្អគ្រប់រូបក្នុងពិភពលោក តែងផ្តល់ការលើកសរសើរដល់មនុស្សល្អ ជាបឋមទៅលើគុណសម្បត្តិរបស់អ្នកនោះក្នុងការគោរពសិទ្ធិមនុស្ស ។

- ក្នុងជំពូក ២ អំពី "ឧត្តមក្រុមប្រឹក្សាជាតិអប់រំ" មាត្រា ៥ ចែងថា

" ត្រូវបង្កើតឧត្តមក្រុមប្រឹក្សាជាតិអប់រំ ដែលមានភារកិច្ច :

- លើកសំណើគោលនយោបាយអប់រំ និងយុទ្ធសាស្ត្ររយៈពេលវែងសំដៅឆ្លើយតបទៅនឹងសំណូមពរអភិវឌ្ឍសង្គមសេដ្ឋកិច្ចរបស់ប្រទេសជាតិជូនរាជរដ្ឋាភិបាល ។

- វាយតំលៃការងារដែលពាក់ព័ន្ធនឹងវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈតាមកាលកំណត់ជូនរាជរដ្ឋាភិបាល ។
- កៀរគរគ្រប់ធនធាន ដើម្បីបម្រើបុព្វហេតុអប់រំ ។"

មាត្រានេះ បង្ហាញអោយឃើញពីសេចក្តីអំពាវនាវដ៏ទទូចដើម្បីអោយមានការចូលរួមវិភាគទានអំពីសំណាក់អ្នកចូលរួមពាក់ព័ន្ធទាំងអស់ ដើម្បីការរីកចំរើនក្នុងវិស័យអប់រំ ។ នេះគឺជាឆន្ទៈនៃការគោរពសិទ្ធិចូលរួមក្នុងវិស័យវប្បធម៌ ។

- ក្នុងជំពូក ៣ អំពី " រដ្ឋបាល និងការគ្រប់គ្រងអប់រំ " មាត្រា ១១ ចែងថា

" នីតិបុគ្គលសាធារណៈ នីតិបុគ្គលឯកជន និង/ឬរូបវន្តបុគ្គល មានសិទ្ធិស្នើបង្កើតគ្រឹះស្ថានសិក្សា ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវរៀបចំបទប្បញ្ញត្តិ និងគោលការណ៍ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានសិក្សា ទាំងសាធារណៈ ទាំងឯកជន តាមប្រភេទគ្រឹះស្ថានសិក្សា ។

ការបិទ ការរំលាយបញ្ចូលគ្នា ការបង្កើតជំនាញថ្មី ការបំបែក និងការប្រែក្លាយគ្រឹះស្ថានសិក្សា ត្រូវកំណត់ក្នុងលិខិតបទដ្ឋានដោយឡែក ។

គ្រប់គ្រឹះស្ថានសិក្សានិងថ្នាក់បណ្តុះបណ្តាលទាំងអស់ត្រូវមានអាជ្ញាប័ណ្ណអប់រំជាមុនទើបមានសិទ្ធិដំណើរការបាន ។ "

មាត្រាខាងលើនេះ ក៏បង្កឱកាសដល់ការចូលរួមតាមបំណង ពីសំណាក់បុគ្គលពេញសិទ្ធិខាងផ្លូវច្បាប់នានា ។

- ក្នុងជំពូកទី ៦ អំពី " ការកំណត់គោលនយោបាយ គោលការណ៍ ផែនការ និងយុទ្ធសាស្ត្រអប់រំ " មាត្រា ២៩ បានចែងពាក់ព័ន្ធដល់ភាពជាដៃគូក្នុងវិស័យអប់រំ ថា

" ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវកសាងផែនការគោលសម្រាប់អភិវឌ្ឍវិស័យអប់រំ អនុលោមតាមគោលនយោបាយអប់រំរបស់ឧត្តមក្រុមប្រឹក្សាជាតិអប់រំ និងត្រូវទទួលខុសត្រូវចំពោះការអភិវឌ្ឍ និងការត្រួតពិនិត្យកែសម្រួលគោលនយោបាយ គោលការណ៍ ផែនការ និងយុទ្ធសាស្ត្រអប់រំ ស្របទៅនឹងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល ។ "

មាត្រាដែលបានលើកឡើងខាងលើ ឆ្លុះបញ្ចាំងអោយឃើញពីចេតនាក្នុងការគោរពសិទ្ធិនយោបាយ សង្គម និងសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋគ្រប់រូប ។

- ជំពូកទី ៧ ទាំងមូល បានចែងអំពី សិទ្ធិ និងករណីយកិច្ចអប់រំ :

- សិទ្ធិទទួលការអប់រំ មានចែងក្នុងមាត្រា ៣១ ថា

" ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិទទួលបានការអប់រំយ៉ាងតិច៩ (ប្រាំបួន) ឆ្នាំ ប្រកបដោយគុណភាពដោយឥតបង់ថ្លៃនៅសាលារៀនសាធារណៈ ។ ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវរៀបចំគោលនយោបាយផែនការយុទ្ធសាស្ត្រ និងវិធានការជាជំហាន១ដើម្បីធានាឱ្យប្រជាពលរដ្ឋគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាពស្របតាមបទប្បញ្ញត្តិ ដែលមានចែងក្នុងច្បាប់នេះ ។ "

- សិទ្ធិមានសមភាពក្នុងការចូលរៀន មានចែងក្នុងមាត្រា ៣២ ថា

" ការចុះឈ្មោះចូលសិក្សានៅថ្នាក់ទី១ (មួយ) នៃកម្មវិធីអប់រំចំណេះទូទៅក្នុងប្រព័ន្ធត្រូវបានកំណត់ចំពោះកុមារដែលមានអាយុចាប់ពី៦ (ប្រាំមួយ) ឆ្នាំ ឬយ៉ាងទាបបំផុត៧០ (ចិតសិប) ខែឡើងទៅនៅថ្ងៃកំណត់ចូលសិក្សារបស់សាលារៀន។ "

- សិទ្ធិមានសេរីភាពក្នុងជំនឿ មានចែងក្នុងមាត្រា ៣៣ ថា

" រដ្ឋគោរពសិទ្ធិសេរីភាពខាងជំនឿសាសនា។

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវយកចិត្តទុកដាក់ចំពោះព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ។ គ្រប់ការបង្ខំឱ្យអ្នកសិក្សា និងអ្នកពាក់ព័ន្ធការអប់រំឱ្យចូលរួមក្នុងសកម្មភាពសាសនា និង/ឬការប្រតិបត្តិសាសនាណាមួយដែលជាផ្នែកនៃការអប់រំ ទោះដោយផ្ទាល់ ឬដោយប្រយោលក្តី ត្រូវហាមឃាត់។

ការសិក្សាអំពីសាសនានៅក្នុងកម្មវិធីសិក្សា ត្រូវបានអនុញ្ញាតសម្រាប់ការយល់ដឹងទូទៅប៉ុណ្ណោះ។ "

- សិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាព មានចែងក្នុងមាត្រា ៣៥ ថា

" សិទ្ធិរបស់អ្នកសិក្សាទាក់ទងនឹងការអប់រំមានដូចតទៅ :

- សិទ្ធិបញ្ចេញទស្សនៈសិក្សាដោយសេរី
- សិទ្ធិមានសេរីភាពខាងការសិក្សា
- សិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាព
- សិទ្ធិប្រមូលផ្តុំជាក្រុមអ្នកសិក្សា ឬក្លឹបអ្នកសិក្សាក្នុងគោលបំណងសម្រាប់ការអប់រំ
- សិទ្ធិពិនិត្យមើល និងចម្លងកំណត់ត្រាផ្ទាល់ខ្លួនស្តីពីការអប់រំ
- សិទ្ធិចូលរួមយ៉ាងសកម្ម និងពេញលេញនៅក្នុងការអភិវឌ្ឍស្តង់ដាអប់រំថ្នាក់គ្រឹះស្ថានសិក្សា និងថ្នាក់ជាតិដោយផ្ទាល់ ឬតាមរយៈតំណាងរបស់ខ្លួន
- សិទ្ធិទទួលបានការគោរព និងការយកចិត្តទុកដាក់ចំពោះសិទ្ធិមនុស្សជាពិសេសសិទ្ធិមានសេចក្តីថ្លៃថ្នូរ សិទ្ធិរួចផុតពីអំពើទារុណកម្ម ឬការដាក់ទណ្ឌកម្មលើរាងកាយ និងផ្នែកស្មារតី។"

- ក្នុងជំពូក ៨ អំពី " ប្រភពធនធានរបស់វិស័យអប់រំ " មាត្រា ៤៤ មានចែងពាក់ព័ន្ធដល់សិទ្ធិចូលរួមក្នុងការអភិវឌ្ឍវប្បធម៌ ថា

" រដ្ឋត្រូវជំរុញ និងផ្តល់ការលើកទឹកចិត្តចំពោះសប្បុរសជន តាមភាពសមស្រប និងចាំបាច់ដោយទទួលស្គាល់ការអប់រំជាការវិនិយោគមួយដ៏ល្អបំផុត។

បុគ្គល បព្វជិត គ្រួសារ សហគមន៍ អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នរដ្ឋ និងឯកជនទាំងអស់ មានសិទ្ធិចូលរួម និងផ្តល់ធនធានយ៉ាងពេញលេញ ទាំងធនធានមនុស្ស ទាំងសម្ភារៈ ឬថវិកាក្នុងគោលបំណងដើម្បីគាំទ្រ និងអភិវឌ្ឍវិស័យអប់រំ។

អ្នកគ្រប់គ្រងគ្រឹះស្ថានសិក្សា មានសិទ្ធិក្នុងការកៀរគរធនធានស្របច្បាប់នានាពីគ្រប់ប្រភព ដើម្បីអភិ

វឌ្ឍគ្រឹះស្ថានសិក្សា។ ការផ្ដល់ធនធានត្រូវធ្វើតាមការស័គ្រចិត្ត និងឥតលក្ខខណ្ឌ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវធានានូវតម្លាភាព និងការទទួលខុសត្រូវចំពោះការគ្រប់គ្រងប្រភព ធនធាននៃការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ការអប់រំ។ ”

មាត្រាខាងលើនេះ ដាក់កំហិតដល់ការធ្វើអោយសំរេចបាននូវសិទ្ធិរបស់ពលរដ្ឋគ្រប់រូប។

## ១. គោលនយោបាយសាលាកុមារមេត្រី

គោលនយោបាយសំរាប់សាលាកុមារមេត្រី បានទទួលការអនុម័ត និងចុះហត្ថលេខានៅថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ ២០០៧ បន្ទាប់ពីបានធ្វើការសាកល្បងដោយជោគជ័យអស់រយៈពេល ៧ឆ្នាំ ( ឆ្នាំ ១៩៩៣ ដល់ ២០០១) នៅតាមសាលារៀនគោលដៅ ដោយបានពង្រីកសកម្មភាពជាបន្តបន្ទាប់ រហូតបានដល់ ១០ ខេត្តក្រុង ធៀបនឹងខេត្តក្រុងទាំង ២៤ នៅទូទាំងប្រទេស។

គោលនយោបាយសាលាកុមារមេត្រី បានគ្របដណ្ដប់យ៉ាងទូលំទូលាយទៅគ្រប់សាលារៀននៅក៏រិតអប់រំមូលដ្ឋាន ទូទាំងប្រទេស។ មានន័យថា គោលនយោបាយនេះ ត្រូវបានរៀបចំឡើងដើម្បីធានា :

- ការអនុវត្តសិទ្ធិកុមារដែលជាសិទ្ធិមានការគាំទ្រជាសកល
- ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការងារអប់រំមូលដ្ឋាន
- ភាពជោគជ័យនៃវិមជ្ឈការនីយកម្ម
- ការប្ដេជ្ញាចិត្តរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការសំរេចអោយបានគោលដៅនៃការអភិវឌ្ឍសហស្សវត្សរ៍ គោលដៅនិងវត្ថុបំណងនៃផែនការជាតិសំរាប់អប់រំទាំងអស់គ្នា និងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។

គោលនយោបាយសាលាកុមារមេត្រីបានបង្ហាញអំពី :

- ខ្លឹមសារ, យុទ្ធសាស្ត្រ និងការអនុវត្តគោលការណ៍អប់រំមូលដ្ឋានប្រកបដោយប្រសិទ្ធភាព តាមរយៈសមាសភាព ៦ នៃកម្មវិធីសាលាកុមារមេត្រី គឺ :
  - សមធម៌ក្នុងការចូលរៀន
  - សមធម៌យេនឌ័រ
  - ប្រសិទ្ធភាពនៃការអប់រំ
  - ការចូលរួមរបស់កុមារ
  - ការការពារកុមារ
  - ការគាំទ្រថ្នាក់ជាតិ ។
- កត្តាសំខាន់ពីរយ៉ាង ក្នុងការអភិវឌ្ឍការអប់រំ :
  - ការធានាសមភាពក្នុងការអប់រំ។
  - ការអំពាវនាវរកការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធទាំងអស់។

តាមការពិត ក្រសួងអប់រំ យុវជន និងកីឡា បានអនុញ្ញាតអោយមានការអនុវត្តគំរោងសាលាកុមារមេត្រីតាំងពីឆ្នាំ ២០០២ ទៅតាមបទពិសោធផ្សេងៗរបស់អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិមួយចំនួន មានដូចជា :

- អង្គការយូនីសេហ្វ ដែលបានគាំទ្រគំរោងសាលារៀន ក្នុងខេត្តចំនួន ៦ គឺ ខេត្តកំពង់ធំ កំពង់ស្ពឺ ព្រៃវែង ស្វាយរៀង ស្ទឹងត្រែង និងឧត្តរមានជ័យ ។
- អង្គការណាវវ៉េសង្គ្រោះកុមារកម្ពុជា ដែលបានគាំទ្រគំរោងសាលារៀនក្នុងខេត្ត/ក្រុង ចំនួន ៧ គឺ ខេត្តសៀមរាប កំពង់ឆ្នាំង ពោធិសាត់ ព្រះវិហារ ឧត្តរមានជ័យ កំពង់ចាម និងភ្នំពេញ ។
- អង្គការសកម្មភាពសម្រាប់សាលាបឋមសិក្សានៅកម្ពុជាដែលបានគាំទ្រគំរោងសាលារៀនក្នុងខេត្តកំពង់ចាម ។

បន្ថែមលើនេះ ឯកសារផ្លូវការស្តីពី " កម្មវិធីសាលាកុមារមេត្រី " ត្រូវបានអនុម័តដាក់ជាគំរោងសកម្មភាពសំរាប់អនុវត្តនៅទូទាំងប្រទេស ពីថ្ងៃទី ២២ ខែសីហា ឆ្នាំ ២០០៥ ។

ការអនុវត្តកម្មវិធីសាលាកុមារមេត្រី បានជួយពង្រឹងបេសកកម្ម និងបង្កើនគុណភាពការអប់រំមូលដ្ឋាន ។ នៅឆ្នាំ ២០០៧ សាលាបង្គោលប្រមាណ ៣០ភាគរយនៅក្នុងបណ្តាគំរោងសាលាកុមារមេត្រី បានប្រែក្លាយជាអនុវិទ្យាល័យបានចំនួន ៨៤៨សាលា ហើយក្នុងចំនួននោះ មានអនុវិទ្យាល័យចំនួន ៣៧ ត្រូវបាន ជ្រើសរើសដើម្បីអនុវត្តសាកល្បងកម្មវិធីសាលាកុមារមេត្រី ។

## ច. គោលនយោបាយអប់រំកុមារពិការ

គោលនយោបាយអប់រំកុមារពិការត្រូវបានអភិវឌ្ឍជាសេចក្តីព្រាង នៅឆ្នាំ ២០០៨ ដោយមានការធានាយ៉ាងទូលំទូលាយអោយកុមារពិការទាំងអស់ បានទទួលការអប់រំប្រកបដោយសមធម៌ ជាមួយគ្នានឹងកុមារទៀត ដែលមានសុខភាពធម្មតា ។ គោលនយោបាយនេះ ទ្រទ្រង់គោលនយោបាយសាលាកុមារមេត្រី ។ ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំប្រឹងប្រែងអស់ពីកំលាំងកាយចិត្តក្នុងការអនុវត្តដោយពេញលេញនូវគោលនយោបាយនេះ ដើម្បីឈានទៅសម្រេច គោលដៅនៃផែនការយុទ្ធសាស្ត្រអប់រំ ក៏ដូចជាផែនការជាតិសម្រាប់អប់រំទាំងអស់គ្នា ។

## ឆ. កម្មវិធីសិក្សាស្តង់ដាសំរាប់អប់រំមូលដ្ឋាន

កម្មវិធីសិក្សាស្តង់ដា គឺជាលទ្ធផលសិក្សាដែលសិស្សអាចបង្ហាញបាននៅខាងចុងបញ្ចប់នៃដំណាក់កាលសិក្សាណាមួយ ។ កម្មវិធីសិក្សាស្តង់ដា សំរាប់ការអប់រំមូលដ្ឋាន ត្រូវបានអភិវឌ្ឍពីឆ្នាំ ២០០៦ និងបានផ្សព្វផ្សាយដល់សិស្សានុសិស្ស មាតាបិតាសិស្ស និងស្ថាប័នអប់រំទូទាំងប្រទេស សម្រាប់ជាលក្ខណៈវិនិច្ឆ័យវាស់ស្ទង់កំរិតលទ្ធផលសិក្សាដែលសិស្សសម្រេចបាន ។

## ជ. កម្មវិធីសិក្សា

សិទ្ធិមនុស្ស ត្រូវបានបង្រៀនក្នុងកម្មវិធីសិក្សាឆ្នាំ ១៩៨៦ ( កម្មវិធីអនុវត្តបច្ចុប្បន្ន) នៅតាមមុខវិជ្ជាពាក់ព័ន្ធមួយចំនួន មានមុខវិជ្ជាសិក្សាសង្គម និងភាសាខ្មែរ ជាពិសេសនៅមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា ពីកំរិតមត្តេយ្យសិក្សា រហូតដល់

ឧត្តមសិក្សា ដូចមានខ្លឹមសារដកស្រង់ខាងក្រោមនេះ :

- នៅមត្តេយ្យសិក្សា មានមេរៀនជាច្រើនបង្រៀនអំពី ការធ្វើអំពើល្អដោយមិនមានការរើសអើង ដោយមានរួមបញ្ចូលទាំងមេរៀនដែលមានចំណងជើងថា " ការពោលពាក្យ អរគុណ "" សុំទោស " " របៀបសំពះ " ជាដើម ។

- នៅបឋមសិក្សា មានមេរៀនជាច្រើនបង្រៀនអោយសិស្សបានយល់ដឹងស៊ីជម្រៅជាងមុន អំពីការអភិវឌ្ឍបុគ្គលិកលក្ខណៈ ពោលគឺ មានការសិក្សាក្នុងក្របខ័ណ្ឌការស្គាល់ខ្លួនឯង ទំនាក់ទំនងក្នុងក្រុមគ្រួសារ ទំនាក់ទំនងក្នុងសហគមន៍ជាដើម ។ ខាងក្រោមនេះ ជាចំណងជើងមេរៀនមួយចំនួន ដកស្រង់ពីកម្មវិធីសិក្សា និងសៀវភៅសិក្សាកីឡាបឋមសិក្សា :

- ការគោរពវិន័យសាលារៀន ( ឧទាហរណ៍ នៅសាលារៀន សិស្សមិនមានការអនុញ្ញាតអោយលេង ឬនាំយកមកនូវអាវុធជាតិផ្ទុះ ជាដើម)
- ការចៀសវាងអំពើទាំងឡាយណាដែលនាំទៅរកគ្រោះថ្នាក់
- ការធ្វើដំណើរប្រកបដោយសុវត្ថិភាពនៅតាមដងផ្លូវ
- ការទទួលស្គាល់កំហុសរបស់ខ្លួន
- ការសិក្សាអំពីគ្រោះថ្នាក់នៃអាវុធជាតិផ្ទុះ
- ការចៀសវាងល្បែងស៊ីសង
- ការសិក្សាអំពីខ្លឹមសារមាត្រាមួយចំនួនដែលមានចែងក្នុងសេចក្តីថ្លែងការណ៍សកលស្តីពីសិទ្ធិមនុស្ស
- ការសិក្សាអំពីសីល៥ ក្នុងព្រះពុទ្ធសាសនា

- នៅមធ្យមសិក្សា មានការបង្រៀនមេរៀនដើម្បីពង្រឹង និងពង្រីកបន្ថែម ចំណេះដឹង ឥរិយាបថ និងបំណិនដែលសិស្សទទួលបានពីបឋមសិក្សា ក្នុងក្របខ័ណ្ឌខ្លឹមសារទាក់ទងនឹង ការគ្រប់គ្រងខ្លួនឯង គ្រួសារ សហគមន៍មូលដ្ឋាន ជាតិ និងអន្តរជាតិ ។ ខាងក្រោមនេះជាឧទាហរណ៍នៃចំណងជើងមេរៀនដកស្រង់ពីកម្មវិធីសិក្សាបច្ចុប្បន្ន ( ឆ្នាំ ១៩៩៦) :

- ការស្គាល់ខ្លួនឯង
- ការថែរក្សាទំនាក់ទំនងល្អជាមួយអ្នកដទៃ
- ការបង្ការ ការគ្រប់គ្រង និងដំណោះស្រាយទំនាស់
- ការគោរពសិទ្ធិមនុស្ស
- ពិភពសន្តិភាពសំរាប់កុមារ

- ការគោរពច្បាប់ជាតិ
- អភិបាលកិច្ចល្អ
- ការបង្ការ និងការកាត់ទោសឧក្រិដ្ឋកម្ម
- ដំណោះស្រាយចំពោះឧបសគ្គដែលរាំងស្ទះដល់សន្តិភាព និងការអភិវឌ្ឍសហគមន៍
- លទ្ធិ និងគោលការណ៍ប្រជាធិបតេយ្យ
- ទស្សនៈអប់រំជាមូលដ្ឋាននៃសាសនាផ្សេងៗដែលមាននៅប្រទេសកម្ពុជា
- ការសិក្សាអំពីគោលនយោបាយក្រៅប្រទេសរបស់ព្រះរាជាណាចក្រកម្ពុជា
- ការសិក្សាអំពីសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ( អាស៊ាន) ។

បទពិសោធនៃការអប់រំសិទ្ធិមនុស្សនៅកម្ពុជា ត្រូវបានលើកបង្ហាញនៅក្នុង សិក្ខាសាលាវគ្គសំណេរស្តីពី" ការអភិវឌ្ឍ**ឯកសារណែនាំការបង្រៀនសិទ្ធិមនុស្សក្នុងសាលារៀននៅតំបន់អាស៊ីអាគ្នេយ៍** ( ហៅកាត់ថា SEA Wrteshop) ។ សិក្ខាសាលានោះ បានរៀបចំឡើងដើម្បីចាប់ផ្តើមបោះជំហានទៅសំរេចវត្ថុបំណងនៃ**ទសវត្សរ៍របស់អង្គការសហប្រជាជាតិដើម្បីការគោរពសិទ្ធិមនុស្ស ( ១៩៩៥ — ២០០៤)** ( ឬហៅកាត់ថា ទសវត្សរ៍នៃអង្គការសហប្រជាជាតិ) តាមរយៈការបោះពុម្ពផ្សាយឯកសារស្តីពី " **ឯកសារណែនាំការបង្រៀនសិទ្ធិមនុស្សក្នុងសាលារៀននៅតំបន់ អាស៊ីអាគ្នេយ៍** " ។ កិច្ចការទាំងនេះមានអត្ថន័យបញ្ជាក់ថា ទសវត្សរ៍នៃអង្គការសហប្រជាជាតិទ្រទ្រង់ការអភិវឌ្ឍឯកសារបង្រៀនសិទ្ធិមនុស្ស ។ បន្ថែមលើនេះ ទសវត្សរ៍នៃអង្គការសហប្រជាជាតិក៏បង្កើនផងដែរនូវកិច្ចសហការរវាងស្ថាប័ននានា ដែលជាមធ្យោបាយគន្លឹះក្នុងការអនុវត្តកម្មវិធីអប់រំសិទ្ធិមនុស្ស ។




ក្នុងដំណើរការរៀបចំចងក្រងឯកសារខាងលើនេះ មានការចូលរួមពីបុគ្គល និងស្ថាប័នជាច្រើននៅបណ្តាប្រទេសអាស៊ីអាគ្នេយ៍ ។ ឯកសារនេះ ផ្តល់គំនិតអំពីការរៀបចំក្របខ័ណ្ឌកម្មវិធីអប់រំសិទ្ធិមនុស្សក្នុងរយៈពេលច្រើនឆ្នាំ ក្នុងនោះការដៅយកចំណោទបញ្ហាផ្សេងៗ មកបង្ហាញដំណោះស្រាយ ជាសេចក្តីសំរេចរបស់អ្នកអភិវឌ្ឍកម្មវិធីសិក្សា ដែលបានមកចូលរួម ។

គំរោងកម្មវិធីអប់រំសិទ្ធិមនុស្ស បញ្ញត្តិសិទ្ធិមនុស្ស និងគុណតម្លៃ ដែលមានបញ្ចូលក្នុងកម្មវិធីសិក្សាឆ្នាំ ១៩៩៦ ត្រូវបានលើកបង្ហាញតាមកំរិតថ្នាក់នីមួយៗ នៅត្រង់ទំព័រទី ១៥ នៃឯកសារនេះ ។ ឯកសារនេះ បានប្រែជាភាសាខ្មែរ និង

បានចែកផ្សាយក្នុងប្រទេសកម្ពុជា។

## ប្រទេសកម្ពុជា

| កំរិតថ្នាក់ | គ្របដណ្តប់កម្មវិធីសិក្សាសិទ្ធិមនុ | ចំណោទបញ្ហា | បញ្ញត្តិសិទ្ធិមនុស្ស | គុណតំលៃសំខាន់ៗ |
|---|---|---|---|---|
| ៧ | ខ្លួនឯង | • បញ្ញត្តិនៃការអភិវឌ្ឍ<br>• សិទ្ធិ និងការគោរពអ្នក ដទៃ<br>• ការរំលោភសិទ្ធិមនុស្ស<br>• ការគ្រប់គ្រងចំណោទបញ្ហា | • សិទ្ធិកុមារ<br>• សិទ្ធិទទួលការអប់រំ<br>• សិទ្ធិដើម្បីអភិវឌ្ឍខ្លួន<br>• សិទ្ធិដើម្បីភាពឯកជន | • សមភាព<br>• ការស្រឡាញ់សាលារៀន<br>• ការទុកចិត្តលើខ្លួនឯង<br>• ការគោរពខ្លួនឯង |
| ៨ | អ្នកដទៃ | • ទំនាក់ទំនងរវាងប្រជាពលរដ្ឋ<br>• ការរើសអើង<br>• អាកប្បកិរិយាសីលធម៌<br>• ការចូលរួម និងថែរក្សា | • ភាពគ្មានការរើសអើង<br>• សមភាព<br>• សិទ្ធិរួចផុតពីការរើសអើង<br>• ការប្រព្រឹត្តក្នុងភាពជាបងប្អូន<br>• សិទ្ធិដើម្បីសន្តិសុខសង្គម<br>• សមភាពភេទ | • មនុស្សធម៌<br>• សេចក្តីគួរសម<br>• សុជីវធម៌<br>• ភាពស្និទ្ធស្នាល<br>• សប្បុរសធម៌<br>• ការចូលរួម |
| ៩ | សហគមន៍ | • សិទ្ធិ និងទំនួលខុសត្រូវ<br>• ការអភិវឌ្ឍ<br>• បរិស្ថាន<br>• ការគោរពច្បាប់ | • សិទ្ធិចូលរួម<br>• សិទ្ធិខាងសង្គម<br>• សិទ្ធិខាងសេដ្ឋកិច្ច<br>• ការសំរេចចិត្តត្រឹមត្រូវ | • ការចូលរួម<br>• ការច្នៃប្រឌិត<br>• ការទទួលខុសត្រូវ<br>• ការគោរពច្បាប់ |
| ១០ | ប្រទេស | • ភាពក្រីក្រ<br>• អសន្តិសុខ<br>• សិទ្ធិ និងទំនួលខុសត្រូវចំពោះសង្គមជាតិ<br>• សាមគ្គីភាព | • សិទ្ធិខាងសង្គម<br>• សិទ្ធិពលរដ្ឋ<br>• សិទ្ធិនយោបាយ | • សេចក្តីស្នេហាជាតិ<br>• កិច្ចសហប្រតិបត្តិការ<br>• ការទទួលខុសត្រូវ<br>• ការគោរពច្បាប់ |
| ១១ | ប្រទេស | • វប្បធម៌ និងសិទ្ធិមនុស្ស<br>• ការធ្វើឱ្យជាសះស្បើយឡើងវិញជម្ងឺផ្លូវចិត្តរបស់ជនរង | • សិទ្ធិមានសេរីភាពសាសនា<br>• សេរីភាពក្នុងការនិយាយស្តី<br>• ភាពស្មើគ្នាចំពោះមុខច្បាប់ | • មនសិការ<br>• ភាពស្មោះត្រង់<br>• ទំនួលខុសត្រូវ |
| | | គ្រោះដោយការរំលោភសិទ្ធិមនុស្ស | • និងការការពារច្បាប់ | • សណ្តាប់ធ្នាប់ |

| ១២ | តំបន់ និង ពិភពលោក | • តំបន់ភាវូបនីយកម្ម<br>• ពិភពលោក | សិទ្ធិមានសណ្តាប់ធ្នាប់សង្គម និងអន្តរជាតិត្រឹមត្រូវ<br>• ករណីយកិច្ចចំពោះសហគមន៍ និងការកំរិតសិទ្ធិ<br>• អំពើប្រឆាំងនឹងសិទ្ធិណាមួយ ដែលមានចែងក្នុងសេចក្តីថ្លែងការណ៍សកល គឺ មិនមែនជាសិទ្ធិទេ | • ទំនួលខុសត្រូវ<br>• ធ្វើចិត្តឱ្យទូលាយ<br>• កិច្ចសហប្រតិបត្តិ ការ<br>• ការគោរព និងស្រឡាញ់ចំពោះពលករ |
|---|---|---|---|---|

តារាង: គំរោងកម្មវិធីសិក្សាសិទ្ធិមនុស្សរបស់ប្រទេសកម្ពុជា( អភិវឌ្ឍក្នុងឆ្នាំ១៩៩៦) បានលើកឡើងនៅក្នុងឯកសារណែនាំការបង្រៀនសិទ្ធិមនុស្សសំរាប់សាលានៅអាស៊ីអាគ្នេយ៍

ដោយពិនិត្យលើកម្មវិធីសិក្សាថ្មី អនុវត្តពីឆ្នាំ ២០០៨-២០០៩ តទៅ បញ្ញត្តិសិទ្ធិមនុស្សដែលមានបញ្ច្រាបក្នុងមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា តាមថ្នាក់នីមួយៗ ឃើញមានដូចខាងក្រោម:

| លរ | កំរិតថ្នាក់ | បញ្ញត្តិសិទ្ធិមនុស្ស /ការអនុវត្តសិទ្ធិមនុស្ស | ចំនួនម៉ោងសិក្សា | ម៉ោងសិក្សាសរុបក្នុង ឆ្នាំសិក្សា ( គ្រប់មុខវិជ្ជា) | ភាគរយនៃម៉ោងសិក្សាសរុបក្នុងឆ្នាំសិក្សា |
|---|---|---|---|---|---|
| កំរិតបឋមសិក្សា | | | | | |
| ១ | ថ្នាក់ទី១ | សិទ្ធិកុមារ:<br>សិទ្ធិទទួលការការពារ | ១៤ | ៩៥០ | ១.៤៩ % |
| ២ | ថ្នាក់ទី២ | សិទ្ធិកុមារ:<br>- សិទ្ធិទទួលការការពារ<br>- សិទ្ធិទទួលការអប់រំ<br>- សិទ្ធិមានការអភិវឌ្ឍ | ២៤ | ៩៥០ | ២.៥២ % |
| ៣ | ថ្នាក់ទី៣ | សិទ្ធិកុមារ:<br>- សិទ្ធិទទួលការការពារ<br>- សិទ្ធិទទួលការអប់រំ<br>- សិទ្ធិមានការអភិវឌ្ឍ | ៨ | ៩៥០ | ០.៨២ % |
| ៤ | ថ្នាក់ទី៤ | សិទ្ធិកុមារ:<br>- សិទ្ធិទទួលការការពារ<br>- សិទ្ធិទទួលការអប់រំ<br>- សិទ្ធិមានការអភិវឌ្ឍ<br>- សិទ្ធិចូលរួម | ១២ | ៩៥០ | ១.២៦ % |
| ៥ | ថ្នាក់ទី៥ | សិទ្ធិកុមារ:<br>- សិទ្ធិទទួលការការពារ | | | |

| | | | | | |
|---|---|---|---|---|---|
| | | - សិទ្ធិទទួលការអប់រំ<br>- សិទ្ធិមានការអភិវឌ្ឍ<br>- សិទ្ធិចូលរួម | ២២ | ៩៥០ | ២.៣១ % |
| ៦ | ថ្នាក់ទី៦ | សិទ្ធិកុមារៈ<br>- សិទ្ធិទទួលការការពារ<br>- សិទ្ធិទទួលការអប់រំ<br>- សិទ្ធិមានការអភិវឌ្ឍ<br>- សិទ្ធិចូលរួម | ២៣ | ៩៥០ | ២.៤២ % |
| កំរិតមធ្យមសិក្សាបឋមភូមិ | | | | | |
| ៧ | ថ្នាក់ទី៧ | សិទ្ធិកុមារៈ<br>- សិទ្ធិទទួលការការពារ<br>- សិទ្ធិទទួលការអប់រំ<br>- សិទ្ធិមានការអភិវឌ្ឍ<br>- សិទ្ធិចូលរួម<br>- សិទ្ធិក្នុងជំនឿ<br>- សិទ្ធិគ្មានការរើសអើង | ៤១ | ១១៤០ | ៣.៥៩ % |
| ៨ | ថ្នាក់ទី៨ | សិទ្ធិកុមារៈ<br>- សិទ្ធិចូលរួម<br>- សិទ្ធិក្នុងជំនឿ<br>- សិទ្ធិគ្មានការរើសអើង | ៤៣ | ១១៤០ | ៣.៧៧ % |
| ៩ | ថ្នាក់ទី៩ | សិទ្ធិកុមារៈ<br>- សិទ្ធិចូលរួម<br>- សិទ្ធិក្នុងជំនឿ<br>- សិទ្ធិគ្មានការរើសអើង<br>- សេរីភាពក្នុងការបង្កើតសមាគម | ៣៤ | ១១៤០ | ២.៩៨ % |
| កំរិតមធ្យមសិក្សាទុតិយភូមិ | | | | | |
| ១០ | ថ្នាក់ទី១០ | - សិទ្ធិសេរីភាពក្នុងការសំដែងមតិ<br>- សិទ្ធិទទួលការការពារដោយច្បាប់ | ៨ | ១១៤០ | ០.៧០ % |
| ១១ | ថ្នាក់ទី១១ | - អនុស.អន្តរ.ស្តីពីសិទ្ធិពល.និងសិទ្ធិនយោបាយ<br>- អនុស.អន្តរ.ស្តីពីសិទ្ធិសេដ្ឋ.សង្គមនិងវប្បធម៌ | ៨ | ១២៦០ | ០.៦៣ % |

| | | | | | |
|---|---|---|---|---|---|
| ១២ | ថ្នាក់ទី១២ | - សេចក្តីថ្លែងការណ៍សកលស្តីពីសិទ្ធិមនុស្ស<br>- អនុស.អន្តរ.ស្តីពីសិទ្ធិពល.និងសិទ្ធិនយោបាយ<br>- អនុស.អន្តរ.ស្តីពីសិទ្ធិសេដ្ឋ.សង្គមនិងវប្បធម៌ | ២៨ | ១២៦០ | ២.២២ % |
| ការអប់រំនៅឧត្តមសិក្សា | | | | | |
| | | មានបញ្ញត្តិមួយចំនួន | | | |

គោលគំនិតអប់រំសិទ្ធិមនុស្សទាំងអស់ដែលបានបញ្ជ្រាបក្នុងកម្មវិធីសិក្សាឆ្នាំ២០០៩ សុទ្ធសឹងផ្អែកលើមូលដ្ឋានច្បាប់រដ្ឋធម្មនុញ្ញ សេចក្តីថ្លែងការណ៍សកលស្តីពីសិទ្ធិមនុស្ស និងអនុសញ្ញា-កតិកាសញ្ញាអន្តរជាតិនានា ដែលប្រមុខរាជរដ្ឋាភិបាលប្រទេសកម្ពុជាបានចុះសច្ចាប័នទទួលយកមកអនុវត្ត។

## សិទ្ធិចូលរួមក្នុងវិស័យអប់រំ

កម្មវិធីគាំទ្រវិស័យអប់រំ ២០០៦-២០១០ ត្រូវបានបង្កើតឡើង ដើម្បីដាក់អោយអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រទាំងឡាយដែលបានលើកឡើងក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០០៦-២០១០ ។ កម្មវិធីគាំទ្រវិស័យអប់រំកំណត់កម្មវិធីសកម្មភាពចាំបាច់ និងជាអាទិភាព ដើម្បីសំរេចគោលដៅអភិវឌ្ឍសហសវត្សរ៍ និងគោលដៅនៃផែនការអប់រំសំរាប់ទាំងអស់គ្នា។ ដើម្បីសំរេចបានដូចនេះ សេចក្តីដកស្រង់ពីអារម្ភកថានៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០០៦-២០១០ ថា:

" ក្រសួងអយកទទួលស្គាល់ថា ដំណើរកែទំរង់វិស័យអប់រំស្ថិតនៅវែងឆ្ងាយនៅឡើយ ដែលទាមទារអោយបង្កើនល្បឿនថែមទៀត។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៦ - ២០១០ ត្រូវបានរៀបរៀងឡើងដើម្បីកំណត់គោលនយោបាយអប់រំ និងយុទ្ធសាស្ត្រជាអាទិភាពលើការចូលរៀនប្រកបដោយសមធម៌ និងមានគុណភាពខ្ពស់នៅកំរិតអប់រំមូលដ្ឋានដែលជាគោលដៅ និងយុទ្ធសាស្ត្ររបស់ផែនការជាតិសម្រាប់អប់រំទាំងអស់គ្នា។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០៦-២០១០ក៏បានផ្តោតការយកចិត្តទុកដាក់ខ្ពស់ផងដែរលើការពង្រីកការអប់រំកុមារតូច ការពង្រីកការងារអប់រំក្រៅប្រព័ន្ធ និងការបណ្តុះបណ្តាលជំនាញដល់យុវជន ការពង្រីកកាលានុវត្តភាពទទួលការអប់រំមធ្យមសិក្សាទុតិយភូមិនិងក្រោយមធ្យមសិក្សា តាមរយៈការកសាងភាពជាដៃគូអោយបានល្អរវាងរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ផ្នែកឯកជន អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍មាតាបិតាសិស្ស។..."

សេចក្តីដកស្រង់ខាងលើនេះ បញ្ជាក់អំពីឆន្ទៈបើកចំហរចំពោះការគោរពដោយពិតប្រាកដសិទ្ធិចូលរួមរបស់ប្រជាពលរដ្ឋ។

រួមសេចក្តីមក បច្ចុប្បន្ននេះ ក្រសួងអប់រំ យុវជន និងកីឡាមានឯកសារគតិយុត្តសំខាន់ៗនិងគ្រប់គ្រាន់ក្នុងការគាំ

ទ្រការអប់រំសិទ្ធិមនុស្ស។ ប៉ុន្តែ ទោះជាច្បាប់អប់រំ គោលនយោបាយ និងកម្មវិធីសិក្សាមានមកជាហូរហែដូចបានលើកបង្ហាញកន្លងមកយ៉ាងណាក៏ដោយ ក៏ឧបករណ៍ទាំងនោះមិនបានគ្របដណ្តប់ទាំងស្រុងលើការអប់រំរាល់បញ្ញត្តិសិទ្ធិមនុស្សដែលសង្គមត្រូវការនៅឡើយ ដោយហេតុថា ឧបករណ៍ដែលមានត្រូវបានរៀបចំឡើងដើម្បីគ្រាន់នឹងសំរេចវត្ថុបំណងជាក់លាក់មួយចំនួនប៉ុណ្ណោះ ឧទាហរណ៍ សិទ្ធិចូលសិក្សារៀនសូត្រ សិទ្ធិមានសមភាពក្នុងការទទួលការអប់រំ សិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាព សិទ្ធិរួចផុតពីការរើសអើង សិទ្ធិសេរីភាពក្នុងការសំដែងមតិ សិទ្ធិបង្កើតក្រុមឬសមាគមជាដើម ។ល ។

## ការប្រតិបត្តិបានប្រសើរក្នុងការអប់រំសិទ្ធិមនុស្សក្នុងប្រព័ន្ធសាលារៀន

ជាទូទៅ កន្លងមក មានការប្រតិបត្តិបានប្រសើរនៅក្នុងការអប់រំសិទ្ធិមនុស្សក្នុងប្រព័ន្ធសាលារៀន ដូចមានខាងក្រោមនេះ:

- ការលើកកំពស់ការយល់ដឹងអំពីសិទ្ធិមនុស្ស ត្រូវបានបញ្ជ្រាបក្នុងម៉ោងសិក្សារៀន និងបង្រៀនមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា ក្នុងថ្នាក់ ក្រៅថ្នាក់ និងសកម្មភាពពិសេស នៅគ្រប់កំរិតថ្នាក់ក្នុងការអប់រំចំណេះទូទៅ ។ ជាទូទៅ មេរៀននីមួយៗត្រូវបានបង្រៀនតាមលំនាំសកម្មភាព៤ ( សកម្មភាពផ្តើម, សកម្មភាពវិភាគ, សកម្មភាពអរូបីកម្ម និងសកម្មភាពប្រតិបត្តិ) ។ នៅក្នុងលំនាំនៃការបង្រៀននិងរៀននោះ គ្រូបង្រៀនតែងសួរថា " តើកុមារមានសិទ្ធិធ្វើកិច្ចការនេះ ឬធ្វើកិច្ចការនោះឬទេ ? តើមនុស្សធំមានសិទ្ធិធ្វើកិច្ចការនេះ ឬកិច្ចការនោះឬទេ ? "



រូបថតផ្តល់ដោយសាលាគរុកោសល្យខេត្តកណ្តាល : សកម្មភាពច្នៃប្រឌិតរបស់សិស្សក្នុងការបង្កើតផ្ទាំងរូបភាព

- មានការវាស់ស្ទង់កំរិតយល់ដឹងរបស់សិស្សអំពីសិទ្ធិមនុស្ស តាមរយៈសំណួរតែសប្រចាំមេរៀន ប្រចាំខែ ប្រចាំត្រីមាស និងតាមរយៈការប្រឡងឆមាស ។

- មានការអនុវត្តកម្មវិធីលើកកំពស់ការយល់ដឹង និងការពារកុមារពីការប្រើប្រាស់គ្រឿងញៀន ពលកម្មកុមារ ការជួញដូរកុមារ ការរងគ្រោះដោយគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ។ នៅក្នុងការអនុវត្តកម្មវិធី កុមារបានរៀនមេរៀនពាក់ព័ន្ធនឹង " ការរក្សាជីវិតគឺជាសិទ្ធិមនុស្ស " ។

- មានការអនុវត្តកម្មវិធីសាលាកុមារមេត្រីនៅខេត្តមួយចំនួន ហើយការអនុវត្តនេះកំពុងមានការពង្រីកទូទាំងប្រទេស ។ ក្នុងការអនុវត្តកម្មវិធីនៅសាលារៀន កុមារបានទទួលការបង្រៀនអោយយល់ដឹងថាពួកគេកំពុងទទួលការធានាសមភាពក្នុងការចូលរៀន កំពុងស្ថិតនៅក្នុងបរិយាកាសអប់រំល្អប្រកបដោយសាមគ្គីភាព សេរីភាព សមភាព សមធម៌ សុខុមាលភាពផ្លូវកាយ ចិត្ត និងបញ្ញាស្មារតី ។

ប៉ុន្តែ ការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌលក្នុងម៉ោងសិក្សា នៅមានចំនុចខ្វះខាត ដោយមូលហេតុមួយចំនួន មានដូចជាសម្ភារៈសិក្សាមិនគ្រប់គ្រាន់ បន្ទប់រៀននៅសាលារៀនមួយចំនួនមានសិស្សច្រើនពេក ជីវភាពគ្រូបង្រៀនមានភាពទន់ខ្សោយ សិស្សានុសិស្សនិងមាតាបិតាសិស្សភាគច្រើនស្ថិតក្នុងជីវភាពក្រីក្រ ។ ល ។

ក្នុងការប្រមើលទៅរកការសំរេចគោលដៅនៃការអប់រំសិទ្ធិមនុស្ស គឺមិនមានឃើញជាពន្លឺទេ ប្រសិនបើមិនមានការអប់រំលើកកំពស់ការយល់ដឹងអំពីសិទ្ធិមនុស្ស ហើយនិងឆន្ទៈប្តូរផ្តាច់របស់អ្នកអប់រំ និងដៃគូពាក់ព័ន្ធនានា ។ ដូចនេះ ការអប់រំសិទ្ធិមនុស្ស ដល់ប្រជាពលរដ្ឋពេញវ័យគ្រប់រូប មិននិយាយត្រឹមការអប់រំសិទ្ធិមនុស្សដល់កុមារទេ គួរចាត់ទុកជាវិស័យអាទិភាព ។

**ការអនុវត្តគោលនយោបាយ**

ចាប់តាំងពីពេលដែលរដ្ឋាភិបាលថ្មីត្រូវបានបង្កើតឡើង ក្រោយកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ប្រទេសកម្ពុជាបានប្រែក្លាយជាអ្នកទទួលភារៈគាំទ្រសកម្មភាពសិទ្ធិមនុស្សរបស់អង្គការអន្តរជាតិ ( តាមរយៈភ្នាក់ងារ ការិយាល័យ អង្គការ និងកម្មវិធីរបស់អង្គការអន្តរជាតិទាំងនោះ) អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងបរទេស ។

អង្គការក្រៅរដ្ឋាភិបាលមួយចំនួនបាននាំមុខគេ ក្នុងការអនុវត្តកម្មវិធីអប់រំសិទ្ធិមនុស្សក្នុងសាលារៀន ។ អង្គការសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស ( ហៅ លីកាដូ) បានចាប់ផ្តើមអនុវត្តកម្មវិធីរបស់ខ្លួន ចាប់តាំងពីឆ្នាំ ១៩៩២ ។ វត្ថុបំណងចំបងរបស់កម្មវិធី គឺការលើកកំពស់ការយល់ដឹងអំពីសិទ្ធិមនុស្ស និងប្រជាធិបតេយ្យដល់ពលរដ្ឋគ្រប់លំដាប់ថ្នាក់ក្នុងសង្គម តាមរយៈការបណ្តុះបណ្តាលជាក្រុម និងការចែកចាយពត៌មាន ។ អង្គការនេះបានបង្កើតការិយាល័យនៅតាមខេត្ត ដែលមានបុគ្គលិកអប់រំដែលអនុវត្តកម្មវិធីនៅលំដាប់ថ្នាក់ខេត្ត ។ ការិយាល័យនៅខេត្តបានផលិតឯកសារពត៌មានស្តីពីសិទ្ធិមនុស្ស ។ អង្គការលីកាដូ បានពង្រីកកម្មវិធីរបស់ខ្លួន នៅក្រោយការបោះឆ្នោតខែឧសភា ឆ្នាំ ១៩៩៣ ដោយប្រើប្រាស់ឯកសាររបស់អាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា ( ហៅកាត់ថា អ៊ុនតាក់) សំរាប់ " ពលរដ្ឋទូទៅរួមទាំងសិស្ស " ប៉ុន្តែមិនមានការរៀបចំត្រឹមត្រូវជាកម្មវិធីសិក្សាតំរូវទៅ តាមលក្ខណៈដោយឡែករបស់ក្រុមគោលដៅជាក់លាក់ ដូចជាសិស្សសាលាជាដើម នោះទេ ។

អង្គការក្រៅរដ្ឋាភិបាលមួយទៀត វិទ្យាស្ថានកម្ពុជាដើម្បីសិទ្ធិមនុស្ស បានធ្វើការងារបណ្តុះបណ្តាលសិទ្ធិមនុស្សដល់ជូរគ្រូបង្រៀន ។ អង្គការនេះបានអនុវត្តគំរោង " វិធីបង្រៀនសិទ្ធិមនុស្ស " ដោយសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា អស់រយៈពេល ៣ឆ្នាំ ដែលមានកំណត់ហេតុដូចខាងក្រោមនេះ :

កម្មវិធីបានអភិវឌ្ឍឡើងជាច្រើនដំណាក់ ។ នៅលើកដំបូង មានការជួបប្រជុំដោយផ្ទាល់ជាមួយឯកឧត្តមរដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីស្នើសុំការឯកភាពលើការសរសេរកម្មវិធីសិក្សាគ្រប់ថ្នាក់ ។ អង្គការបានបញ្ជាក់ដល់ឯកឧត្តមរដ្ឋមន្ត្រីថា គំរោងនេះជាគំរោងរបស់លោក ហើយជោគជ័យរបស់គំរោងនេះ គឺជាជោគជ័យរបស់ក្រសួងអប់រំ យុវជន និងកីឡា ។ ក្រសួងក៏បានយកចិត្តទុកដាក់ ដើម្បីធានាអោយមានការគាំទ្រពីសំណាក់មន្ត្រីដឹកនាំជាន់ខ្ពស់ដទៃទៀត ដោយរួមទាំងនាយករដ្ឋមន្ត្រីទាំងពីររូបផង តាមរយៈការស្នើសុំអោយលោកបន្តចូលរួមសកម្មភាពក្រោយៗ មកទៀត ដូចជាពីធីចែកវិញ្ញាបនប័ត្រជាដើម ។

អ្នកសរសេរកម្មវិធីសិក្សារបស់ក្រសួងអប់រំយុវជន និងកីឡា ក្រោយកិច្ចសហការជាមួយបុគ្គលិកវិទ្យាស្ថានកម្ពុជាដើម្បីសិទ្ធិមនុស្ស បានធ្វើសេចក្តីព្រាងកម្មវិធីសិក្សាមួយចប់ ដោយគ្របដណ្តប់ ១១កំរិតថ្នាក់ ពីបឋមសិក្សា រហូតដល់មធ្យមសិក្សា ។ ជាការចាប់ផ្តើម មានការបើកសិក្ខាសាលាបង្ហាញមួយដើម្បីជួយដល់មន្ត្រីក្រសួងអប់រំក្នុងការបង្កើនចំណេះដឹងអំពីសិទ្ធិមនុស្ស និងដឹកនាំការងារ ។ សមាជិកមួយចំនួននៃអង្គការក្រៅរដ្ឋាភិបាល ក្រុមស្រ្តី សិស្សនិស្សិត .ល. បានទទួលការអញ្ជើញមកចូលរួមក្នុងសិក្ខាសាលា ។ ជាលទ្ធផលចុងក្រោយ សៀវភៅគ្រូចំនួន ៦មុខសំរាប់គ្រប់កំរិតសិក្សា ត្រូវបានផលិត ។ នៅកំរិតសិក្សានីមួយៗ មានសៀវភៅពីរប្រភេទ គឺប្រភេទកម្មវិធីសកម្ម ( សិទ្ធិមនុស្សត្រូវបានបង្រៀនដាច់ដោយឡែក) និងប្រភេទកម្មវិធីបញ្ជ្រាប ដែលត្រូវបញ្ជ្រាបក្នុងមុខវិជ្ជាភាសាខ្មែរផ្នែកអត្ថបទអំណាន និងអក្សរសិល្ប៍ ។ សៀវភៅទាំងនេះ ត្រូវបានបញ្ចប់សព្វគ្រប់នៅឆ្នាំ ១៩៩៤ ។

បន្ទាប់ពីបានអនុម័តជាផ្លូវការលើសំណៅកម្មវិធីរួចហើយ ក្រសួងអយកបានផ្តល់ពត៌មានដល់វិទ្យាស្ថានកម្ពុជាដើម្បីសិទ្ធិមនុស្សថាមេរៀនសិទ្ធិមនុស្សដែលមាននេះមិនទាន់អាចប្រើប្រាស់ក្នុងថ្នាក់រៀនបានទេ ព្រោះគ្រូបង្រៀនមិនទាន់ចេះប្រើប្រាស់សៀវភៅទាំងនេះ លុះត្រាមានការបណ្តុះបណ្តាល ។ គ្រូបង្រៀនរាប់ពាន់នាក់ ត្រូវបានពិឃាតដោយខ្មែរក្រហម ។ ក្រោយមកទើបមានការជ្រើសរើសគ្រូថ្មី ប៉ុន្តែក្នុងការជ្រើសរើស គេបានជួបប្រទះជាញឹកញាប់នូវគ្រូដែលមានការសិក្សាតិចតួច និងបានឆ្លងកាត់ការបណ្តុះបណ្តាលនិងបទពិសោធន៍រយៈពេលខ្លី ។

សំណើរបស់ក្រសួងអប់រំ យុវជន និងកីឡា សុំអោយវិទ្យាស្ថានកម្ពុជាដើម្បីសិទ្ធិមនុស្សធ្វើការបណ្តុះបណ្តាលដល់គ្រូបង្រៀន គឺជាដំណាក់កាលទី២នៃមហិច្ឆិតារបស់គំរោង ដែលត្រូវបណ្តុះបណ្តាលគ្រូបឋមសិក្សានិងមធ្យមសិក្សាជាង ៧ ម៉ឺននាក់ អោយចេះបង្រៀនសិទ្ធិមនុស្ស ប្រជាធិបតេយ្យ និងធម៌អហិង្សាក្នុងថ្នាក់រៀន ។ រហូតដល់ពាក់កណ្តាលទសវត្សរ៍ឆ្នាំ ១៩៩០ គ្រូបង្រៀនជាង ១ម៉ឺន ៧ពាន់នាក់ ដែលក្នុងចំនួននោះ មានសិក្ខាកាមជាស្ត្រីប្រហែល ៤០ភាគរយ និងមានគ្រូមធ្យមសិក្សាភាគច្រើន បានទទួលការបណ្តុះបណ្តាល ។ វិទ្យាស្ថានបានបន្តធ្វើការវាយតំលៃកម្មវិធីបណ្តុះបណ្តាល និងបានទទួលលទ្ធផលគួរជាទីពេញចិត្ត " *នៅខែកញ្ញា ឆ្នាំ ១៩៩៦ មន្ត្រីអប់រំ និងគ្រូបង្រៀនចំនួន ១៨ ៦៣៧នាក់ បានទទួលការបណ្តុះបណ្តាលវិធីសាស្ត្របង្រៀនសិទ្ធិមនុស្ស ដែលមានន័យថាសិស្សរបស់លោកអ្នកទាំងនោះប្រមាណ ១លាននាក់ ក្នុង ១ឆ្នាំ បានទទួលការបង្រៀនបញ្ញត្តិសិទ្ធិមនុស្ស និងប្រជាធិបតេយ្យ* " កម្មវិធីបណ្តុះបណ្តាលបានទទួលការចូលរួមពីសំណាក់គ្រូឧទ្ទេសថ្នាក់ជាតិ គ្រូមធ្យមសិក្សា គ្រូបឋមសិក្សា គ្រូឧទ្ទេសសំរាប់គរុសិស្សបឋមសិក្សា និងគរុសិស្សបឋមសិក្សា ។ កំណត់ហេតុមួយទៀតបានសរសេរថា :

គ្រូបង្រៀន ៤ម៉ឺននាក់ បានទទួលការបណ្តុះបណ្តាលមុនពេលដែលកាលកំណត់របស់ គំរោងបានបញ្ចប់នៅខែតុលា ឆ្នាំ ២០០១។ គ្រប់សាលារៀននៅទីក្រុងភ្នំពេញ មានតំណាងគ្រូបង្រៀនចូលរួមវគ្គបណ្តុះ បណ្តាលចំនួន ២វគ្គ។ គ្រប់សាលាមធ្យមសិក្សា និងស្ថាប័នបណ្តុះបណ្តាលនិងវិក្រឹតការក្នុងប្រទេសបានទទួលការបណ្តុះបណ្តាល។ គំរោងបានផ្តល់ការបណ្តុះបណ្តាលរយៈពេល ៥ថ្ងៃកន្លះ ផ្តល់ឯកសារ និងបានបង្ហាញវិធីបង្រៀនសិទ្ធិមនុស្ស តាមរបៀបជាមុខវិជ្ជាដោយឡែក ឬតាមរបៀបដែលមានកាលវិភាគចង្អៀត ដោយបញ្ជ្រាបទៅនឹងមុខវិជ្ជាដទៃទៀត ជាច្រើន។ ក្នុងរយៈពេល១០ឆ្នាំកន្លងទៅ ការអប់រំសិទ្ធិមនុស្សត្រូវបានរៀបចំឡើងភាគច្រើនក្នុងបណ្តាសហគមន៍នៅ ទូទាំងប្រទេស ជាញឹកញាប់រៀបចំនៅតាមសាលារៀន ដោយអង្គការសិទ្ធិមនុស្សក្នុងស្រុក និងអន្តរជាតិ។

អង្គការក្រៅរដ្ឋាភិបាលមួយទៀតមានឈ្មោះថា មូលនិធិសិទ្ធិកុមារ ដែលមានបេសកកម្មគាំទ្រសិទ្ធិស្របច្បាប់របស់កុមារនិងយុវជន ធ្វើអោយកុមារសំរេចបាននូវសិទ្ធិរបស់ខ្លួនក្នុងសាលារៀន និងក្នុងសហគមន៍ ក៏បានបង្ហាញជោគជ័យដ៏ធំធេងក្នុងការលើកកំពស់សិទ្ធិ និងការចូលរួមរបស់កុមារ នៅកម្ពុជា។ របាយការណ៍របស់អង្គការមូលនិធិសិទ្ធិកុមារ បានបង្ហាញថាៈ

- គ្រូបង្រៀន គ្រូបង្គោល គ្រូឧទ្ទេសនៅសាលាគរុកោសល្យនិងវិក្រឹតការ មន្ត្រីក្រសួងអប់រំ យុវជន និងកីឡា គណៈគ្រប់គ្រងសាលារៀន និងមន្ត្រីការិយាល័យរដ្ឋបាល បានទទួលការបណ្តុះបណ្តាលសិទ្ធិកុមារ និងការទទួលខុសត្រូវ ការជួញដូរនិងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងការលើកកំពស់ការគោរពវិន័យនិងបទបញ្ជាដោយឆន្ទៈ។

- កុមារ និងយុវជនជាង ៤ម៉ឺននាក់ បានទទួលការបណ្តុះបណ្តាលផ្នែកសិទ្ធិកុមារ ការជួញដូរនិងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងបញ្ហាដទៃទៀតដែលកើតមាន និងប៉ះពាល់ដល់ពួកគេ នៅសាលារៀន និងសហគមន៍។

ទន្ទឹមនឹងនោះ ក្រសួងអប់រំ យុវជន និងកីឡា បានផ្តួចផ្តើមសកម្មភាពជាបន្តបន្ទាប់មួយចំនួនដើម្បីពង្រឹងគុណភាពការអប់រំសិទ្ធិមនុស្សក្នុងសាលារៀន។ នៅឆ្នាំ ២០០៣ ក្រសួងបានបញ្ជូនមន្ត្រីម្នាក់ (លោកស្រី ជិន យ៉ាហាន) ទៅចូលរួមសិក្ខាសាលាថ្នាក់តំបន់ជាច្រើនវគ្គបន្តគ្នា ស្តីពី " ការអប់រំសិទ្ធិមនុស្ស "ដែលបានរៀបចំដោយមជ្ឈមណ្ឌលពត៌មានសិទ្ធិមនុស្សប្រចាំអាស៊ីប៉ាស៊ីភិច (HURIGHT OSAKA)។ បណ្តាវគ្គទាំងនោះ បានបោះជំហានទៅរកការបោះពុម្ពផ្សាយសៀវភៅ " **លំណែនាំការបង្រៀនសិទ្ធិមនុស្ស សំរាប់សាលារៀនអាស៊ីអាគ្នេយ៍** "ជាភាសាអង់គ្លេស នៅខែតុលា ឆ្នាំ ២០០៣។ មួយឆ្នាំក្រោយមក (ខែ តុលា ឆ្នាំ ២០០៤) សៀវភៅនោះ ត្រូវបានបកប្រែជាភាសាខ្មែរ និងបោះពុម្ពបានចំនួន ៦៥០ក្បាល ហើយបានបែងចែកទៅស្ថាប័នពាក់ព័ន្ធ និងមន្ទីរអប់រំ យុវជន និងកីឡា នៅខេត្តក្រុងទាំង ២៤ ក្នុងប្រទេសកម្ពុជា បានចំនួនពី ២០ ទៅ ៣០ក្បាល សំរាប់កន្លែងទទួលនីមួយៗ។ នៅខែមេសា ឆ្នាំ ២០០៥ មន្ត្រីនាយកដ្ឋានស្រាវជ្រាវគរុកោសល្យ ៣ រូប (គឺលោក អេង គឹមលី អនុប្រធាននាយកដ្ឋានស្រាវជ្រាវគរុកោសល្យ, លោកស្រី ថាច់ ធីសារ៉ន អនុប្រធានការិយាល័យអភិវឌ្ឍកម្មវិធីសិក្សា, និងលោកស្រី ជិន យ៉ាហាន មន្ត្រីជំនាញអភិវឌ្ឍកម្មវិធីសិក្សា) បានទទួលការអញ្ជើញទៅចូលរួមក្នុងសិក្ខាសាលាថ្នាក់តំបន់ស្តីពីការប្រកាសផ្សាយជាផ្លូវការសៀវភៅ " **លំណែនាំការបង្រៀនសិទ្ធិមនុស្ស សំរាប់សាលារៀនអាស៊ីអាគ្នេយ៍** "ដែលមានបកប្រែជាភាសាជាតិរបស់ប្រទេសមួយចំនួន។ សិក្ខាសាលានោះ ក៏បានផលិតចេញនូវសេចក្តីព្រាងផែន

ការសកម្មភាពពង្រឹងការអប់រំសិទ្ធិមនុស្សនៅប្រទេសរៀងៗខ្លួន និងបានណែនាំការប្រើប្រាស់សៀវភៅដែលទើបប្រកាសផ្សាយនោះ ។

នៅខែឧសភា ឆ្នាំ ២០០៥ សេចក្តីព្រាងផែនការសកម្មភាពពង្រឹងការអប់រំសិទ្ធិមនុស្សនៅប្រទេសនីមួយៗ ត្រូវបានលើកយកទៅពិនិត្យជាថ្មីនៅសិក្ខាសាលាថ្នាក់តំបន់មួយ ។ ផែនការសកម្មភាពដែលមានឈ្មោះថា " គំរោងបណ្តុះបណ្តាលវិធីបញ្ជ្រាបសិទ្ធិមនុស្សទៅក្នុងកម្មវិធីសិក្សា សៀវភៅសិក្សា និងបរិយាកាសសាលារៀន ២០០៥ - ២០០៧ ដែលក្នុងនោះមានផែនការអនុវត្តសកម្មភាពដោយមានការចូលរួមពីអង្គការក្រៅរដ្ឋាភិបាលផ្នែកសិទ្ធិមនុស្ស បានទទួលការឯកភាពអំពីអគ្គនាយកដ្ឋានអប់រំ ។ នៅខែវិច្ឆិកា ឆ្នាំ ២០០៥ ផែនការសកម្មភាពនោះ បានលើកឡើងនៅក្នុងសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិមួយនៅសណ្ឋាគារឡឺរ៉ូយ៉ាល់ ដែលរៀបចំដោយនាយកដ្ឋានស្រាវជ្រាវគរុកោសល្យ ឧបត្ថម្ភដោយអង្គការយូណេស្កូ នៅភ្នំពេញ និងមានការចូលរួមជាប្រធានគណៈអធិបតីពីសំណាក់ឯកឧត្តម អ៊ឹម សិទ្ធី ( កាលនោះឯកឧត្តមជារដ្ឋលេខាធិការក្រសួងអយក) ។

សិក្ខាសាលាពិគ្រោះយោបល់នោះ បានលើកឡើងនូវអនុសាសន៍ដូចខាងក្រោមនេះ :

- ក្រសួងអប់រំ យុវជន និងកីឡា គួរលើកទឹកចិត្តការគោរព និងការធ្វើអោយសំរេចបាននូវសិទ្ធិមនុស្សនៅក្នុងប្រព័ន្ធសាលារៀន ។
- គួរមានការពង្រឹងសមត្ថភាពគ្រូបង្រៀនដែលមានតួនាទីសំខាន់ក្នុងក្នុងការងប់រំសិទ្ធិមនុស្ស និងមន្ត្រីថ្នាក់កណ្តាលដែលមានតួនាទីពិនិត្យតាមដានការអនុវត្តសិទ្ធិមនុស្ស ។
- គួរមានការបញ្ជ្រាបបញ្ញត្តិសិទ្ធិមនុស្សនៅក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូគ្រប់កំរិត ។
- គួរដាក់សំណើសុំអ្នកពិគ្រោះការ និងថវិកាឧបត្ថម្ភ ទៅអង្គការការិយាល័យអង្គការយូណេស្កូ នៅក្នុងប្រទេសឬនៅក្នុងតំបន់ និងគួរអនុវត្តគំរោងទៅមុខទៀត ។
- គួរបន្តបញ្ជ្រាបបញ្ញត្តិសិទ្ធិមនុស្ស សិទ្ធិកុមារ ទៅក្នុងមុខវិជ្ជាពាក់ព័ន្ធជាក់លាក់ ។
- គួរសហការជាមួយអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការងារផ្នែកសិទ្ធិមនុស្ស ។

ប៉ុន្តែ បន្ទាប់ពីបានធ្វើសិក្ខាសាលាពិគ្រោះយោបល់នោះរួចមក មិនមានការអនុវត្តតាមផែនការសកម្មភាពដែលបានទទួលការឯកភាពកន្លងមកនោះទេ ដោយមូលហេតុខ្វះថវិកាគាំទ្រ ។

នៅថ្ងៃទី ២៩ ដល់៣០ ខែឧសភា ឆ្នាំ ២០០៧ នាយកដ្ឋានស្រាវជ្រាវគរុកោសល្យបានរៀបចំសិក្ខាសាលាមួយទៀតស្តីពី " ការអប់រំផ្អែកលើមូលដ្ឋានសិទ្ធិមនុស្ស សន្តិភាព និងការអភិវឌ្ឍ " ដែលឧបត្ថម្ភដោយអង្គការយូណេស្កូ នៅភ្នំពេញដើម្បីពិចារណាឡើងវិញពីការប្រើប្រាស់សៀវភៅ "**លំណែនាំការបង្រៀនសិទ្ធិមនុស្ស សំរាប់សាលារៀនអាស៊ីអាគ្នេយ៍** " ដែលមានជាភាសាខ្មែរ ( ឧបត្ថម្ភការបោះពុម្ពដោយអង្គការយូណេស្កូ បាងកកពីឆ្នាំ ២០០៤), ការងារបន្តរបស់មន្ត្រីអប់រំដែល

បានទៅចូលរួមសិក្ខាសាលាថ្នាក់តំបន់ពីឆ្នាំ ២០០៥ នៅទីក្រុងម៉ានីល អំពីការប្រកាសផ្សាយសៀវភៅ " លំណែនាំ..." (ឧបត្ថម្ភដោយការិយាល័យនៃឧត្តមស្នងការសហប្រជាជាតិដើម្បីសិទ្ធិមនុស្ស), គំរោងផែនការសកម្មភាព បញ្ជ្រាបសិទ្ធិមនុស្សក្នុងកម្មវិធីសិក្សា សៀវភៅសិក្សា និងបរិយាកាសសាលារៀន ២០០៥ - ២០០៧ (ដែលបានស្នើឡើងដោយនាយកដ្ឋានស្រាវជ្រាវគរុកោសល្យ), លទ្ធផលនៃសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិដែលបានរៀបចំពីខែវិច្ឆិកា ឆ្នាំ ២០០៥ (ឧបត្ថម្ភដោយអង្គការយូណេស្កូ នៅភ្នំពេញ)និងការអនុវត្តគំរោងផែនការសកម្មភាព, ការបោះពុម្ពសៀវភៅ " លំណែនាំ... " បន្ថែមចំនួន ១០០០ក្បាល (ឧបត្ថម្ភដោយអង្គការយូណេស្កូ នៅភ្នំពេញ ពីខែកក្កដា ឆ្នាំ ២០០៦), និងដើម្បីរំលឹកការចាប់អារម្មណ៍ដល់ស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តផែនការអប់រំសិទ្ធិមនុស្សរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

សិក្ខាសាលាស្តីពី " ការអប់រំផ្អែកលើមូលដ្ឋានសិទ្ធិមនុស្ស សន្តិភាព និងការអភិវឌ្ឍ " មានវត្ថុបំណង:

- ធ្វើការអភិវឌ្ឍ និងស្នើឡើងនូវបណ្តាញគ្រូឧទ្ទេសនៅតាមភូមិភាគនីមួយៗក្នុងប្រទេស ដើម្បីបណ្តុះបណ្តាលការបញ្ជ្រាបបញ្ញត្តិសិទ្ធិមនុស្សទៅក្នុងកម្មវិធីសិក្សា ។

- លើកបង្ហាញសៀវភៅ "**លំណែនាំការបង្រៀនសិទ្ធិមនុស្ស សំរាប់សាលារៀនអាស៊ីអាគ្នេយ៍** " (ជាភាសាខ្មែរ) ដែលចាត់ទុកជាមូលដ្ឋាននៃការបណ្តុះបណ្តាលគ្រូ និងការប្រើប្រាស់ក្នុងថ្នាក់រៀន តាមរយៈ :

- ការពិភាក្សាអំពីបញ្ញត្តិសិទ្ធិមនុស្ស ដោយផ្អែកលើសេចក្តីថ្លែងការណ៍សកលស្តីពីសិទ្ធិមនុស្សនិងអនុសញ្ញាស្តីពីសិទ្ធិកុមារ ។
- ការពិភាក្សាអំពីគោលវិធីបញ្ជ្រាបដែលត្រូវអនុវត្តចំពោះការអប់រំសិទ្ធិមនុស្ស ។
- ការណែនាំបង្ហាញសៀវភៅ " លំណែនាំ.. ទុកជាឧទាហរណ៍នៃការបញ្ជ្រាបសិទ្ធិមនុស្សក្នុងមុខវិជ្ជានានា ។
- លំហាត់ប្រើប្រាស់សៀវភៅ " លំណែនាំ.."
- លំហាត់អំពីការបណ្តុះបណ្តាលគ្រូលើការអនុវត្តសិទ្ធិមនុស្ស

- ធ្វើផែនការតាមដាន និងត្រួតពិនិត្យការបណ្តុះបណ្តាលគ្រូអំពីការអប់រំសិទ្ធិមនុស្ស ។




រូបថតៈ ការថ្លែងសុន្ទរកថាបើកសិក្ខាសាលារបស់ឯកឧត្តម កុល ផេង រដ្ឋមន្ត្រីក្រសួងអយក, ប្រធានគណៈអធិបតី

គណៈអធិបតី (ពីឆ្វេងទៅស្តាំៈ ១.លោកស្រី ទន់ សាអ៊ីម ប្រធាននាយកដ្ឋានស្រាវជ្រាវគរុកោសល្យ, ២. លោកបណ្ឌិត សម្តេតសែនភុនប្រសើរសិរី អតីតអ្នកជំនាញផ្នែកអប់រំ, អង្គការយូណេស្កូ ភ្នំពេញ,៣. លោក ហ្វីលីព ត់ណាងអង្គការយូណេស្កូ, ភ្នំពេញ,៤. កញ្ញា ចូហាណា ស៊ី អ៊ិនខាបូ អ្នកជំនាញកម្មវិធី, អង្គការយូណេស្កូ, មជ្ឈមណ្ឌលអប់រំការយល់គ្នាជាអន្តរជាតិ, អាស៊ីប៉ាស៊ីហ្វិច)



រូបថតៈ សមាជិកចូលរួមក្នុងសិក្ខាសាលា

ដោយមានការចូលរួមរបស់សិក្ខាកាមចំនួន ៧៩ រូប មកពីក្រសួងអប់រំ យុវជន និងកីឡា, អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកដែលធ្វើការងារផ្នែកសិទ្ធិមនុស្ស, និងអង្គការយូណេស្កូនៅភ្នំពេញ សិក្ខាសាលាសំរេចបានលទ្ធផលដូចខាងក្រោមៈ

- បញ្ញត្តិសិទ្ធិមនុស្ស ត្រូវបានយល់ច្បាស់ បន្ទាប់ពីសិក្ខាកាមបានឆ្លងកាត់បទបង្ហាញ សកម្មភាពសួរ-ឆ្លើយ ការពិភាក្សាតាមក្រុម និងការលើកផែនការសកម្មភាពលើកកំពស់ការយល់ដឹងអំពីសិទ្ធិមនុស្សនៅតាមស្ថាប័ន/អង្គភាពរៀងៗខ្លួន។

❖ សិក្ខាកាមបានស្នើឡើងនូវមតិយោបល់ និងអនុសាសន៍មួយចំនួន ដើម្បីគូសបញ្ជាក់លើយុទ្ធសាស្ត្រដែលបានរៀបចំឡើងហើយ អោយឈានទៅសំរេចគោលដៅនៃការអប់រំផ្អែកលើសិទ្ធិមនុស្ស សន្តិភាព និងការអភិវឌ្ឍ ដូចខាងក្រោមនេះ :

- បរិយាកាសដែលមានការគោរពសិទ្ធិមនុស្ស និងសន្តិភាព ក្នុងវិស័យអប់រំ នៅកម្ពុជា គួរថែបំប៉ន ។
- សៀវភៅ "**លំណែនាំការបង្រៀនសិទ្ធិមនុស្ស សំរាប់សាលារៀនអាស៊ីអាគ្នេយ៍**" (ជាភាសាខ្មែរ) គួរបោះពុម្ពបន្ថែម និងចែកជូនទៅគ្រូបង្រៀន ក៏ដូចជាគ្រូឧទ្ទេសនៅមជ្ឈមណ្ឌលគរុកោសល្យ ដើម្បីទុកជាសម្ភារៈប្រើប្រាស់ក្នុងវគ្គបណ្តុះបណ្តាលគរុសិស្ស និងវគ្គវិក្រឹតការ ។
- ឯកសារ និងគំនិតពាក់ព័ន្ធពិសេសដល់លំនាំនៃការបង្រៀន និងរៀនសិទ្ធិមនុស្ស ដែលទទួលបានអំពីសិក្ខាសាលានេះ គួរផ្សព្វផ្សាយបន្តអោយដល់មន្ត្រីអប់រំខេត្ត គ្រូបង្រៀន មាតាបិតាសិស្ស និងសិស្ស ។
- អង្គការយូណេស្កូ និង/ឬ ភ្នាក់ងារពាក់ព័ន្ធដទៃទៀត គួរផ្តល់ការឧបត្ថម្ភគាំទ្របន្ថែមទៀតដល់វគ្គបណ្តុះបណ្តាលសិទ្ធិមនុស្សនៅថ្នាក់ខេត្ត ស្រុក និងសហគមន៍ ។
- សារទាំងអស់របស់សិក្ខាសាលានេះ គួរត្រូវបានបញ្ជូនអោយដល់មន្ត្រីក្រោមឱវាទដទៃទៀត អោយបានញឹកញាប់ យ៉ាងហោចណាស់នៅពេលប្រជុំប្រចាំខែ ។

រួមមក ជាបឋម សិក្ខាសាលានេះបានផ្តល់ដល់ក្រសួងអប់រំនូវក្រុមអ្នកមានមូលដ្ឋានចំណេះដឹងក្នុងការបណ្តុះបណ្តាលសិទ្ធិមនុស្ស ដែលបានអញ្ជើញមកពីគ្រប់ភូមិភាគក្នុងប្រទេស ។ សារៈបន្ទាប់គឺ សៀវភៅ "**លំណែនាំការបង្រៀនសិទ្ធិមនុស្សសំរាប់សាលារៀនអាស៊ីអាគ្នេយ៍**" (ជាភាសាខ្មែរ) ដែលបានបោះពុម្ពលើកទី ២ ចំនួន ១០០០ ក្បាល បានផ្ញើជូនទៅគ្រប់ខេត្តក្រុង ។ ជាសរុប មន្ទីរអប់រំខេត្តក្រុងនីមួយៗ បានទទួលសៀវភៅចំនួនប្រមាណ ៥០ក្បាល ដែលត្រូវចែកជូនទៅសាលារៀនមួយចំនួន និងសាលាគរុកោសល្យក្នុងខេត្តក្រុង ។ ប៉ុន្តែ ចំនួននេះមិនគ្រប់គ្រាន់ទេ បើប្រៀបធៀបនឹងចំនួន ២៣ ៩៩៧ក្បាល ( ៣ក្បាល ក្នុងសាលារៀនមួយ × ៧ ៩៩៩សាលារៀន) ដែលត្រូវការនៅទូទាំងប្រទេស ។

ដូចគ្នានឹងរបាយការណ៍របស់អង្គការក្រៅរដ្ឋាភិបាល លទ្ធផលនៃការអង្កេតស្រាវជ្រាវចំនួន ២លើក ( នៅខែ តុលា ឆ្នាំ ២០០៧ និងខែឧសភា ឆ្នាំ ២០០៨) ដែលបានអនុវត្តនៅសាលារៀន និងស្ថាប័នគោលដៅជំរើសមួយចំនួន ក្នុងខេត្តក្រុងទាំង ២៤ បានផ្តល់នូវកំរងចម្លើយរាប់ពាន់ច្បាប់ ។ ប៉ុន្តែ ដោយហេតុមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការបញ្ចូលទិន្នន័យទាំងអស់បាន យើងបានជ្រើសយកតាមរបៀបចៃដន្យនូវសន្លឹកកិច្ចការមួយចំនួនប៉ុណ្ណោះដើម្បីធ្វើការស្រង់ទិន្នន័យ ។

ជាទូទៅ យើងបានអោយដឹងថា ក្នុងបណ្តាអ្នកផ្តល់ចម្លើយទាំងអស់( ក្នុងនោះមានមន្ត្រីអប់រំ គ្រូបង្រៀន និងសិស្សានុសិស្ស) មាន ៨០ភាគរយ បានយល់អំពីបញ្ញត្តិសិទ្ធិមនុស្ស ( សូមមើលកំរងសំណួរជាច្រើនប្រភេទ ដែលមានជូនភ្ជាប់នៅអត្ថបទបន្ថែម) ។

តបតាមកំរងសំណួរមួយប្រភេទដែលបានផ្ញើទៅសិស្សានុសិស្សបឋមសិក្សា និងមធ្យមសិក្សា កំរងចំឡើយចំនួន ១ ៤៤០ ច្បាប់បានទទួល ក្នុងនោះមាន ៤៥៦ច្បាប់ ត្រូវបានជ្រើសរើសតាមរបៀបចៃដន្យ ដើម្បីបញ្ចូលទិន្នន័យ និងវិភាគ។ ខាងក្រោមនេះ ជាទិន្នន័យចម្លើយ ដែលបានឆ្លើយតបនឹងសំណួររកអនុសាសន៍ពាក់ព័ន្ធនឹងការយល់អំពីបញ្ញត្តិសិទ្ធិមនុស្ស :

- សិស្ស ៣២.៧% (ក្នុងចំណោម ៤៥៦នាក់) ស្នើសុំអោយការអប់រំមានគុណភាពខ្ពស់ជាងមុន។
- ១៨% ស្នើសុំអោយជីវភាពរស់នៅរបស់ពួកគេមានភាពប្រសើរជាងមុន។
- ១២.៣% ស្នើសុំអោយមានការផ្គត់ផ្គង់សម្ភារៈសិក្សា។
- ៦.១% ស្នើសុំអោយមានការលើកកំពស់ការយល់ដឹងអំពីសិទ្ធិមនុស្សដល់សហគមន៍មូលដ្ឋានរបស់ពួកគេ។
- ៤.៤% ស្នើសុំអោយមានការលើកកំពស់ការយល់ដឹងអំពីសិទ្ធិមនុស្សដល់គ្រូបង្រៀនមួយចំនួន។
- ២.៤% ស្នើសុំអោយមានការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ។
- ២.៤% បានថ្លែងអំណរគុណចំពោះការផ្តល់ឱកាសដល់ពួកគេអោយបានឆ្លើយនឹងកំរងសំណួរនេះ ហើយសុំអោយមានការសួររបៀបនេះជារៀងរាល់ឆ្នាំ។
- ២.៤% បានអំពាវនាវដល់កុមារទាំងអស់អោយមានការអធ្យាស្រ័យចំពោះគ្នានឹងគ្នា។
- ១.៣% បានសុំអោយមានការផ្សព្វផ្សាយអំពីសិទ្ធិកុមារអោយដល់កុមារទាំងអស់នៅទូទាំងប្រទេស។
- ១.១% បានស្នើសុំអោយសាលារៀនរបស់ពួកគេមានគ្រូគ្រប់គ្រាន់។
- ០.៤% បានអំពាវនាវអោយកុមារទាំងអស់ចៀសវាងប្រើគ្រឿងញៀន ព្រោះវានាំអោយខូចសុខភាព។
- និងនៅទីបំផុត កុមារ ១៦.៤% មិនមានយោបល់អ្វីទេ។

ច្បាស់លាស់ណាស់ថា តាមរយៈសកម្មភាពទាំងឡាយដែលបានបំពេញក្នុងការស្រាវជ្រាវអង្កេត លទ្ធផលនៃគំរោងអប់រំសិទ្ធិមនុស្សរបស់ក្រសួងអប់រំ យុវជន និងកីឡាដែលបានសហការជាមួយសង្គមស៊ីវិលនានា អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ បានបង្ហាញអោយឃើញត្រឹមកំរិតអាចទទួលយកបានប៉ុណ្ណោះ។ យើងបានមើលឃើញថា ការអប់រំសិទ្ធិមនុស្សបានប្រឈមមុខនឹងឧបសគ្គជាច្រើន ក្នុងនោះមានភាពក្រីក្រផងដែរ។ ជាក់ស្តែង បណ្តាអនុសាសន៍ដែលយើងបានឃើញខាងលើនេះ បានឆ្លុះអោយឃើញពីកង្វល់របស់កុមារដែលមានភាពទាក់ទិននឹងសិទ្ធិមនុស្ស ដែលត្រូវដោះស្រាយព្រមគ្នា ចាប់ពីពេលនេះតទៅ។

ដំណោះស្រាយជាក់ស្តែងគឺ ការអប់រំសិទ្ធិមនុស្សក្នុងសាលារៀនត្រូវអោយមានភាពស៊ីសង្វាក់គ្នានឹងការបំពេញ

ង្រៀន និងសម្ភារៈសិក្សាគ្រប់គ្រាន់ ការផ្គត់ផ្គង់ជីវភាពគ្រូបង្រៀន ការអនុវត្តយុទ្ធសាស្ត្រ

។

...ទោះបីមានអធិការកិច្ចអនុវត្តយ៉ាងទៀងទាត់ក៏ដោយ ក៏ក្រសួងអយកនៅតែមិនទាន់ ...នោថាគ្រូបង្រៀនកំពុងតែធ្វើការអប់រំសិទ្ធិមនុស្សនៅក្នុងសាលារៀននៅឡើយ ។

## ...រវិភាគខ្លឹមសារច្បាប់អប់រំ គោលនយោបាយ កម្មវិធីសិក្សា និងកម្មវិធីផ្សេងៗ

ដោយគោរពតាមច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ ជាពិសេសដើម្បីគោរពសិទ្ធិមនុស្សដូចមានចែងក្នុងមាត្រា ៣១ នៃច្បាប់រដ្ឋធម្មនុញ្ញ :

*ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។*

*ប្រជាពលរដ្ឋខ្មែរមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពទៀតឡើយ ។ ឯការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខ័ណ្ឌកំណត់ក្នុងច្បាប់ ។*

និងដោយគោរពតាមនិយមន័យ " ការអប់រំសិទ្ធិមនុស្ស " ដែលមានចែងក្នុងផែនការសកម្មភាពដំណាក់កាលទី ១ នៃ គំរោងកម្មវិធីពិភពលោកដើម្បីការអប់រំសិទ្ធិមនុស្ស :

*ការអប់រំសិទ្ធិមនុស្ស អាចផ្តល់និយមន័យថាជា ការអប់រំ ការបណ្តុះបណ្តាល និងការផ្តល់ពត៌មាន ដែលផ្តោតទៅលើការកសាងវប្បធម៌សកលមួយ ហៅថាវប្បធម៌សិទ្ធិមនុស្ស ។ ការអប់រំសិទ្ធិមនុស្ស ក្នុងន័យទូលាយ គឺមិនមែនត្រឹមតែជាការផ្តល់នូវចំណេះដឹងអំពីសិទ្ធិមនុស្ស និងការអនុវត្តយន្តការដើម្បីការពារសិទ្ធិមនុស្សប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការផ្តល់ដោយឡែកនូវបំណិនចាំបាច់នានា សម្រាប់ប្រើប្រាស់ក្នុងការលើកកំពស់ ការបង្ការ និងការអនុវត្តសិទ្ធិមនុស្សក្នុងជីវភាពប្រចាំថ្ងៃផងដែរ ។ ការអប់រំសិទ្ធិមនុស្ស ចិញ្ចឹមទុកនូវឥរិយាបថនិងអាកប្បកិរិយាចាំបាច់នានា ដើម្បីគាំទ្រសិទ្ធិមនុស្សរបស់សមាជិកសង្គមគ្រប់រូប ។*

បណ្តាច្បាប់ គោលនយោបាយ គំរោងកម្មវិធី និងកម្មវិធីសិក្សានានា ដែលជារបស់ក្រសួងអប់រំ យុវជន និងកីឡា អាចលើកយកមកវិភាគបង្ហាញជូនដូចខាងក្រោមនេះ :

### ក. គោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សា ២០០៥ - ២០០៩

គោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សា ២០០៥ - ២០០៩ ត្រូវបានគេមើលឃើញថាជាឧបករណ៍អប់រំ ដែលផ្តល់

ឱកាសយ៉ាងច្រើនដល់ការអនុវត្តសិទ្ធិទទួលការអប់រំ នៅក្នុងប្រព័ន្ធសាលារៀន ។ ឥរិយាបថ និងបំណិនរបស់សិស្ស ដែលមានចែងក្នុងគោលនយោបាយ មានការផ្សារភ្ជាប់ទៅនឹងសិទ្ធិមនុស្ស ។ ឧទាហរណ៍ មាត្រា ២.១ បានគាំទ្រសិទ្ធិទទួលការអប់រំសិទ្ធិចូលរួម សិទ្ធិក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម សិទ្ធិមានសេរីភាពក្នុងការសំដែងមតិ សិទ្ធិមានសេរីភាពក្នុងជំនឿ ជាដើម ។ល ។( សូមមើលខ្លឹមសារដកស្រង់នៅទំព័រអត្ថបទបន្ថែម) ។

តាមការពិនិត្យដល់កម្មវិធីសិក្សាចំណេះទូទៅ យើងមើលឃើញថាបញ្ញត្តិសិទ្ធិមនុស្សអាចបង្រៀនបានជាចំបង និងដោយត្រង់ៗក្នុងមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា ។ មុខវិជ្ជានេះជាមុខវិជ្ជារងមួយ ក្នុងចំណោមមុខវិជ្ជារងបួន ( សីលធម៌-ពលរដ្ឋវិជ្ជា, ប្រវត្តិវិទ្យា, ភូមិវិទ្យា, និងគេហវិទ្យា-សេដ្ឋកិច្ច) នៃមុខវិជ្ជាសិក្សាសង្គម ហើយត្រូវបានដាក់ជាមុខវិជ្ជាតំរូវអោយសិស្សសិក្សាពីថ្នាក់ទី ១ ដល់ទី ១០ និងត្រូវបានដាក់ជាមុខវិជ្ជាជ្រើសរើសនៅថ្នាក់ទី ១១ រហូតដល់ ១២ ។

ខ្លឹមសារមាត្រាក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារដែលចែងអំពីសិទ្ធិទទួលការការពារ ត្រូវបានលើកយកទៅដាក់ឱ្យសិស្សថ្នាក់ទី១-៣សិក្សា ក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ-សិក្សាសង្គម រយៈពេល ៣ម៉ោងសិក្សាក្នុង ១សប្តាហ៍ តាមរយៈការផ្តល់ចំណេះដឹងមូលដ្ឋានអំពីអ្វីគួរធ្វើ អ្វីមិនគួរធ្វើនៅផ្ទះ នៅតាមផ្លូវពីផ្ទះទៅសាលារៀន នៅសាលារៀន ដោយស្របតាមទំនៀមទំលាប់ប្រពៃណីខ្មែរ និងវិន័យសីលធម៌បច្ចុប្បន្ន ។

សិទ្ធិទទួលការការពារ សិទ្ធិមានការអភិវឌ្ឍ សិទ្ធិទទួលការគោរពសេចក្តីថ្លៃថ្នូរក្នុងនាមជាមនុស្ស ..ល.ដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ត្រូវបានរៀបជាមេរៀនដាក់អោយសិស្សសិក្សា ក្នុងមុខវិជ្ជាវិទ្យាសាស្ត្រ និងមុខវិជ្ជាសិក្សាសង្គម នៅថ្នាក់ទី ៤ ចំនួន ៤ម៉ោងសិក្សាក្នុងមួយសប្តាហ៍ និងនៅថ្នាក់ទី ៥ ចំនួន ៥ម៉ោងសិក្សាក្នុងមួយសប្តាហ៍ ។ មុខវិជ្ជាទាំងពីរនេះ មានដាក់សំណួរពិភាក្សាអំពីវិន័យសីលធម៌បច្ចុប្បន្ន និងបន្ថែមអំពីទំនាក់ទំនងល្អប្រកបដោយសុវត្ថិភាពជាមួយអ្នកដទៃមានមិត្តភក្តិ ឬប្រជាជនក្នុងសហគមន៍ជាដើម ហើយនិងអំពីអ្វីគួរធ្វើដើម្បីរក្សាបរិស្ថានធម្មជាតិអោយនៅគង់វង្សល្អ ។

ការសិក្សាក្នុងមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា ដែលជាមុខវិជ្ជារងនៃមុខវិជ្ជាសិក្សាសង្គម ចំនួន ២ម៉ោង ក្នុង ១សប្តាហ៍ មានការដាក់សំណួរអោយសិស្សពិភាក្សាដើម្បីមានការយល់ដឹងជាមូលដ្ឋានអំពី :

- សិទ្ធិស្ត្រី ដោយធៀបនឹងផ្នត់គំនិតចាស់អំពីយេនឌ័រ ។
- ទំនាក់ទំនងល្អប្រកបដោយសុវត្ថិភាពរវាងក្មេងប្រុស និងក្មេងស្រី ។
- វិធីល្អក្នុងការជ្រើសរើសតំណាង ឬអ្នកដឹកនាំល្អ ក្នុងចំណោមសិស្សក្នុងថ្នាក់ ។
- សិទ្ធិកុមារពិការ ដោយធៀបនឹងផ្នត់គំនិតចាស់អំពីការរើសអើង ។
- សន្តិភាព និងការបំបាត់អាវុធ ។
- ការបោះឆ្នោតថ្នាក់ឃុំ សង្កាត់ ។

- សារៈសំខាន់នៃការងារ ។
- ពហុវប្បធម៌ក្នុងជំនឿ ។
- មតិផ្សេងៗផ្អែកលើសិទ្ធិមនុស្ស ដែលមានក្នុងសហគមន៍ ស្ដីពីរូបរាង គុណសម្បត្តិ ជំនាញ និង សមត្ថភាពរបស់បុរស ដោយធៀបនឹងស្ត្រី របស់សាសន៍មួយ ដោយធៀបនឹងសាសន៍មួយទៀត ។
- គោលការណ៍ដំណោះស្រាយដោយសន្តិវិធី ចំពោះទំនាស់ដែលកើតមាននៅកន្លែងធ្វើការ ទំនាស់ រវាងមនុស្ស និងមនុស្ស រវាងប្រជាជាតិមួយនិងប្រជាជាតិមួយទៀត ។
- វិធីអភិរក្សឥរិយាបថ វប្បធម៌ ប្រពៃណីខ្មែរ ដោយស្របនឹងការយល់ដឹងកាន់តែច្រើន អំពីសិទ្ធិមនុស្ស ។
- គោលការណ៍សំខាន់ៗនៃលទ្ធិប្រជាធិបតេយ្យ ។
- សារៈសំខាន់នៃបញ្ញត្តិអភិបាលកិច្ចល្អ
- មធ្យោបាយបង្កើតការងារ ។

ការយល់ដឹងជាមូលដ្ឋានអំពីប្រធានរឿងខាងលើនេះ នាំទៅរកការយល់ដឹងអំពីសិទ្ធិទទួលការការពារ សិទ្ធិមានការអភិវឌ្ឍ សិទ្ធិចូលរួម សិទ្ធិមានសន្តិសុខសង្គម សមភាពយេនឌ័រ សិទ្ធិមានសេចក្ដីថ្លៃថ្នូរជាមនុស្ស ..ល. ដូចដែលមានចែងក្នុង សេចក្ដីថ្លែងការណ៍សកលស្ដីពីសិទ្ធិមនុស្ស, សិទ្ធិកុមារ, អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនារីភេទ ជាដើម ។ល ។

ចំពោះកម្មវិធីសិក្សាសំរាប់មធ្យមសិក្សាទុតិយភូមិ ដោយការអនុវត្តតាម ៣ មាត្រានៃគោលនយោបាយ ( មាត្រា ៩.៣, ១០.១, ១១.១) ការសិក្សាច្រើនជាងមុនលើបញ្ញត្តិសិទ្ធិមនុស្សដែលមាននៅសេចក្ដីថ្លែងការណ៍សកលស្ដីពីសិទ្ធិ មនុស្ស, អនុសញ្ញាស្ដីពីសិទ្ធិកុមារ, អនុសញ្ញាស្ដីពីការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនារីភេទ, អនុសញ្ញាអន្តរ ជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, អនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌, និងមាត្រាច្បាប់ក្នុង ប្រទេសមួយចំនួន ត្រូវបានបញ្ជ្រាបក្នុងមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា ពីថ្នាក់ទី ១០ ដល់ទី ១២ ។ បន្ថែមលើនេះចំនួនម៉ោង សិក្សាក្នុងមុខវិជ្ជានេះ នៅថ្នាក់ទី ១១ និងទី ១២ ត្រូវបានបង្កើនពី ២ម៉ោង ទៅ ៦ម៉ោង ក្នុងមួយសប្ដាហ៍ ។

ទោះជាយ៉ាងណាក៏ដោយ ក៏នៅមានភាពមិនប្រាកដថាមេរៀនទាំងនេះនឹង "ធានាឱ្យសិស្សមាន( ឬ នឹងទទួលបាន) ការយល់ដឹងស៊ីជំរៅនិងច្រើនជាងមុន អំពីសីលធម៌ និងការទទួលខុសត្រូវជាពលរដ្ឋ" នោះទេ ពីព្រោះមុខវិជ្ជានេះ នៅតែត្រូវ បានចាត់ទុកជាមុខវិជ្ជារងនៃមុខវិជ្ជាសិក្សាសង្គម និងជាមុខវិជ្ជាជ្រើសរើសនៅឡើយ ទោះបីមាត្រា ២៣ នៃច្បាប់អប់រំ បាន

ចែងអំពីការកំណត់ជាធាតុសំខាន់នៃកម្មវិធីសិក្សាគោលនូវការអប់រំសីលធម៌ និងពលរដ្ឋវិជ្ជា [១៧] ក៏ដោយ ដោយមាន អំណះអំណាងថាច្បាប់អប់រំចេញ (នៅឆ្នាំ ២០០៧) ក្រោយការចេញគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សា (ចេញនៅឆ្នាំ ២០០៥) ។

មាតាបិតាសិស្ស/សហគមន៍មូលដ្ឋាន/អង្គការក្រៅរដ្ឋាភិបាល ក៏មានតួនាទីជួយដល់សាលារៀនផងដែរ ក្នុងការគាំទ្រសកម្មភាពក្រៅថ្នាក់ដែលមាននៅក្នុងកម្មវិធីបំណិនជីវិតតាមមូលដ្ឋាន តាមរយៈការផ្តល់ឱកាសឱ្យមានការបណ្តុះបណ្តាលបំណិនជាក់លាក់ដែលសមស្របទៅនឹងតំរូវការនៃមូលដ្ឋានរបស់សិស្ស (តាមមាត្រា ៣.១ ដល់៣.១១) ។

បន្ថែមលើនេះ គោលនយោបាយមានចែងមាត្រាមួយចំនួនដែលគាំទ្រដល់សិស្សពិការឬសិស្សមានតម្រូវការពិសេស (មាត្រា ៣.១៤ ដល់ ៣.១៩) ។

កម្មវិធីសិក្សាថ្មី មានគំរោងនឹងចាប់ផ្តើមអនុវត្ត ពីឆ្នាំសិក្សា ២០០៧ - ២០០៨ នៅថ្នាក់ទី ១ ។ ឯថ្នាក់បន្តបន្ទាប់ទៀត នឹងត្រូវអនុវត្តនៅឆ្នាំបន្ទាប់ ។ បច្ចុប្បន្ន សៀវភៅសិស្ស និងសៀវភៅគ្រូកំពុងអភិវឌ្ឍដោយផ្នែកឯកជន ។ ដោយឡែក ក្រសួងអប់រំ យុវជន និងកីឡា កំពុងធ្វើផែនការបណ្តុះបណ្តាលគ្រូ ។

ប៉ុន្តែ យន្តការដើម្បីការបណ្តុះបណ្តាលសិទ្ធិមនុស្ស ក៏ដូចជាការវាស់ស្ទង់នៅតែជាតំរូវការចាំបាច់ ។ ការចូលរួមវិភាគទាននាពេលអនាគតអំពីសំណាក់គំរោងអប់រំសិទ្ធិមនុស្សជាលាក់ណាមួយ ជាតំរូវការចាំបាច់ ដើម្បីចូលទៅជំនួសគំរោងបណ្តុះបណ្តាលថ្នាក់ជាតិ (២០០៥ -២០០៧) ដែលមិនអាចមានដំណើរការ ។ ទន្ទឹមនឹងនេះ ការបង្កើតប្រព័ន្ធផ្លូវការមួយដើម្បីតាមដានត្រួតពិនិត្យការអប់រំសិទ្ធិមនុស្ស ដោយគ្របដណ្តប់ដំណើរអនុវត្តគំរោងថ្មីទាំងមូល ក៏មានសារៈសំខាន់ខ្លាំងណាស់ដែរ ។ ប៉ុន្តែ ទោះជាយ៉ាងណាក្តី បច្ចុប្បន្នក៏នៅតែមិនទាន់មានប្រព័ន្ធជាក់លាក់ណាមួយដើម្បីតាមដានត្រួតពិនិត្យវាយតម្លៃការប្រើប្រាស់គោលវិធីនេះនៅឡើយ ។

## ខ. ច្បាប់អប់រំ

ច្បាប់អប់រំ គឺជាឧបករណ៍ខាងផ្លូវច្បាប់ដ៏ចំបង ដែលផ្តល់នូវវិធានការទាំងឡាយគាំទ្រការអប់រំសិទ្ធិមនុស្សក្នុងប្រព័ន្ធសាលារៀន ។ ច្បាប់អប់រំបានឱ្យនិយមន័យការអប់រំដោយសំដៅដល់ " **កិច្ចដំណើរការអភិវឌ្ឍការសិក្សា ឬការបណ្តុះបណ្តាលកាយសម្បទា សតិ បញ្ញា និងសីលធម៌ តាមរយៈគ្រប់សកម្មភាពអប់រំ ដែលធ្វើឱ្យអ្នកសិក្សាទទួលបានសំណុំ ចំណេះដឹង ជំនាញ សមត្ថភាព និងតម្លៃ ដើម្បីឱ្យក្លាយខ្លួនជាបុគ្គលល្អ ដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងពិភពលោក ។** " (មាត្រា ៤ នៅក្នុងជំពូក ១) ។

---

[17] មាត្រា ២៣ នៃច្បាប់អប់រំ បានចែងថា " ក្រសួងទទួលបន្ទុកអប់រំ ត្រូវកំណត់ជាក់លាក់នូវកម្មវិធីសិក្សាគោលសម្រាប់ការអប់រំចំណេះទូទៅ ដែលមានលក្ខណៈជាកាតព្វកិច្ចសំរាប់អនុវត្តនៅគ្រប់គ្រឹស្ថានសិក្សាទាំងអស់នៅព្រះរាជាណាចក្រកម្ពុជា ។ ការអប់រំ សីលធម៌ និងពលរដ្ឋវិជ្ជា ការអប់រំឱ្យចេះរួមរស់ជាមួយគ្នា ការអប់រំដើម្បីសន្តិភាព ការអប់រំដើម្បីអភិវឌ្ឍប្រកបដោយចីរភាព ការអប់រំឱ្យចេះគោរពវប្បធម៌ផ្សេងៗ និងតម្លៃប្រពៃណី ត្រូវកំណត់ជាធាតុសំខាន់នៃកម្មវិធីសិក្សាគោល ។

និយមន័យនេះ គ្របដណ្តប់យ៉ាងទូលំទូលាយដល់ប្រភេទផ្សេងៗនៃការអប់រំ គឺមិននិយាយចំពោះតែការបង្រៀននិងរៀនសិទ្ធិមនុស្ស ឬមុខវិជ្ជាប្រភេទផ្សេងដទៃណាមួយប៉ុណ្ណោះទេ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ អ្នកអប់រំល្អគ្រប់រូបក្នុងពិភពលោក តែងកោតសរសើរមនុស្សល្អ ជាបឋមលើគុណធម៌របស់អ្នកនោះក្នុងការគោរពសិទ្ធិមនុស្ស។

ច្បាប់អប់រំ បានបង្កើតឱ្យមានឧត្តមក្រុមប្រឹក្សាជាតិអប់រំ ដែលមានភារកិច្ច :

- លើកសំណើគោលនយោបាយអប់រំ និងយុទ្ធសាស្ត្ររយៈពេលវែងសំដៅឆ្លើយតបទៅនឹងសំណូមពរអភិវឌ្ឍសង្គម សេដ្ឋកិច្ចរបស់ប្រទេសជាតិជូនរាជរដ្ឋាភិបាល។
- វាយតំលៃការងារ ដែលពាក់ព័ន្ធនឹងវិស័យអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈតាមកាលកំណត់ជូនរាជរដ្ឋាភិបាល។
- កៀរគរគ្រប់ធនធាន ដើម្បីបម្រើបុព្វហេតុអប់រំ។ ( មាត្រា ៥ ក្នុងជំពូកទី ២) ។

មាត្រានេះ ផ្តល់នូវមូលដ្ឋាននៃការរួមវិភាគទានដ៏សំខាន់ និងគ្មានទីបញ្ចប់ ពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់ក្នុងវិស័យអប់រំ មិនចំពោះតែការអប់រំសិទ្ធិមនុស្សប៉ុណ្ណោះទេ។

ច្បាប់អប់រំ អនុញ្ញាតឱ្យអង្គភាពសាធារណៈ និងឯកជនបង្កើតស្ថាប័នអប់រំ និងផ្តល់ឱកាសអោយស្ថាប័នប្រភេទផ្សេងៗបានចូលរួមក្នុងការងារអប់រំ។ ទន្ទឹមនឹងនេះ ច្បាប់អប់រំក៏បានលើកទឹកចិត្តការចូលរួមរបស់ស្ថាប័នសាធារណៈ និងឯកជន ក្នុងកម្មវិធីអភិវឌ្ឍ/តាមដានត្រួតពិនិត្យ/វាស់ស្ទង់ការងារអប់រំ ផងដែរ។

នៅទីបំផុត ច្បាប់អប់រំបានរ៉ាយរ៉ាប់សិទ្ធិនិងករណីយកិច្ចរបស់ប្រជាពលរដ្ឋគ្រប់រូប ដែលត្រូវបំពេញអោយបាន ដូចមានខាងក្រោមនេះ :

- សិទ្ធិទទួលការអប់រំ : ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិទទួលបានការអប់រំយ៉ាងតិច ៩( ប្រាំបួន) ឆ្នាំ ប្រកបដោយគុណភាពដោយឥតបង់ថ្លៃនៅសាលារៀនសាធារណៈ។ ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រនិងវិធានការជាជំហានៗ ដើម្បីធានាឱ្យប្រជាពលរដ្ឋគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាព ស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់នេះ។ ( មាត្រា ៣១)
- សិទ្ធិចុះឈ្មោះចូលសិក្សានៅថ្នាក់ទី១( មួយ) នៃកម្មវិធីអប់រំចំណេះទូទៅ : ការចុះឈ្មោះចូលសិក្សានៅថ្នាក់ទី១( មួយ) នៃកម្មវិធីអប់រំចំណេះទូទៅក្នុងប្រព័ន្ធត្រូវបានកំណត់ចំពោះកុមារដែលមានអាយុចាប់ពី៦( ប្រាំមួយ) ឆ្នាំ ឬយ៉ាងទាបបំផុត៧០( ចិតសិប) ខែឡើងទៅ នៅថ្ងៃកំណត់ចូលសិក្សារបស់សាលារៀន។ ( មាត្រា ៣២)
- សិទ្ធិសេរីភាពខាងជំនឿសាសនានៅក្នុងការអប់រំ : រដ្ឋគោរពសិទ្ធិសេរីភាពខាងជំនឿសាសនា។

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវយកចិត្តទុកដាក់ចំពោះព្រះពុទ្ធសាសនា ដែលជាសាសនារបស់រដ្ឋ។ គ្រប់ការបង្ខំឱ្យអ្នកសិក្សា និងអ្នកពាក់ព័ន្ធការអប់រំឱ្យចូលរួមក្នុងសកម្មភាពសាសនា និង/ឬការប្រតិបត្តិសាសនាណាមួយដែលជាផ្នែកនៃការអប់រំ ទោះដោយផ្ទាល់ ឬដោយប្រយោលក្តី ត្រូវហាមឃាត់។

ការសិក្សាអំពីសាសនានៅក្នុងកម្មវិធីសិក្សា ត្រូវបានអនុញ្ញាតសម្រាប់ការយល់ដឹងទូទៅប៉ុណ្ណោះ។ ( មាត្រា ៣៣)

- សិទ្ធិ និងករណីយកិច្ចរបស់អ្នកសិក្សា : សិទ្ធិរបស់អ្នកសិក្សាទាក់ទងនឹងការអប់រំមានដូចតទៅ :
    - សិទ្ធិបញ្ចេញទស្សនៈសិក្សាដោយសេរី

- សិទ្ធិមានសេរីភាពខាងការសិក្សា

- សិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាព

- សិទ្ធិប្រមូលផ្តុំជាក្រុមអ្នកសិក្សា ឬក្លឹបអ្នកសិក្សាក្នុងគោលបំណងសម្រាប់ការអប់រំ

- សិទ្ធិពិនិត្យមើល និងចម្លងកំណត់ត្រផ្ទាល់ខ្លួនស្តីពីការអប់រំ

- សិទ្ធិចូលរួមយ៉ាងសកម្ម និងពេញលេញនៅក្នុងការអភិវឌ្ឍស្តង់ដាអប់រំថ្នាក់គ្រឹះស្ថានសិក្សា និងថ្នាក់ជាតិដោយផ្ទាល់ ឬតាមរយៈតំណាងរបស់ខ្លួន

- សិទ្ធិទទួលបានការគោរព និងការយកចិត្តទុកដាក់ចំពោះសិទ្ធិមនុស្សជាពិសេសសិទ្ធិមានសេចក្តីថ្លៃថ្នូរ សិទ្ធិរួចផុតពីអំពើទារុណកម្ម ឬការដាក់ទណ្ឌកម្មលើរាងកាយ និងផ្នែកស្មារតី ។

ករណីយកិច្ចរបស់អ្នកសិក្សាមានដូចតទៅ :

- គោរពបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថានសិក្សា តម្លៃខាងសមធម៌យេនឌ័រ ដោយអនុវត្តសិទ្ធិរបស់ ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវ និងគោរពសិទ្ធិអ្នកដទៃ ។

- ខិតខំសិក្សាឱ្យអស់ពីលទ្ធភាពរបស់ខ្លួន ដើម្បីទទួលបានការអភិវឌ្ឍចំណេះដឹង ជំនាញ សមត្ថភាព បញ្ញា និងសេចក្តីថ្លៃថ្នូរ ។ ( មាត្រា ៣៥)

- សិទ្ធិទទួលពត៌មានអប់រំ : ពត៌មានអប់រំនៃគ្រប់ស្ថាប័នអប់រំ គ្រឹះស្ថានសិក្សាជាពត៌មានសាធារណៈ លើកលែងតែពត៌មាននោះទាក់ទងនឹងរូបវន្តបុគ្គល ស្ថាប័នអប់រំ គ្រឹះស្ថានសិក្សា ត្រូវផ្តល់ពត៌មានអប់រំដែលមាន ឱ្យទៅអ្នកដែលមានផលប្រយោជន៍តាមការស្នើសុំ ។

បែបបទស្តីពីការផ្តល់ពត៌មានអប់រំ ត្រូវកំណត់ដោយប្រកាសក្រសួងទទួលបន្ទុកវិស័យអប់រំ ។ ( មាត្រា ៤៣)

- ការចូលរួម ការកៀរគរ និងការគ្រប់គ្រងធនធានមនុស្សសម្រាប់ការអប់រំ (ដែលមានអត្ថន័យធ្វើឱ្យសំរេចនូវសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការចូលរួមអភិវឌ្ឍវប្បធម៌ ): រដ្ឋត្រូវជំរុញ និងផ្តល់ការលើកទឹកចិត្តចំពោះសប្បុរសជន តាមភាពសមស្រប និងចាំបាច់ ដោយទទួលស្គាល់ការអប់រំជាការវិនិយោគមួយដ៏ល្អបំផុត ។

បុគ្គល បព្វជិត គ្រួសារ សហគមន៍ អង្គការជាតិ អង្គការអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នរដ្ឋ និងឯកជនទាំងអស់មានសិទ្ធិចូលរួម និងផ្តល់ធនធានយ៉ាងពេញលេញទាំងធនធានមនុស្សទាំងសម្ភារៈ ឬថវិកា ក្នុងគោលបំណងដើម្បីគាំទ្រ និងអភិវឌ្ឍវិស័យអប់រំ ។

អ្នកគ្រប់គ្រងគ្រឹះស្ថានសិក្សា មានសិទ្ធិក្នុងការកៀរគរធនធានស្របច្បាប់នានាពីគ្រប់ប្រភព ដើម្បីអភិវឌ្ឍគ្រឹះស្ថានសិក្សា ។ ការផ្តល់ធនធានត្រូវធ្វើតាមការស្ម័គ្រចិត្ត និងឥតលក្ខខណ្ឌ ។

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវធានានូវតម្លាភាព និងការទទួលខុសត្រូវចំពោះការគ្រប់គ្រងប្រភពធនធាននៃការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ការអប់រំ ។ ( មាត្រា ៤៤ ក្នុងជំពូកទី ៨)

## គ. គោលនយោបាយដទៃទៀតក្នុងវិស័យអប់រំ

គោលនយោបាយអប់រំសម្រាប់ទាំងអស់គ្នា ( មានគោលដៅ ៦ ត្រូវសំរេចឱ្យបាននៅឆ្នាំ ២០១៥), ផែនការយុទ្ធ

សាស្ត្រអប់រំ, គោលនយោបាយសាលាកុមារមេត្រី, និងគោលនយោបាយអប់រំកុមារពិការ សុទ្ធសឹងជាឧបករណ៍គតិយុត្តដែលផ្តល់ការតំរង់ទិសសកម្មភាពគាំទ្រការអប់រំសិទ្ធិមនុស្សក្នុងប្រព័ន្ធសាលារៀន ។

## ឃ. កម្មវិធីគាំទ្រសកម្មភាពជាអាទិភាពក្នុងវិស័យអប់រំ

កម្មវិធីគាំទ្រសកម្មភាពជាអាទិភាពក្នុងវិស័យអប់រំ ក៏មានអត្ថន័យជាកម្មវិធីគាំទ្រការអប់រំសិទ្ធិមនុស្សក្នុងប្រព័ន្ធសាលារៀន ដែរ ។ ថ្វីត្បិតកម្មវិធីនេះ មិនមានការបង្រៀនសិទ្ធិមនុស្សក្នុងសាលារៀន ប៉ុន្តែកម្មវិធីនេះទ្រទ្រង់កម្មវិធីពិសេសៗដទៃទៀត ដែលពាក់ព័ន្ធនឹងការធ្វើឱ្យកុមារសំរេចបាននូវសិទ្ធិរបស់ខ្លួន ។ កម្មវិធីពិសេសៗ មានដូចជា :

- កម្មវិធីអាហារូបករណ៍សំរាប់សិស្សស្រី ក្នុងសាលារៀននៅតំបន់ជនបទដាច់ស្រយាល ។
- កម្មវិធីបង្រៀនថ្នាក់គួប ។
- កម្មវិធីផ្គត់ផ្គង់សម្ភារៈឧបទេស ។
- កម្មវិធីផ្គត់ផ្គង់អាហារពេលព្រឹក ។
- កម្មវិធីថ្នាក់ពីរភាសា ។ល ។

## ង. កម្មវិធីសិក្សាស្តង់ដាសំរាប់ការអប់រំមូលដ្ឋាន

កម្មវិធីសិក្សាស្តង់ដា គឺលទ្ធផលសិក្សាដែលសិស្សអាចបង្ហាញបាននៅចុងបញ្ចប់ដំណាក់កាលណាមួយនៃការសិក្សា ។

កម្មវិធីសិក្សាស្តង់ដា ត្រូវបានអភិវឌ្ឍចប់សព្វគ្រប់នៅខែសីហា ឆ្នាំ ២០០៦ ហើយត្រូវបានប្រើប្រាស់ទន្ទឹមគ្នានឹងការអនុវត្តកម្មវិធីសិក្សាថ្មី ចាប់ពីឆ្នាំ ២០០៧ - ២០០៨តទៅ ។

កម្មវិធីសិក្សាស្តង់ដា ត្រូវបានចែកជូនទៅស្ថាប័នពាក់ព័ន្ធ គ្រប់សាលារៀនបឋមសិក្សា និងមធ្យមសិក្សាសាធារណៈ និងឯកជន សហគមន៍មូលដ្ឋាន អង្គការសង្គមស៊ីវិលនានា និងមាតាបិតាសិស្ស ដើម្បីប្រើប្រាស់ជាមូលដ្ឋានរួមក្នុងការវាស់ស្ទង់លទ្ធផលសិក្សារបស់សិស្ស ឬកូនចៅរបស់ខ្លួន ។

កម្មវិធីសិក្សាស្តង់ដា ជាឧបករណ៍ធានាសិទ្ធិទទួលបានការអប់រំប្រកបដោយគុណភាព ។

## ចំណាប់អារម្មណ៍ទូទៅ

បណ្តាច្បាប់ គោលនយោបាយ និងកម្មវិធីសិក្សា បានបញ្ជាក់ច្បាស់អំពីគុណតំលៃមួយចំនួនដែលគួរនាំមុខបាវចនារបស់សាលារៀន ។ គុណតំលៃទាំងនេះបានផ្សារភ្ជាប់ជាមួយការអប់រំសិទ្ធិមនុស្ស ដូចមានលើកឡើងខាងក្រោមនេះ :

- ➢ កុមារគួរតែធ្វើខ្លួនជាសិស្សល្អ កូនល្អ និងមិត្តល្អ
- ➢ រៀនដើម្បីយល់ដឹង រៀនដើម្បីធ្វើ រៀនដើម្បីរៀបចំខ្លួន និងរៀនដើម្បីរស់នៅជាមួយគ្នា

➢ បរិស្ថានល្អជាជីវិតយើង

➢ កុមារត្រូវការគ្រូល្អ

➢ សិទ្ធិកុមារជាមូលដ្ឋានមាន ៤ គឺ សិទ្ធិមានជីវិត សិទ្ធិទទួលការអប់រំ សិទ្ធិទទួលការការពារ និងសិទ្ធិចូលរួម

គរុកោសល្យ ត្រូវបានផ្តល់សារៈសំខាន់ នៅក្នុងច្បាប់អប់រំ បណ្តាគោលនយោបាយ និងកម្មវិធីសិក្សា ។

សារៈសំខាន់ដែលបានផ្តល់ចំពោះគរុកោសល្យ មានលើកឡើងដូចនៅមាត្រា ៣.១២ នៃគោលនយោបាយសំរាប់អភិវឌ្ឍកម្មវិធីសិក្សា ដូចខាងក្រោម :

កម្មវិធីបង្រៀនសំរាប់កម្មវិធីសិក្សាជាតិក្នុងសាលានីមួយៗ ត្រូវតែៈ

- ជាការបង្រៀនតាមរចនាសម្ព័ន្ធ មានលំដាប់លំដោយតាមប្រព័ន្ធត្រឹមត្រូវ និងជាគោលវិធីសិស្សមជ្ឈមណ្ឌល
- មានសកម្មភាពក្នុងថ្នាក់រៀន និងក្រៅថ្នាក់រៀន
- អោយសិស្សរៀនទាំងទ្រឹស្តី ទាំងអនុវត្តន៍
- ផ្តល់ឱកាសសំរាប់ការលើកទឹកចិត្ត និងការអភិវឌ្ឍភាពច្នៃប្រឌិត និងប្រឌិតញាណរបស់សិស្ស ។

ការអប់រំសិទ្ធិមនុស្ស តំរូវអោយមានការអនុវត្តគរុកោសល្យស្របតាមសេចក្តីណែនាំរបស់គោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សា ។

ប្រការសំខាន់គួរចាប់អារម្មណ៍គឺ ការអប់រំសិទ្ធិមនុស្សបានត្រូវផ្សព្វផ្សាយក្នុងប្រព័ន្ធអប់រំចំណេះទូទៅទាំងមូល ។ ហើយការអប់រំសិទ្ធិមនុស្សក្នុងសាលារៀនបច្ចុប្បន្ននៅកម្ពុជា គឺជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធអប់រំចំណេះទូទៅទាំងមូល ។

## សេចក្តីសន្និដ្ឋាន

ក្នុងការសន្និដ្ឋាន ប្រទេសកម្ពុជាគួរមានមោទនភាពចំពោះសមិទ្ធផលខាងផ្នែកអប់រំសិទ្ធិមនុស្សដ៏ធំធេង ដោយមានច្បាប់អប់រំ បណ្តាគោលនយោបាយអប់រំ ផែនការយុទ្ធសាស្ត្រវិស័យអប់រំ កម្មវិធីសិក្សា គោលនយោបាយបណ្តុះបណ្តាលផ្សេងៗ ល. ដែលបានឆ្លុះបញ្ចាំងអោយឃើញពីបំណង និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការធ្វើអោយបានសំរេចនូវគោលដៅសិទ្ធិមនុស្ស ។

ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តសិទ្ធិមនុស្ស និងការធ្វើអោយបានសំរេចនូវគោលដៅសិទ្ធិមនុស្សកំពុងតែធ្វើដំណើរនៅលើកំណាត់ផ្លូវដែលទទួលផលប៉ះពាល់អំពីបញ្ហាស្មុគស្មាញជាច្រើន ។ ដូចនេះ កិច្ចសហការរវាងបណ្តាអ្នកចូលរួមថ្នាក់អន្តរជាតិ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ដើម្បីដាក់ចុះនូវបំណងអប់រំសិទ្ធិមនុស្ស អោយទៅជាការប្រតិបត្តិជាក់ស្តែងប្រកបដោយផ្លែផ្កា គឺជាបញ្ហាគន្លឹះ ។

យើងមានជំនឿថា ការដាក់ទុនមានកំរិតណា ការទទួលផលក៏មានកំរិតនោះដែរ ។

IV. **អនុសាសន៍**

ទោះបីក្រសួងអយក កំពុងតែអនុវត្តច្បាប់អប់រំ បណ្តាគោលនយោបាយ និងកម្មវិធីសិក្សាយ៉ាងណាក្តី ក៏នៅមានចំណុចខ្វះខាតមួយចំនួនបានលេចឡើងអោយឃើញផងដែរ ។

ជាក់ស្តែង កន្លងមក គេសម្គាល់ឃើញមានចំណុចខ្វះខាតមួយចំនួនដូចខាងក្រោមនេះ:

- សកម្មភាពរបស់ក្លឹបទាំងឡាយរបស់កុមារ( ដែលផ្តោតលើការហ្វឹកហ្វឺនអនុវត្តសិទ្ធិកុមារ) កំពុងត្រូវបានលើកទឹកចិត្ត ប៉ុន្តែសកម្មភាពទាំងនេះមិនទាន់ត្រូវបានពង្រីក ដោយស្របតាមច្បាប់អប់រំ និងដោយទូលំទូលាយនៅទូទាំងប្រទេស នៅឡើយ ។
- គោលវិធីសិស្សមជ្ឈមណ្ឌលត្រូវបានផ្សព្វផ្សាយ ប៉ុន្តែគោលវិធីនេះមិនបានអនុវត្តដោយពេញលេញក្នុងសកម្មភាពរៀន និងបង្រៀននទេ ដោយហេតុថ្នាក់រៀនមួយចំនួន មានសិស្សច្រើនហួសកំណត់ ។
- រាល់ទម្រង់នៃការធ្វើទារុណកម្មលើកុមារក្នុងសាលារៀនត្រូវបានហាមឃាត់ ប៉ុន្តែមិនទាន់មានប្រព័ន្ធជាក់លាក់ណាមួយដើម្បីពិនិត្យតាមដាន និងធ្វើរបាយការណ៍អំពីស្ថានភាពនេះនៅឡើយ ។
- សមធម៌ក្នុងការចូលរៀនត្រូវបានលើកកំពស់ ប៉ុន្តែការបោះបង់ការរៀនសូត្រដែលបណ្តាលមកពីភាពក្រីក្រនៅតែជាបញ្ហាចំបងដែលមិនអាចដោះស្រាយបានក្នុងរយៈពេលខ្លី ។
- ថ្វីត្បិតមានការបង្កើតវគ្គបណ្តុះបណ្តាលសិទ្ធិមនុស្សជាច្រើនវគ្គក៏ដោយ ក៏ការបណ្តុះបណ្តាលនេះមិនទាន់បានទទួលការចូលរួមគ្រប់គ្នាពីសំណាក់មន្ត្រីក្រសួងអប់រំ និងគ្រូបង្រៀន នៅទូទាំងប្រទេសនៅឡើយ ។
- នៅក្នុងកម្មវិធីសិក្សាថ្មី ( អនុវត្តចាប់ពីឆ្នាំ ២០០៧-០៨) មុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា បានក្លាយជាមុខវិជ្ជាជ្រើសរើសនៅថ្នាក់ទី ១១ ដូចមុខវិជ្ជាដទៃមួយចំនួនដែរ ។ ប៉ុន្តែគួរកត់សម្គាល់ថា ក្នុងបណ្តាមុខវិជ្ជាទាំងអស់ មានតែមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជាតែមួយប៉ុណ្ណោះ ដែលមានទីកន្លែងសមស្របច្រើនជាងគេសំរាប់បញ្ជ្រាបការអប់រំសិទ្ធិមនុស្ស ។

ដើម្បីដោះស្រាយចំណុចខ្វះខាតដែលនៅប្រឈមមុខនឹងការអប់រំសិទ្ធិមនុស្ស ក៏ដូចជាការធ្វើអោយសម្រេចបាននូវសិទ្ធិមនុស្ស គួរមានការពិនិត្យពិចារណាលើអនុសាសន៍ដូចខាងក្រោម ចំពោះ:

**ក. ការអនុវត្តបណ្តាគោលនយោបាយអប់រំ និងកម្មវិធីសិក្សា**

- ការលើកកំពស់ការយល់ដឹងអំពីសិទ្ធិមនុស្ស គួរដើរទន្ទឹមគ្នានឹងការធ្វើអោយសំរេចនូវសិទ្ធិហើយ និងការហាត់អនុវត្តសិទ្ធិ ដើម្បីអោយមានការទទួលស្គាល់ថា នេះជាវិធីអប់រំប្រកបដោយប្រសិទ្ធភាពខ្ពស់ ( ទ្រឹស្តីដើរទន្ទឹមគ្នានឹងការនុវត្ត) ។
- ដោយអនុវត្តតាមច្បាប់អប់រំ ការអប់រំសិទ្ធិមនុស្ស ក៏ដូចជាការបង្រៀនមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា គួរដាក់ជាមុខវិជ្ជាចាំបាច់ ដោយហេតុថាពលរដ្ឋដែលបានសិក្សាមុខវិជ្ជានេះ នឹងក្លាយជាពលរដ្ឋដែលមានការទទួលខុសត្រូវក្នុងការអនុវត្តសិទ្ធិនិងករណីយកិច្ចរបស់ខ្លួន ។

**ខ.សម្ភារៈរៀន និងបង្រៀន**

➢ គួរជំរុញការបន្តអភិវឌ្ឍសម្ភារៈរៀន និងបង្រៀនដែលពាក់ព័ន្ធនឹងការអប់រំសិទ្ធិមនុស្ស ដោយស្របច្បាប់ ។

➢ សម្ភារៈរៀន និងបង្រៀនដែលពាក់ព័ន្ធនឹងការអប់រំសិទ្ធិមនុស្ស គួរផ្គត់ផ្គង់អោយបានគ្រប់គ្រាន់ ដើម្បីបំពេញសេចក្តីត្រូវការរបស់សាលារៀន នៅក្នុងប្រទេស ។

**គ. គរុកោសល្យ- ដំណើរការរៀន និងបង្រៀន**

➢ ការអប់រំសិទ្ធិមនុស្សគួរបំបែកចេញជាមុខវិជ្ជាដោយឡែកមួយ ដែលមានខ្លឹមសារសិទ្ធិមនុស្សសព្វគ្រប់ ហើយត្រូវបានទទួលស្គាល់ជាមុខវិជ្ជាចាំបាច់ដែលត្រូវសិក្សាតាមរយៈការអប់រំចំណេះទូទៅ (១២ឆ្នាំ) ។

➢ ការអប់រំសិទ្ធិមនុស្ស គួរចាត់ជាកាតព្វកិច្ចសិក្សារបស់កុមារគ្រប់រូបដើម្បីគេចេះរៀបចំការរស់នៅជាមួយគ្នាដោយសន្តិភាព ។ ក្នុងទស្សនៈនេះ ការអប់រំសិទ្ធិមនុស្សក្នុងប្រព័ន្ធសាលារៀន គួរដើរទន្ទឹមគ្នានឹងការអប់រំសិទ្ធិមនុស្សនៅក្រៅសាលា ។

➢ ក្នុងលំនាំបង្រៀន និងរៀន គួរមានការយកចិត្តទុកដាក់អនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល ។

➢ គួរបង្កើតអោយមានកម្មវិធីពិសេសសំរាប់ការអប់រំសិទ្ធិមនុស្សក្នុងការផ្សាយរបស់ទូរទស្សន៍ ។

**ឃ. ការបណ្តុះបណ្តាលគ្រូ**

➢ ការបណ្តុះបណ្តាលសិទ្ធិមនុស្សដល់គ្រូបង្រៀន គួរមានសំរាប់គ្រូទូទាំងប្រទេស ពីព្រោះការយល់ដឹងអំពីសិទ្ធិមនុស្សនឹងនាំអោយមនុស្សប្រព្រឹត្តអំពើត្រឹមត្រូវ ហើយអាចចៀសវាងបានពី ពីការធ្លាក់ខ្លួនជាជនល្មើសដោយមិនដឹងខ្លួន ។

➢ កម្មវិធីពិភពលោកសំរាប់ការអប់រំសិទ្ធិមនុស្ស គួរឧបត្ថម្ភគាំទ្រការបណ្តុះបណ្តាលសិទ្ធិមនុស្សដល់មន្ត្រីក្រសួងអប់រំ និងគ្រូបង្រៀនដែលកំពុងមានបំណងសិក្សា ។

**ង. ប្រព័ន្ធវាស់ស្ទង់ក៏រិតយល់ដឹងអំពីសិទ្ធិមនុស្ស**

➢ គួរបង្កើតអោយមានប្រព័ន្ធវាស់ស្ទង់ក៏រិតយល់ដឹងអំពីសិទ្ធិមនុស្សថ្នាក់ជាតិ ដែលមានសមាសភាពចូលរួមពីក្រសួងអប់រំ យុវជន និងកីឡា និងអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកផ្នែកសិទ្ធិមនុស្ស ។ ប្រព័ន្ធនេះ មានសិទ្ធិបំពេញការងារក្នុងអាណត្តិរបស់ខ្លួន ។

➢ គួរបង្កើត និងចាប់ផ្តើមអោយមានសកម្មភាពតុលាការផ្នែកអប់រំ ។

**ច. សកម្មភាពក្រៅថ្នាក់**

➢ អ្នកចូលរួមទាំងអស់គួរឧបត្ថម្ភគាំទ្រសកម្មភាពក្រៅថ្នាក់របស់សិស្ស ដើម្បីធានាដល់វិសាលគមពេញលេញនៃការហាត់អនុវត្តសិទ្ធិរបស់គេ( សិទ្ធិកុមារ) ។

**ឆ.បរិយាកាសក្នុងសាលារៀន**

➢ នៅគ្រប់សាលារៀន សម្ភារៈឬឯកសាររៀន-បង្រៀនដែលមានពាក់ព័ន្ធនឹងការអប់រំសិទ្ធិមនុស្សគួរមានគ្រប់គ្រាន់ ដើម្បីអោយសិស្សានុសិស្ស ឬគ្រូបង្រៀនម្នាក់ៗបានប្រើប្រាស់ ពីព្រោះបញ្ញត្តិសិទ្ធិមនុស្សចាំបាច់ត្រូវយកទៅហ្វឹកហាត់ និងផ្ទៀងផ្ទាត់ឡើងវិញតាមខ្លឹមសារដែលមានចងក្រងទុក ។

➢ សាលារៀនគួរបង្កើតអោយមានប្រព័ន្ធ ឬចលករជំរុញការអប់រំសិទ្ធិមនុស្ស និងវាស់ស្ទង់កំរិតយល់ដឹងអំពីសិទ្ធិមនុស្សក្នុងចំណោមសិស្សនិងគ្រូក្នុងសាលារៀន ពីព្រោះប្រព័ន្ធនេះនឹងជួយធានាដល់គុណភាពនៃការអប់រំ ។

## ជ. តួនាទីអ្នកចូលរួម

➢ អ្នកចូលរួមគួរចាត់ទុកវិស័យអប់រំជាវិស័យអាទិភាពក្នុងការដាក់ទុនវិនិយោគ ដើម្បីការលូតលាស់រីកចំរើនរបស់ប្រទេសជាតិ ។

➢ ការចូលរួមអំពីសំណាក់អ្នកចូលរួមនានាក្នុងការស្តាបនាប្រទេសជាតិឡើងវិញ ពិសេសក្នុងវិស័យអប់រំមានសារៈសំខាន់ជាទីបំផុតសំរាប់និរន្តរភាពនៃការអភិវឌ្ឍៈ

- ការឧបត្ថម្ភគាំទ្រគ្រប់ប្រភេទ និងគ្រប់មធ្យោបាយចំពោះវិស័យអប់រំនៅកម្ពុជា កំពុងស្ថិតក្នុងសេចក្តីត្រូវការចាំបាច់ដើម្បីជាប្រយោជន៍ដល់កុមារក៏ដូចជាដើម្បីអោយពិភពលោកមានភាពកាន់តែប្រសើរឡើង ។
- ការទិតៀនពីសំណាក់អ្នកចូលរួមទាំងអស់ គួរតែជាការទិតៀនដើម្បីស្ថាបនា ប្រកបព្រមដោយការណែនាំដែលអាចប្រតិបត្តិបានអំពីវិធីធ្វើអោយមានការផ្លាស់ប្រែ និងគួរតែតាមមើលដោយប្រាកដថាអ្នកមានកំហុសបានដឹងខ្លួន និងបានកែប្រែ ។
- សហប្រតិបត្តិការរបស់បណ្តាអ្នកចូលរួម ក្នុងការអនុវត្តគំរោងអប់រំសិទ្ធិមនុស្ស ក៏ដូចជាការអនុវត្តគោលនយោបាយសំរាប់ការអភិវឌ្ឍកម្មវិធីសិក្សា (២០០៥ -២០០៩) គួរចាប់ផ្តើមចាប់ ពីពេលនេះតទៅ ។

ភ្នំពេញ, ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០០៨

អ្នកស្រាវជ្រាវ

ជិន យ៉ាហាន

ភ្នំពេញ, ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៨

បានឃើញ និងឯកភាព

ប្រធាននាយកដ្ឋានស្រាវជ្រាវគរុកោសល្យ

អេង_គឹមលី

# សេចក្តីបន្ថែម

## ១.ឯកសារពិគ្រោះ


- កម្រងឯកសារច្បាប់មួយចំនួនដែលកំពុងអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា រៀបរៀងដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា, បោះពុម្ពលើកទី ៤ ខែកញ្ញា ឆ្នាំ ២០០៥
- Kampuchea: From Tragedy to Rebirth, Compiled by E.V.KOBELEV, Progress Publishers Moscow, 1979
- ការអប់រំសំរាប់ទាំងអស់គ្នា គោលដៅទាំង៦ សំរាប់ឆ្នាំ ២០១៥, រៀបរៀងដោយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិអប់រំសំរាប់ទាំងអស់គ្នា( គជអទ), បោះពុម្ពលើកទី ២ ខែមេសា ឆ្នាំ ២០០៥
- គោលនយោបាយសំរាប់អភិវឌ្ឍន៍កម្មវិធីសិក្សាចំនេះទូទៅ ២០០៥-២០០៩, រៀបចំដោយនាយកដ្ឋានស្រាវជ្រាវគរុកោសល្យ ឆ្នាំ ២០០៤
- ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ឆ្នាំ ២០០៦-២០១០, ក្រសួងអប់រំ យុវជន និងកីឡា, ខែធ្នូ ឆ្នាំ ២០០៥
- គោលនយោបាយស្តីពីសាលាកុមារមេត្រី, ក្រសួងអប់រំ យុវជន និងកីឡា, ខែ ធ្នូ ឆ្នាំ ២០០៧
- ព្រះរាជក្រម "ច្បាប់ស្តីពីការអប់រំ", ខែធ្នូ ឆ្នាំ ២០០៨
- គោលនយោបាយស្តីពីការអប់រំកុមារពិការ, ក្រសួងអប់រំ យុវជន និងកីឡា, ខែមីនា ឆ្នាំ ២០០៨
- A Master Plan to implement the Policy for Curriculum Development 2005-09, MoEYS
- អាំងឌីកាទ័រអប់រំ ២០០២-០៦, ក្រសួងអប់រំ យុវជន និងកីឡា
- របាយការណ៍បូកសរុបបវេសនកាល ឆ្នាំសិក្សា ២០០៦-២០០៧, នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ
- Human Rights Teaching Methodology in Cambodian Primary and Secondary Schools, Cambodian Institute of Human Rights, HURIGHTTS OSAKA
- The Cambodian League for the Promotion and Defense of Human Roghts and Its Human Rights Education Program, Vann Sophath, Human Rights Education in Asian Schools
- Teaching Human Rights in Cambodia, Dara Yi, Horn Pheng and John Lowrie, Human Rights Education in Asian Schools
- Human Rights Education in Cambodian Schools- The Experience of the Last Three Years, Mengho Leang,Phnom Penh, Cambodia, HURIGHTS OSAKA
- OHCHR in the Field: OHCHR in Asia and the Pacific, OHCHR 2007 Report
- Reaching New Heights in Realizing Child Rights, Five-year report 2002-2006, Child Rights Foundation
- របាយការណ៍បំពេញការងារវិស័យអប់រំឆ្នាំ ២០០៥, ក្រសួងអប់រំ យុវជន និងកីឡា
- ឯកសារបណ្តុះបណ្តាលគ្រូអំពីការអនុវត្តកម្មវិធីសិក្សាអប់រំមូលដ្ឋាន, នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ, ឆ្នាំ ២០០៦


## ២. រចនាសម្ព័ន្ធថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា អាណត្តិទី ៣ (២០០៣-០៨)

ORGANIZATIONAL CHART OF
THE MINISTRY OF EDUCATION, YOUTH AND SPORT




## ៣. មាត្រាមួយចំនួនដកស្រង់ពីគោលនយោបាយអភិវឌ្ឍកម្មវិធីសិក្សា២០០៥-២០០៩

២.១ គោលបំណងនៃកម្មវិធីសិក្សាគឺអភិវឌ្ឍកោសល្យ និងសមត្ថភាពរបស់សិស្ស ដើម្បីអោយគេក្លាយជាមនុស្សពេញលេញរីកចំរើនលូតលាស់គ្រប់ផ្នែកព្រមៗគ្នា ដោយមានតុល្យភាពរវាងប្រាជ្ញា ស្មារតី សញ្ចេតនា និងរូបកាយ។ ជាពិសេសនៅពេលសិស្សបញ្ចប់ការសិក្សា ពួកគេមាន :

- មានចំនួលចិត្ត និងស្រឡាញ់ការសិក្សា ដើម្បីបំរើការងារ និងបន្តការសិក្សាពេញមួយជីវិតបាន។
- មានចំនេះដឹងផ្នែក ភាសាខ្មែរ អក្សរសាស្ត្រខ្មែរ និងគណិតវិទ្យាជាមូលដ្ឋាន។
- មានចំនេះដឹង បំនិន និងឥរិយាបថចាំបាច់ ដើម្បីលើកស្ទួយការថែរក្សាសុខភាព ផ្នែកផ្លូវកាយ បញ្ញាស្មារតីរបស់ខ្លួន ហើយចូលរួមចំនែកក្នុងការលើកស្ទួយការថែរក្សាសុខភាពក្រុមគ្រួសារ និងសង្គមអោយកាន់តែល្អប្រសើរ ថែមទៀត។
- មានសមត្ថភាពគ្រប់គ្រង មានទំនួលខុសត្រូវលើសកម្មភាព លើសេចក្តីសំរេចរបស់ខ្លួន និងមានជំនឿជាក់លើខ្លួនឯង។

- មានការកោតសរសើរ និងអោយតំលៃសារៈសំខាន់នៃគំនិតវិទ្យាសាស្ត្រ បច្ចេកវិទ្យា បង្កើតថ្មី និងគំនិតច្នៃប្រឌិត ។
- មានបំនិនក្នុងការបំរើការងារ យល់ដឹងនិងមានឥរិយាបថវិជ្ជមានចំពោះការងារ និងមានសមត្ថភាពធ្វើការងារជាមួយអ្នកដទៃក្នុងការពិចារណា ថ្លឹងថ្លែង មានស្មារតីទទួលខុសត្រូវ មានសីលធម៌ ចេះបែងចែក វិភាគ ដោះស្រាយបញ្ហាក្នុងគ្រួសារ និងសង្គម ។
- ស្វែងយល់ និងអោយតំលៃដល់អ្នកដទៃ ដល់អរិយធម៌ វប្បធម៌ផ្សេងៗ ប្រវត្តិសាស្ត្រនានា ដែលអាចឈានទៅរកការកសាងស្មារតីសាធារណៈ ក្នុងន័យចេះគោរពសិទ្ធិអ្នកដទៃ និងមានសមធម៌ ។
- ជាពលរដ្ឋសកម្ម មានគំនិតយល់ដឹងជ្រៅជ្រះអំពីការវិវត្តនៃសង្គម ប្រព័ន្ធគ្រប់គ្រង ច្បាប់ទំលាប់របស់ប្រទេសកម្ពុជា ចេះរក្សា និងលើកស្ទួយតំលៃជាតិ មានស្មារតីស្រលាញ់ជាតិ សាសនា និងព្រះមហាក្សត្រ ។
- យល់ដឹងសារៈសំខាន់ និងចេះការពារ ថែរក្សាបរិស្ថានធម្មជាតិ សង្គម និងវប្បធម៌ ។

៥.៣ គោលបំនងនៃកម្មវិធីសិក្សាអប់រំមូលដ្ឋាន គឺចូលរួមចំនែកធ្វើអោយសំរេច គោលបំនងនៃការសិក្សារបស់សិស្សនៅសាលារៀន ដើម្បីមានសមត្ថភាព អាចបន្តការសិក្សានៅមធ្យមសិក្សាទុតិយភូមិ ឬសិក្សាឯកទេស ឬចូលរួមក្នុងជីវភាពសង្គម ដោយធានាថាសិស្សម្នាក់ៗនឹងទទួលបាន :

- ការចេះភាសាខ្មែរ និងគណិតវិទ្យា
- ការស្គាល់អត្តសញ្ញាណជាតិ
- ការយល់ដឹង សីលធម៌រស់នៅ និងការទទួលខុសត្រូវរបស់ពលរដ្ឋចំពោះប្រទេស
- បំនិនជីវិតប្រចាំថ្ងៃ ចាំបាច់សំរាប់ការចូលរួមក្នុងជីវភាពសហគមន៍មូលដ្ឋាន និងក្នុងសង្គមកម្ពុជា
- សមត្ថភាពធ្វើទំនាក់ទំនងជាភាសាបរទេស ។

៦.១ គោលបំនងនៃកម្មវិធីសិក្សាអប់រំមូលដ្ឋានកំរិតបឋមសិក្សា "ថ្នាក់ទី១-៣" គឺធានាថាសិស្សម្នាក់ៗមានមូលដ្ឋានរឹងមាំផ្នែកភាសាខ្មែរ និងគណិតវិទ្យា ព្រមទាំងបានអភិវឌ្ឍសុខភាព កាយសម្បទា សីលធម៌ បំនិនសិក្សា និងបំនិនជីវិត ។

៧.១ គោលបំនងនៃកម្មវិធីសិក្សាអប់រំមូលដ្ឋានកំរិតបឋមសិក្សា "ថ្នាក់ទី៤-៦" គឺពង្រឹង និងពង្រីកចំនេះដឹង និងការយល់របស់សិស្សលើផ្នែក ភាសាខ្មែរ គណិតវិទ្យា បំនិនសិក្សា បំនិនជីវិត សីលធម៌ និងការអភិវឌ្ឍបុគ្គលិកលក្ខណៈ ដែលអាចអោយសិស្សបន្តការសិក្សាពេញមួយជីវិតបាន ព្រមទាំងចាប់ផ្តើមណែនាំសិស្សលើខ្លឹមសារផ្នែកវិទ្យាសាស្ត្រ និងសិក្សាសង្គម ។

៨.១ គោលបំនងនៃកម្មវិធីសិក្សាអប់រំមូលដ្ឋានកំរិតមធ្យមសិក្សាបឋមភូមិ "ថ្នាក់ទី៧-៩ " គឺពង្រីកវិសាលភាពចំនេះ ដឹង បំនិនភាសាខ្មែរ គណិតវិទ្យា វិទ្យាសាស្ត្រ បំនិនជីវិត បំនិនសិក្សា ការអប់រំវិជ្ជាជីវៈ ការអប់រំសីលធម៌ ព្រមទាំងការអភិវឌ្ឍបុគ្គលិកលក្ខណៈចាំបាច់ដើម្បីអោយសិស្សអាចរួមចំនែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកម្ពុជា ហើយមានលក្ខណសម្បត្តិបន្តការសិក្សាទៅថ្នាក់លើ បណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ ឬចូលរួមក្នុងជីវភាពសង្គម ។

៩.៣ គោលបំនងនៃកម្មវិធីសិក្សាមធ្យមសិក្សាទុតិយភូមិ មិនគ្រាន់តែពង្រឹង និងពង្រីកចំនេះដឹងដែលសិស្សទទួលបានពីកម្មវិធីសិក្សាអប់រំមូលដ្ឋានប៉ុណ្ណោះទេ គឺថែមទាំងផ្តល់ការសិក្សាបែបតំរង់ទិស ដើម្បីមានសមត្ថភាពអាចបន្ត

ការសិក្សានៅឧត្តមសិក្សា ឬសិក្សាឯកទេស ឬចូលរួមក្នុងជីវភាពសង្គម ដោយធានាថាសិស្សនឹងទទួលបាន :

- ការចេះដឹងកាន់តែខ្ពស់ផ្នែកអក្សរសាស្ត្រ និងគណិតវិទ្យា
- ការស្គាល់អត្តសញ្ញាណជាតិកាន់តែច្បាស់
- ការអភិវឌ្ឍការយល់ដឹងកាន់តែខ្លាំងពី សីលធម៌រស់នៅ និងការទទួលខុសត្រូវរបស់ពលរដ្ឋចំពោះប្រទេស
- បំនិនជីវិតប្រចាំថ្ងៃ ចាំបាច់សំរាប់ការចូលរួមក្នុងជីវភាពសហគមន៍មូលដ្ឋាន និងក្នុងសង្គមកម្ពុជា
- ការយល់ដឹងកាន់តែទូលំទូលាយពីពិភពលោក និងគោលការណ៍គណិតសាស្ត្រ
- សមត្ថភាពកាន់តែខ្ពស់ក្នុងការទំនាក់ទំនងជាភាសាបរទេស ។

១០.១ គោលបំនងនៃកម្មវិធីសិក្សាថ្នាក់ទី១០ គឺពង្រឹងនិងពង្រីកចំនេះដឹងដែលសិស្សទទួលបានពីកំរិតអប់រំមូលដ្ឋាន ។ ទន្ទឹមនឹងនោះសាលារៀនត្រូវផ្តល់ការណែនាំតំរង់ទិសដល់សិស្សអំពីជំរើសមុខវិជ្ជាដែលត្រូវបន្តសិក្សានៅថ្នាក់ទី១១ និង១២ ។ ការណែនាំនេះត្រូវចាប់ផ្តើមពីដើមឆ្នាំសិក្សា ។

១១.១ គោលបំនងនៃកម្មវិធីសិក្សាថ្នាក់ទី ១១-១២ គឺផ្តល់ឱកាសអោយសិស្សជ្រើសរើសមុខវិជ្ជាឯកទេស ដើម្បីអភិវឌ្ឍចំនេះដឹង អោយកាន់តែស៊ីជំរៅលើមុខវិជ្ជាណាមួយ ឬជ្រើសរើសមុខវិជ្ជាដែលមានមូលដ្ឋានសិក្សាឯកទេសវិជ្ជាជីវៈ ដើម្បី អាចបន្តការសិក្សានៅឧត្តមសិក្សា ឬសិក្សាឯកទេសវិជ្ជាជីវៈ ឬចូលរួមក្នុងជីវភាពសង្គម ។

## ៣. ការរៀបចំកម្មវិធីសិក្សា

៣.១ ក្រសួងអប់រំ យុវជន និងកីឡា (អ.យ.ក) មានភារៈផ្តល់មូលនិធិ ផ្តល់គ្រូបង្រៀន ផ្តល់មធ្យោបាយរូបវ័ន្ត និងប្រភពធនធានផ្សេងៗទៀត ដល់អ្វីដែលមានចែងក្នុងកម្មវិធីសិក្សាជាតិ ។

៣.២ កម្មវិធីសិក្សាជាតិ ត្រូវកំនត់អោយបង្រៀន៣៨សប្តាហ៍ ក្នុងមួយឆ្នាំសិក្សា ។

៣.៣ សាលារៀន សហគមន៍មូលដ្ឋាន អង្គការសហគមន៍ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកផ្តល់សេវាកម្មអប់រំឯកជន ត្រូវអភិវឌ្ឍកម្មវិធីសិក្សាដើម្បីជួយបង្កើនគុណភាព និងជួយពង្រីកកម្មវិធីសិក្សាជាតិអោយកាន់តែមានលក្ខណៈល្អប្រសើរ ។

៣.៤ សាលារៀនត្រូវបង្កើនភាពជាដៃគូជាមួយមាតាបិតាសិស្ស សហគមន៍មូលដ្ឋាន អង្គការសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល ហើយត្រូវអភិវឌ្ឍកម្មវិធីបំនិនជីវិតតាមមូលដ្ឋាន (ក.ប.ជ.ម.) ដែលមានពី២ ទៅ ៥ម៉ោងសិក្សាក្នុងមួយសប្តាហ៍ (មួយម៉ោងសិក្សាមានរយៈពេល៤០នាទី សំរាប់បឋមសិក្សា និង៥០នាទី សំរាប់មធ្យមសិក្សា) ដើម្បីជួយបំពេញកម្មវិធីសិក្សាជាតិ ។

៣.៥ បំនែកចែកម៉ោងសិក្សាសំរាប់ កម្មវិធីសិក្សាជាតិ និងសំរាប់ ក.ប.ជ.ម. មានដូចខាងក្រោម :

| **បឋមសិក្សា** | | |
|---|---|---|
| **កម្មវិធីសិក្សាជាតិ** | **កម្មវិធីបំនិនជីវិតតាមមូលដ្ឋាន** | **សរុប** |
| ៥ម៉ោងសិក្សាក្នុង១ថ្ងៃដែល<br>១ម៉ោងសិក្សាមាន៤០នាទី | ២ម៉ោងសិក្សាក្នុង១សប្តាហ៍<br>១ម៉ោងសិក្សាមាន ៤០នាទី | ២៧-៣០ម៉ោងសិក្សាក្នុង១សប្តាហ៍ |

| | | |
|---|---|---|
| (២៥×៤០នាទីក្នុងមួយ សប្ដាហ៍) | | |
| **មធ្យមសិក្សា (ថ្នាក់ទី ៧-១០)** | | |
| ៣០ម៉ោងសិក្សាក្នុង១សប្ដាហ៍<br>១ម៉ោងសិក្សាមាន ៥០នាទី<br>(៣០×៥០នាទីក្នុងមួយសប្ដាហ៍) | ២-៥ម៉ោងសិក្សាក្នុង១សប្ដាហ៍<br>១ម៉ោងសិក្សាមាន ៥០ នាទី | ៣២-៣៥ម៉ោងសិក្សាក្នុង១សប្ដាហ៍ |
| **មធ្យមសិក្សា (ថ្នាក់ទី ១១-១២)** | | |
| ៣២ម៉ោងសិក្សាក្នុង ១សប្ដាហ៍<br>១ម៉ោងសិក្សាមាន ៥០ នាទី<br>(៣២×៥០នាទីក្នុងមួយសប្ដាហ៍) | | ៣២ម៉ោងសិក្សាក្នុង ១សប្ដាហ៍<br>១ម៉ោងសិក្សាមាន ៥០ នាទី |

៣.៦ គោលបំណងនៃ **ក.ប.ជ.ម.**គឺ

៣.៦.១ ផ្ដល់ឱកាសអោយសាលារៀនសហការជាមួយ មាតាបិតាសិស្ស សហគមន៍មូលដ្ឋាន អង្គការសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងការរៀបចំខ្លឹមសារកម្មវិធីសិក្សាមូលដ្ឋានមួយ ដែលពាក់ព័ន្ធទៅនឹងតំរូវការជាក់លាក់របស់សិស្សតាមមូលដ្ឋានរបស់ពួកគេ។

៣.៦.២ ផ្ដល់ឱកាសអោយសាលារៀនប្រើពេលវេលាក្នុងកម្មវិធីសិក្សាសំរាប់ធ្វើសកម្មភាពបន្ថែមដូចជា សេវាកម្មសង្គម ឬសកម្មភាពចលនាយុវជន ដែលអាចជួយសិស្សមានទំលាប់ទទួលខុសត្រូវ និងមានទំនុកចិត្តថែមទៀតលើខ្លួនគេ។ ទំលាប់ទាំងនេះត្រូវបណ្ដុះអោយបានរឹងមាំនៅកំរិតបឋមសិក្សាដោយប្រើ ពេលវេលាដែលមានក្នុង ក.ប.ជ.ម.។

៣.៧ សាលារៀនមានភារៈទទួលខុសត្រូវក្នុងការរៀបចំរកមូលនិធិ រកបុគ្គលិក ព្រមទាំងបំពាក់សំភាររូបវ័ន្ត និងបរិក្ខារ សំរាប់ ក.ប.ជ.ម. ដោយសហការជាដៃគូជាមួយមាតាបិតាសិស្ស សហគមន៍មូលដ្ឋាន អង្គការសហគមន៍ និងអង្គការមិនមែនរដ្ឋាភិបាល។

៣.៨ នៅថ្នាក់ទី១១ និង១២ នៃមធ្យមសិក្សាទុតិយភូមិ កម្មវិធីសិក្សាត្រូវបានផ្ដល់តាមរយៈមុខវិជ្ជា កម្មវិធីសិក្សាជាតិ និងកម្មវិធីអប់រំវិជ្ជាជីវៈជំរើស។ ចំនែកនៅថ្នាក់ទី១០មាន កម្មវិធីសិក្សាជាតិ និងកម្មវិធីបំនិនជីវិតតាមមូលដ្ឋាន។

៣.៩ គោលបំណងនៃកម្មវិធីអប់រំវិជ្ជាជីវៈជំរើស គឺផ្ដល់ឱកាសអោយសិស្សចូលរួមក្នុងកម្មវិធីបណ្ដុះបណ្ដាលវិជ្ជាជីវៈដែលផ្ដល់ដោយមូលដ្ឋាន។

៣.១០ មុខវិជ្ជាក្នុងកម្មវិធីអប់រំវិជ្ជាជីវៈជំរើស ត្រូវផ្ដល់ដោយក្រសួង អ.យ.ក និង/ឬផ្នែកសេវាកម្មអប់រំឯកជនក្នុងលក្ខណៈជាដៃគូ ដែលទទួលស្គាល់និងអនុញ្ញាត (ចុះបញ្ជី) ដោយក្រសួង អ.យ.ក។ សិស្សដែលសិក្សាក្នុងកម្មវិធីអប់រំវិជ្ជាជីវៈជំរើស នឹងទទួលការផ្គត់ផ្គង់មូលនិធិដោយក្រសួង អ.យ.ក ដៃគូសហការ ឬបង់ថ្លៃ។

៣.១១ កម្មវិធីសិក្សាសំរាប់មុខវិជ្ជាក្នុងកម្មវិធីអប់រំវិជ្ជាជីវៈជំរើស ត្រូវទទួលការយល់ព្រមពីក្រសួង អ.យ.ក

ហើយវង្វាយតំលៃមុខវិជ្ជាទាំងនេះក៏ត្រូវទទួលការណែនាំពីក្រសួង អ.យ.ក ដែរ។

៣.១៤ សាលារៀនត្រូវតែផ្តល់ឱកាសស្មើគ្នា រវាងសិស្សប្រុស និងសិស្សស្រី ក្នុងការទទួលគ្រប់សមាសភាគអប់រំដែលមានក្នុងកម្មវិធីសិក្សា។ សាលារៀនគួរតែខំប្រឹងប្រែងជាពិសេសក្នុងការជួយសំរួលអោយសិស្សស្រីបានចូលរួមគ្រប់ទិដ្ឋភាពនៃកម្មវិធីសិក្សា។

៣.១៥ សាលារៀននីមួយៗគួរផ្តល់ឱកាសសំរាប់ជំរុញសិស្សពូកែ។ ការងារទាំងនេះអាចធ្វើបាន ដោយអោយសិស្សពូកែ និងសិស្សដែលមានកោសល្យបង្កើនសមត្ថភាពពួកគេ ដោយប្រើម៉ោងសិក្សា ដែលបានកំនត់នៅក្នុង ក.ប.ជ.ម. ។

៣.១៦ សាលារៀនត្រូវជួយជ្រោមជ្រែងសិស្សដែលមានការលំបាកក្នុងការសិក្សា តាមរយៈជំនួយរបស់គ្រូក្នុងម៉ោងសិក្សា និងតាមរយៈកម្មវិធីពិសេសដែលបានកំនត់ក្នុង ក.ប.ជ.ម.។

៣.១៧ សាលារៀននីមួយៗត្រូវព្យាយាមផ្តល់សិទ្ធិទទួលការអប់រំក្នុងកម្មវិធីសិក្សា ដល់សិស្សពិការ។

៣.១៨ ចំពោះកម្មវិធីវង្វាយតំលៃ សាលារៀននីមួយៗគួរតែផ្តល់ការបញ្ជាក់យ៉ាងច្បាស់លាស់ដល់សិស្ស និងមាតាបិតាសិស្សអំពីកំរិតលទ្ធផលដែលសិស្សទទួលបាន ធៀបទៅនឹងកំរិតស្តង់ដាដែលរំពឹងទុកក្នុងកម្មវិធីសិក្សាថ្មី និងធៀបទៅនឹងស្តង់ដានៃកម្មវិធីសិក្សាសំរាប់សិស្សថ្នាក់ទី៣ ទី៦ ទី៩ និងទី១២ (ស្របតាមគោលនយោបាយចែងក្នុងការអប់រំសំរាប់ទាំងអស់គ្នាទំព័រ៦០)។ វង្វាយតំលៃនេះគួរតែបង្ហាញដល់សិស្សនូវពត៌មានច្បាស់លាស់អំពីចំនុចខ្លាំង ចំនុចខ្សោយ និងជំហានដែលពួកគេត្រូវអនុវត្ត ដើម្បីបង្កើនលទ្ធផលសិក្សារបស់ពួកគេ។ សាលារៀនត្រូវរាយការណ៍ជូនមាតាបិតាសិស្ស ពីការចូលរួមរបស់សិស្ស ពីសមិទ្ធផលរបស់សិស្សលើគ្រប់សមាសភាគនៃកម្មវិធីសិក្សាដែលមានក្នុងសាលារៀន។

៣.១៩ ភាសាខ្មែរជាភាសាយានក្នុងការបង្រៀន។ សៀវភៅសិក្សាត្រូវបោះពុម្ពជាភាសាខ្មែរ លើកលែងតែសៀវភៅមុខវិជ្ជាភាសាបរទេស។ នៅសាលារៀនណាដែលមានសិស្សភាគច្រើននិយាយភាសាខ្មែរ ត្រូវអាចប្រើភាសាជនជាតិខ្លះៗបានក្នុងការបង្រៀន ហើយគ្រូបង្រៀនគួរតែបកប្រែវាក្យស័ព្ទគន្លឹះសំខាន់ៗដែលមានក្នុងសៀវភៅសិក្សាពីភាសាខ្មែរទៅភាសាជនជាតិទាំងនោះ ដើម្បីជាមធ្យោបាយជួយសិស្សក្នុងការសិក្សា។

## ៤. គំរូសំណួរសិក្សាស្រាវជ្រាវការអប់រំសិទ្ធិមនុស្ស (ផ្ញើទៅក្រុមគោលដៅ ពីថ្ងៃទី០២-១៦ខែឧសភា ២០០៨)

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**គណៈកម្មការសំរាប់ការអប់រំសិទ្ធិមនុស្ស**

### គំរូសំណួរស្រាវជ្រាវអំពីការអប់រំសិទ្ធិមនុស្សរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីចូលរួមក្នុងកម្មវិធីពិភពលោកសំរាប់ការអភិវឌ្ឍ និងអនុវត្តក្នុងសាលារៀន

**១.សមាសភាពទូទៅ**

ក. គោលនយោបាយ

